# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

INSTITUT BOUDDHIQUE

ឆ្នាំទី ២៧ ខែតុលា លេខ ១០

ព.ស.២៤៩៧ – គ.ស.១៩៥៥

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ដ្រ
បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

បញ្ជីរឿង

*ផ្នែកសាសនា* — ទំព័រ

— សាសនាមានប្រយោជន៍យ៉ាងណា .... ព្រះបាឧលិវង្ស សូរ-ហាយ .. ៧២៣
— បញ្ញាសជាតក ភាគទី ៤ (តមក).... បណ្ឌិតមហា ឈឹម -ស៊ុម .... ៧៣៤
— រឿងធម្មទូជបណ្ឌិត (តចប់) ....... លោក ជាំ-ឌុំ .......... ៧៤១

*ផ្នែកអក្សរសាស្ដ្រ*

— ពិធីបំបួសនាគជាតិភូមា .......... លោក ញែម -វឹម ....... ៧៦៩
— រឿងសាមកុក (តមក).......... ឧកញ៉ា នូ- កន ......... ៧៨២
— ដំណឹងតាមខ្យល់ក្នុងកត្តារ: (តមក)... លោក ផេង -ជ្រីវ ......... ៧៨៨
— រឿងបល្ល័ង្កទិព្យ (តមក)......... លោក ភ៉យ- ប៊ុក ......... ៧៩២

មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃជាវ ២១០៛.០០

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique

## *TABLE DES MATIÈRES*

**PARTIE RELIGIEUSE:** *Page*


— Les Bienfaits de Religion . . . *Vén. SO-HAY* . . . . . . . 723
— Pannasajataka-vol. 4 (suite.) . *M. CHHIM-SOUM* . . . . 734
— Dhammadhajapandit (suite et fin) . . . . . . . . *M. KAM-DOUM* . . . . . 751


**PARTIE LITTERAIRE:**


— Cérémonie d'ordination Birmane . . . . . . . . . . *M. NHEM-KHEM* . . . . 769
— Histoire de SAMKOK (suite) . . *Okuba NOU-KAN* . . . . . 782
— Le souffle du désert (suite) . *M. PHENG-CHRIV* . . . 788
— Les trente deux récits du TRONE (suite) . . . . . . . *M. RAY-BUC* . . . . . . 792


Prix d'abonnement annuel (comprenant 12 numéros) 210,00

# សាសនាមានប្រយោជន៍យ៉ាងណា?

## របស់ព្រះឧបាលិវង្ស ស៊ូរ-ហាយ ក្រុមជំនុំព្រះត្រៃបិដក

---

សាសនាមានប្រយោជន៍ធំទូលាយ ឬមិនធំទូលាយ ដូចដំណើរសេចក្ដីដែលត្រូវអធិប្បាយតទៅ ប៉ុន្តែមុននឹងអធិប្បាយអំពីប្រយោជន៍របស់ព្រះពុទ្ធសាសនា សូមចែកប្រភេទសាសនាដែលមាននៅក្នុងលោកមុនសិន ព្រោះសាសនាក្នុងលោកបច្ចុប្បន្ននេះមានច្រើន គឺថា ប្រជាជនគ្រប់ជាតិសុទ្ធតែកាន់សាសនា ឥតមានជនជាតិណាមួយ ដែលមិនមានសាសនាសម្រាប់កាន់នោះឡើយ បើទុកជាសាសនាមិនមានគោលចារឹកយ៉ាងណាក៏ដោយ គង់មានសាសនាព្រៃផ្សៃ ដោយការគោរពជឿខ្មោចបិសាចជាដើមពុំខាន ។

សាសនាទោះបីមានច្រើន តាមចំនួនប្រជាជនគ្រប់ជាតិ ក៏ពិតមែន ប៉ុន្តែបើកប់យកចំពោះសាសនាធំៗ មានតែត្រឹម ៤ ប្រភេទ គឺ

១– ពុទ្ធសាសនា សាសនាព្រះពុទ្ធ

២– ព្រាហ្មណសាសនា សាសនាព្រាហ្មណ៍

៣– គ្រិស្ដសាសនា សាសនាគ្រិស្ដ

៤– ឥស្លាមសាសនា សាសនាឥស្លាម ។

សាសនាក្រៅពីនេះ មានច្រើនទៀតជាសាសនាកើតអំពីអ្នកប្រាជ្ញ ដូចយ៉ាងសាសនានៅប្រទេសចិន ដែលកើតអំពីឡាវជឺនឹងខុងជឺជាដើម ។

ក្នុងទីនេះ សូមអធិប្បាយដោយសង្ខេប ចំពោះសាសនាទាំង ៤ ប្រភេទ ដូចតទៅនេះ ៖

១.— ពុទ្ធសាសនា ជាសាសនាផ្សាយចេញអំពីមហាបុរសមួយរូប ជាព្រះរាជបុត្រនៃព្រះបាទសុទ្ធោទនៈ និងព្រះនាងមហាមាយាទេវី ជាក្សត្រសោយរាជ្យក្នុងក្រុងកបិលពស្តុ នាប្រទេសឥណ្ឌា ។ មហាបុរសនេះ ព្រះនាមដើមហៅ សិទ្ធត្ថៈ មិនពេញព្រះហឫទ័យក្នុងរាជសម្បត្តិ ទើបចេញទៅទ្រង់ព្រះផ្នួស ស្វែងរកអនុត្តរសម្មោធិញ្ញាណ ដោយព្យាយាមដ៏ឧក្រិដ្ឋ ជាទុក្ករកម្មអស់ប្រាំមួយឆ្នាំ បានត្រាស់ដឹងឃើញធម៌ប្លែកអស្ចារ្យចំពោះធម៌ដែលមិនធ្លាប់ចេះដឹង ពីកាលមុនមក ហើយស្រាប់តែឃើញច្បាស់ បានទទួលឋានៈថាជាព្រះពុទ្ធ ។ បន្ទាប់ពីនោះមក ទ្រង់ក៏ចេះតែស្តេចយាងទៅសំដែងធម៌ប្រោសប្រជាជនក្នុងស្រុកតូចធំ និគមរាជធានី តាមពុទ្ធអធ្យាស្រ័យ ។ អ្នកដែលមានសទ្ធាបញ្ញាចាស់ក្លា ក៏ប្រគល់កាយថ្វាយខ្លួន ចូលបួសតាមព្រះអង្គ, អ្នកខ្លះគ្រាន់តែចុះចូលជឿតាម ប៉ុន្តែនៅជាភេទគ្រហស្ថ ដោយគ្រាន់តែប្រកាសខ្លួនថាជាឧបាសកឧបាសិកា ។ សាសនារបស់ព្រះអង្គក៏រីកធំទូលាយផ្សព្វផ្សាយជាលំដាប់មក ។

ពុទ្ធសាសនា លើកយកសរណគមន៍ ៣ ជាវត្ថុស័ក្តិសិទ្ធិដែលហៅថា “ត្រៃសរណគមន៍គឺព្រះពុទ្ធ ១ ព្រះធម៌ ១ ព្រះសង្ឃ ១” ។ មានគម្ពីរ ៣ ជាគោលធំ ហៅថាព្រះត្រៃបិដក គឺព្រះវិន័យបិដក ១ សុត្តន្តបិដក ១ អភិធម្មបិដក ១” ។ ព្រះត្រៃបិដកនេះមានគម្ពីរចែកចេញជាច្រើនទៀត

ដែលហៅថា "គម្ពីរអដ្ឋកថា, ដីកា" ។ អត្ថរសពុទ្ធសាសនា ក្នុងផ្ទៃគម្ពីរ ទាំងនេះមានសារប្រយោជន៍ជាច្រើន ដែលសម្រាប់ទូន្មានប្រៀនប្រដៅ ពត់និស្ស័យសន្តាន របស់ប្រជាជន ឲ្យមានសីលធម៌ល្អឡើង ខុសពីប្រក្រតីដើម ។ ពុទ្ធសាសនាសម្បូណ៌ដោយអត្ថបទល្អច្រើនណាស់ ហើយសុទ្ធតែមានហេតុផលប្រាប់ប្រយោជន៍ដល់បុគ្គលអ្នកប្រព្រឹត្តតាំងអំពីប្រយោជន៍បច្ចុប្បន្ន ប្រយោជន៍បរលោកទឹងមគ្គផលនិព្វាន ។

## ២.— ព្រាហ្មណសាសនា ឬហៅថា ព្រហ្មញ្ញសាសនា

ក៏បាន, សាសនានេះចាស់ទុំជាងសាសនាឯទៀតទាំងអស់ ប៉ុន្តែមិនមានចេញឈ្មោះអ្នកបង្កើតសាសនាព្រាហ្មណ៍ថាឈ្មោះអ្វីទេ ។ សាសនានេះគោរពបោកអ្នកសក្តិសិទ្ធិច្រើនអង្គ ប៉ុន្តែដែលធំ ប្រសើរជាងគេនោះ ៣ អង្គ គឺព្រះព្រហ្ម ១ ព្រះសិវៈ ឬហៅព្រះឥសូរ ១ ព្រះវិស្ណុ ឬហៅព្រះនារាយន៍ ១ ។ ព្រះទាំង ៣ ព្រះអង្គនេះគង់នៅឯឋានសួគ៌ជានិច្ច ជាព្រះបិតរនៅប្រចាំលោក ពុំចេះច្យុតប្រែប្រួលឬវិនាសទេ ។ សាសនានេះ មានគម្ពីរ ជាគោលដើមនោះ ៣ គម្ពីរ ហៅថាគម្ពីរត្រៃវេទ (វេទ ៣) គឺគម្ពីរ សាមវេទ សំដែងអំពីពលិកម្ម ការបួងសួងសូមឲ្យព្រះអភិបាលរក្សាមនុស្សលោក ១, គម្ពីរឥរុវេទ សំដែងអំពីគុស្តីសូមឲ្យព្រះប្រទានពរឲ្យបានសម្រេចខាងហត្ថកម្ម ១, គម្ពីរយជុវេទ សំដែងអំពីយុទ្ធសង្គ្រាមសូមឲ្យមានជ័យជំនះឲ្យមានជោគជ័យ ១ ។

គម្ពីរត្រៃវេទទាំងនេះបែកចេញជាច្រើនគម្ពីរទៀត ដូចជាគម្ពីរព្រះត្រៃបិដកយើងដែរ ។

៣.— គ្រិស្តសាសនា ជាសាសនាដែលកើតអំពីបុរសម្នាក់ ឈ្មោះ ហ្ស៊េ-ហ្ស៊ុយ ជាជាតិជ្វីហ្វដែលកើតឡើងក្នុងកាល ព.ស. ៥៤៣ ជាកូនរបស់ជោសែហ្វនិងនាងម៉ារី នៅក្រុងបេថលេហេម ជិតក្រុងហ្ស៊េរុយសាឡែម ។ សាសនានេះ ហៅថា "យេស៊ូសាសនា ឬ កាតូលិកសាសនា" ក៏បាន លើកយកវត្ថុស័ក្តិសិទ្ធិ ៣ យ៉ាងទុកជាគោលធំ គឺព្រះបិតា ១ ព្រះបុត្រ ១ ព្រះវិញ្ញាណបរិសុទ្ធ ១, មានគម្ពីរជាគោលដើម នោះឈ្មោះគម្ពីរ ប៊ីប្ល៍ (Bible) ។ សាសនានេះ សំដែងថាមានព្រះដែលធំនោះមួយអង្គ ព្រះនាម យ៉ះហោវ៉ា គង់នៅឋានសួគ៌ ឯព្រះហ្ស៊េ-ហ្ស៊ុយគ្រិស្ត ឬហៅថាព្រះយេស៊ូ គ្រាន់តែជាអ្នកប្រដៅសាសនាតំណាងព្រះអង្គប៉ុណ្ណោះ មានបញ្ញត្តិរបស់ព្រះម្ចាស់សួគ៌ ១០ យ៉ាង មានបទបញ្ញត្តិថា ត្រូវគោរពបូជាព្រះម្ចាស់សួគ៌ជាដើម ។

៤.— ឥស្លាមសាសនា ជាសាសនាដែលកើតអំពីបុរសម្នាក់ ឈ្មោះមោហាម៉ែទ ជាជាតិអារ៉ាប់ កើតក្នុងស្រុកម៉េកះ ក្នុងកាល ព.ស. ១១១៣ ។ ស្រុកម៉េកះនេះ នៅក្នុងប្រទេសអារ៉ាប់ ។ មោហាម៉ែទជាមនុស្សក្លាហានអង់អាចហ៊ានពុះពារឧបសគ្គ ខាងក្រោយមកបានតាំងខ្លួនជាសាស្តាចារ្យប្រដៅសាសនា ដោយអាងថា ខ្លួនបានក្បួនអំពីទេពតា ហើយលើកខ្លួនឯងថាបាននាមថា "ន:ប៊ី" ។ ពាក្យ "ន:ប៊ី" នេះជាពាក្យអារ៉ាប់ ត្រូវនឹងពាក្យបាលីថា "សព្វញ្ញូ" ខ្មែរយើងថា "អ្នកដឹងសព្វ" ។ មោហាម៉ែទ ចាប់ផ្តើមប្រកាសសាសនាឡើងឲ្យឈ្មោះថា "ឥស្លាមសា-

សនា” បើប្រែមកជាខ្មែរថា “សាសនាស្រោចស្រង់សត្វ,, ៗ បរិស័ទអ្នកចុះចូលជឿស៊ប់ក្នុងឥស្លាមសាសនានេះ ចុះនាមថា “មុស្លីម៉ាន់” ត្រង់គ្នានឹងពាក្យយើងថា “ឧបាសក ឧបាសិកា” ដែរ ៗ ឥស្លាម-សាសនានេះ ហៅថា “មោហម័ទសាសនា” ក៏បាន ៗ សាសនានេះមានគម្ពីរដើមមួយឈ្មោះគម្ពីរកោរ៉ាន ឬកូរ៉ាន សំដែងថា “មានព្រះដែលធំនោះតែមួយអង្គ គឺព្រះអាហ្លា គង់នៅឯឋានសួគ៌, ឯព្រះមោហម័ទគ្រាន់តែជាទេវទូតចុះមកប្រដៅសាសនាតំណាងព្រះអាហ្លាប៉ុណ្ណោះ” ៗ សាសនានេះមានពិធីជាករណីយកិច្ចធំៗ ៣ យ៉ាង គឺការឧស្សាហ៍សូត្រមន្ត ១ ការអត់អាហារតាមកំណត់ថ្ងៃ ១ ការឲ្យទានដល់មនុស្សសត្វ ១ ៗ

សាសនាទាំងអស់ ក្នុងសកលលោក សុទ្ធតែមានបញ្ញត្តិមានឧទ្ទេស មានអត្ថបទសម្រាប់ប្រៀនប្រដៅដើម្បីប្រយោជន៍ឲ្យមនុស្សជឿជាប់ចិត្តទៅជាទំនៀមដោយឥតហេតុផលក៏មាន ប្រដៅមនុស្សឲ្យមានសីលធម៌ក៏មាន ប៉ុន្តែក្នុងទីនេះ យើងអ្នកនិពន្ធ មិនមានបំណងអធិប្បាយអំពីប្រយោជន៍របស់សាសនាទាំងនោះទេ សូមអធិប្បាយចំពោះតែប្រយោជន៍របស់ព្រះពុទ្ធសាសនាមួយប៉ុណ្ណោះ ដូចសេចក្តីតទៅនេះ ៖

## ព្រះពុទ្ធសាសនាមានប្រយោជន៍ដល់ប្រទេសជាតិ

វិជ្ជាស្ថាននៃពុទ្ធសាសនា ជាវិជ្ជាដែលមានគុណ តម្លៃគួរអ្នកសិក្សាចំណាយពេលវេលា ដើម្បីសិក្សាផ្លូវសាសនាឲ្យយល់គោលបំណងរបស់លោកអ្នកប្រាជ្ញ ក្នុងសម័យជាន់មុន ព្រមទាំងប្រយោជន៍របស់សាសនាក្នុងសកលលោក ព្រោះថា សាសនាសុទ្ធតែជាអនុសាសនី សម្រាប់

បៀនប្រដៅមនុស្ស ឲ្យបែរមុខទៅរកផ្លូវល្អ ដែលមានប្រយោជន៍ច្រើនក៏មាន តិចតួចមានប្រយោជន៍ក៏មាន ប៉ុន្តែទុកជាយ៉ាងណា ក៏យើងគួរសិក្សាឲ្យស្គាល់មូលហេតុនៃសាសនា ដើម្បីជាគ្រឿងស្ទាបស្ទង់ពិចារណាមើល ឲ្យកើតសតិបញ្ញាបរិបូណ៌សម្រាប់ឋានៈនៃខ្លួនជាបុរសស្ត្រីអ្នកសិក្សា អាចឃើញប្រយោជន៍ដូចតទៅនេះ ៗ

១.– ព្រះពុទ្ធសាសនាទុកដូចជាមហាមន្ទីរជាទីកើតនៃសីលធម៌ទាំងប្រពៃណីដ៏ល្អ ដែលគួរប្រតិបត្តិតាម ជាផ្លូវដើម្បីរំលត់ទុក្ខនាំសេចក្ដីសុខមកឲ្យដល់មនុស្សអ្នកប្រតិបត្តិ ទុកដូចជាដួងប្រទីបមួយដ៏ធំ ក្នុងលោកសម្រាប់ត្រួលបំភ្លឺឲ្យមនុស្សលោកឃើញផ្លូវប្រតិបត្តិ ដើរកាត់តម្រង់ទៅរកសន្តិសុខទាំងក្នុងបច្ចុប្បន្ននិងបរលោក ជាសាសនាលូកកាវរកឃើញមគ្គផលនិព្វានបាន ៗ ព្រះពុទ្ធសាសនាមានគុណភាពប្រកបដោយប្រយោជន៍ជាច្រើនយ៉ាង ដូចយ៉ាងសេចក្ដីចំរើនឈានលឿនទៅមុខរបស់មនុស្សលោក ក៏ច្រើនតែកើតមកអំពីព្រះពុទ្ធសាសនាជាដំបូង សូម្បីវេជ្ជសាស្ត្រនិងវិទ្យាសាស្ត្រដែលកប់ថាជាវិជ្ជាសម័យថ្មី ក៏កើតមកអំពីអ្នកប្រាជ្ញដែលចម្លងផ្ដិតយករបៀបអំពីព្រះពុទ្ធសាសនាខ្លះ មិនខាន បើមិនច្រើនក៏តិច ៗ

គ្រប់ប្រទេសទាំងអស់ ច្រើនតែទទួលដឹងថា សេចក្ដីចម្រើនក្នុងសិល្បៈវិទ្យាបានទទួលកំណើតអំពីសាសនា ៗ អ្នកប្រាជ្ញប្រវត្តិសាស្ត្រប្រទេសជប៉ុន បានសរសេរចុះក្នុងប្រវត្តិសាស្ត្រថា "ព្រះពុទ្ធសាសនាជាសាសនានាំសេចក្ដីចំរើនមកប្រគល់ឲ្យប្រទេសជប៉ុន, ព្រះពុទ្ធសាសនា

បានបើកទ្វារប្រទេសជប៉ុន ដោយទ្រឹស្តីមុនដំបូងបង្អស់ ឲ្យប្រទេសជប៉ុន ឈមមុខទៅរកសេចក្តីចំរើន ព្រោះហេតុនោះ យើងជាជាតិជប៉ុននៅចុង ប៉ូចបូព៌ាប្រទេស គួរណាស់តែសើរើសិក្សាអនុវត្តព្រះពុទ្ធសាសនាដោយ គោរព មិនត្រូវធ្វេសប្រហែស" ។

២.– ព្រះពុទ្ធសាសនាជាអន្ទង់សម្រាប់កើតនៃការសិក្សា ទោះបី ការសិក្សានោះ ពុំបានធំទូលាយក៏អាចចិញ្ចឹមការសិក្សាឲ្យមានជីវិតជាប់ ពូជពារមិនដាច់ ។ ប្រទេសកម្ពុជារបស់យើងដែលមានការចេះដឹងក្នុង ផ្លូវលទ្ធិសាសនាក្តី ក្នុងផ្លូវអក្សរសាស្ត្រក្តី សុទ្ធតែកើតអំពីវត្តអារាមរបស់ ព្រះពុទ្ធសាសនាជាដំបូង សូម្បីវិជ្ជាពេទ្យក៏ច្រើនតែកើតមកអំពីបព្វជិត ពុទ្ធសាសនា ទោះបីមានវិន័យហាមមិនឲ្យបព្វជិតធ្វើពេទ្យមើលជម្ងឺ ក៏ ហាមបានដោយក្រណាស់ ដោយហេតុបព្វជិតមើលជម្ងឺឲ្យទទេ មិន បាច់យកថ្លៃ ។

៣.– វត្តអារាមជាកន្លែងប្រជុំនៃប្រជាជន ដើម្បីសន្ទនាពីធម៌អាថ៌ ឬពីព្រឹត្តិការណ៍ណាមួយ តាមសេចក្តីចេះដឹងក្នុងសម័យនិយមនោះ ៗ ។ វត្តអារាមទុកជាពេងហត្ថកម្មមួយរបស់ការដាង មានការដាងឈើកសាង វិហារសាលាជាដើម ។ ពូជពារនៃសេចក្តីចម្រើនរបស់ប្រទេសយើង ដែលមានឈ្មោះជាប់មក ជាប្រទេសមានអក្សរសាស្ត្រ មានបុរាណវត្ថុ កេរ្តិ៍ដំណែល មានប្រជាជាតិជាម្ចាស់ប្រទេស មានមហាក្សត្រសោយ រាជ្យ ក៏ដោយអំណាចគុណនៃព្រះពុទ្ធសាសនា ឬថាព្រះពុទ្ធសាសនា ជាឃ្លាំងទុកដាក់នូវអក្សរសាស្ត្ររបស់ជាតិ ឲ្យមានជីវិតរស់នៅរហូតមក

រួមសេចក្ដីថា "ព្រះពុទ្ធសាសនានាំមកនូវប្រយោជន៍យ៉ាងធំឲ្យប្រទេសកម្ពុជារបស់យើង" ។

៨.– ប្រទេសកម្ពុជារបស់យើង ក៏យើងអាចបានឃើញជាក់ច្បាស់ហើយ គឺថាកាលដែលប្រទេសយើងមិនទាន់មានសាលារៀនអក្សរសាស្ត្រក្នុងផ្ទៃការនៅឡើយ មានតែវត្តអារាមប៉ុណ្ណឹងឯង ជាសាលារៀន កាលដែលមិនទាន់មានមន្ទីរពេទ្យព្យាបាលរោគ មានតែវត្តអារាមជាមន្ទីរពេទ្យសម្រាប់មើលជម្ងឺនៃប្រជាជន មិនត្រឹមតែមើលជម្ងឺក្នុងកាយប៉ុណ្ណោះទេ អាចពិនិត្យមើលជម្ងឺក្នុងចិត្តផងទៀត ព្រោះថា ការកើតទុក្ខព្រួយបារម្ភក្នុងផ្ទៃចិត្តនេះ ចាត់ជារោគមួយយ៉ាងធំណាស់ វត្តអារាមនៃពុទ្ធសាសនាឈ្មោះថាជាកន្លែងសម្រាប់រម្ងាប់រោគកាយ-ចិត្តដែលមានទុក្ខឲ្យធូរស្រាលក៏មាន ឲ្យជាសះស្បើយទៅក៏មាន ។

៩.– ប្រទេសកម្ពុជាដែលមានវត្តអារាមធំៗ ក្នុងរាជធានីភ្នំពេញមានវត្តឧណ្ណាលោម, វត្តលង្កា, វត្តបទុមវតីជាដើម ជាវត្តទទួលបន្ទុកនៃពួកភិក្ខុ, សាមណេរនិងក្មេងតូចធំបានច្រើនណាស់ ។ វត្តនីមួយៗ មានភិក្ខុសាមណេរ និងក្មេងដែលចេញសួះពន្ធះអំពីស្រុក-ខែត្រផ្សេងៗ មកនៅបញ្ចុះដីជាមួយគ្នា ដើម្បីសិក្សារៀនសូត្រយកចំណេះវិជ្ជា ព្រោះថាក្រុងភ្នំពេញជាទីប្រជុំធំសម្បូណ៌ដោយការសិក្សាជាងទីឯទៀត ។ ពួកភិក្ខុដែលមកគង់នៅក្នុងវត្តទាំងនោះបានយូរឆ្នាំ ទាំងមានសមត្ថភាពគ្រាន់បើហើយបានធ្វើជាមេកុដិ អាចទទួលបញ្ចាំភិក្ខុ, សាមណេរនិងក្មេងឲ្យនៅរៀនសូត្រទាល់តែសម្រេចការសិក្សា ។ ពួកក្មេងដែលមកនៅអាស្រ័យ

ជែកគោន គួរតែជាមួយទីពេះសង្ឃនោះ សុទ្ធតែជាកូនអ្នកស្រែចំការ ដែលក្រទ័លទ្រព្យសម្បត្តិ គួរឲ្យអាណោជអាធម្ម អាណិតអាសូរពួកក្មេង កំសត់ទាំងនេះពន់ពេក បើកុំតែមានវត្តព្រះពុទ្ធសាសនា ប្រហែលជាមិនបានទទួលរស្មីការសិក្សាដូចកូនអ្នកមានទ្រព្យទេ ប្រែសេចក្ដីឲ្យច្បាស់ថា "កូនអ្នកក្រីក្រធនធានរស់នៅដោយសារបាយវត្ត" ខំទ្រាំទ្រនៅបំពេញការសិក្សាទាំងរហេមរហាម ទាល់តែសម្រេចផលនៃការសិក្សាបានឡើងឋានៈទៅជាអ្នកមានជីវភាពខ្ពង់ខ្ពស់តាមសមគួរដល់សមត្ថភាពរបស់ខ្លួន, ចំណែកខាងកូនអស់លោកឥស្សរជន ឬ កូនគហបតី គេមិនបាច់ត្រូវការមកជែកគោននៅអាស្រ័យកុងវត្តឡើយ ។

កូនចៅរបស់អ្នកក្រីក្រ បានទទួលសេចក្ដីសង្គ្រោះអំពីបព្វជិតពុទ្ធសាសនិកក្នុងឆ្នាំមួយៗបានច្រើននាក់ណាស់ ដូចយ៉ាងវត្តធំៗ មានក្មេងចំនួន ៣០០ ឬ ៤០០ នាក់ ។ ចំនួនពួកក្មេងទាំងប៉ុណ្ណោះ បើជារដ្ឋាភិបាលទទួលយកទៅចិញ្ចឹមនោះ ខាតបង់ប្រាក់ថវិកាជាតិមិនមែនតិចទេ ។ ក្មេងទាំងនេះ ឈ្មោះថារស់នៅដោយអាស្រ័យទីជម្រកព្រះពុទ្ធសាសនា នៅជែកគោនក្រោមម្លប់ទង់ជ័យព្រះពុទ្ធសាសនា ខំប្រឹងប្រែងសិក្សាទាល់តែបានទទួលលទ្ធផលនៃការសិក្សារបស់ខ្លួនៗ ។ ករណីនេះឃើញថាព្រះពុទ្ធសាសនា នៅប្រទេសកម្ពុជាយើង មានប្រយោជន៍ដ៏ធំទូលាយអាចជួយសង្គ្រោះទំនុកបំរុងដល់ប្រទេសជាតិបាន គឺថាព្រះពុទ្ធសាសនាទុកដូចជាកន្លែងអាហារូបករណ៍មួយ ដ៏ប្រសើររបស់ពួកក្មេងអ្នកក្រីក្រ, អាចចិញ្ចឹមមនុស្សក្រទ័ល ដែលមិនមានលំនៅសម្រាប់ជែកគោនទីង

អាហារបរិភោគ ៗ វត្តពុទ្ធសាសនា ឈ្មោះថាបានជួយសម្រាលភារៈនៃរដ្ឋាភិបាល ឲ្យធូរស្រាលបានច្រើនណាស់ ៗ

៦.– បព្វជិតពុទ្ធសាសនិក នៅវត្តអារាមគ្រប់ស្រុក មានលោកចៅអធិការគ្រូសូត្រជាដើម ដែលភ្ជាក់ខ្លួនក្នុងការសិក្សាធម្មវិន័យហើយបានចុះស្លាមក្នុងផ្លូវសិក្សាតាមសម័យនិយម ៗ ការសិក្សាច្បាប់ព្រះពុទ្ធ-សាសនារបស់បព្វជិតពុទ្ធសាសនិកនោះ ជាកម្លាំងមួយដែលនាំឲ្យមានប្រាជ្ញាស្មារតីបរិបូណ៌ ក្នុងផ្លូវធម៌ផងផ្លូវលោកផង គឺថាការសិក្សានោះជួយឲ្យមានឧត្តមគតិមានសមត្ថភាពដល់ខ្លួន ដល់ពួកឧបាសកដើរវត្ត អាចដឹកនាំចិត្ត ឲ្យមានសទ្ធាជ្រះថ្លាក្នុងការកសាងសេនាសនៈសម្រាប់បម្រើព្រះពុទ្ធសាសនាផង បម្រើប្រទេសជាតិផង ៗ ដូចយ៉ាងសាលាសិក្សាអក្សរសាស្ត្រដែលកើតមានព្រោងព្រាតក្នុងស្រុក - ខេត្តផ្សេងៗ មានខេត្តកណ្ដាល - តាកែវ - ស្វាយរៀងជាដើម ច្រើនតែកើតអំពីចំហាយនៃការសិក្សាព្រះពុទ្ធសាសនាជាដើមអាទិ៍ គឺថាសាលាសិក្សាទាំងនោះកើតឡើងបានដោយសារស្នាដៃរបស់ព្រះសង្ឃមានចៅអធិការឬគ្រូសូត្រជាដើមដែលនាំពួកគ្រហស្ថដើរវត្តកសាងដោយឥតមើលបំណាំរដ្ឋាភិបាលឡើយ . លុះកសាងហើយជូនប្រគល់សាលាសិក្សានោះ ដល់រដ្ឋាភិបាលដើម្បីឲ្យរកការចាត់ចែងរកគ្រូបង្រៀនតាមផ្លូវការតទៅ ដែលអាចគាំពាររដ្ឋាភិបាលជួយកម្លាំងឲ្យរដ្ឋាភិបាលចំណេញថវិកាជាតិបានច្រើនណាស់ ៗ

ដំណើរនេះសឲ្យឃើញថា "ព្រះពុទ្ធសាសនាកាលបើបុគ្គលណាមួយបានអប់រំសិក្សាល្អហើយ អាចនាំឲ្យចុះបំភ្លឺ បើញសារប្រយោជន៍ក្នុង

ផ្លូវធម៌ក៏បាន ផ្លូវលោកក៏បាន" ។ ព្រះពុទ្ធសាសនាឈ្មោះថាជាសាសនាជួយប្រជាជនប្រទេសកម្ពុជា ឲ្យបេះស្រឡាញ់ប្រទេសជាតិរបស់ខ្លួនបានដោយបរិបូណ៌ ជាសាសនាមានទ្រឹស្ដីល្អអាចជួយសាងសាមគ្គីរបស់ជាតិឲ្យមានវឌ្ឍនធម៌ ។

៧- អក្សរសាស្ត្រខ្មែរសម្រាប់ប្រទេសយើង បើកុំតែមានវត្តអារាមនៃពុទ្ធសាសនិក ប្រហែលជាសាបសូន្យអស់ទៅហើយ ព្រោះហេតុនោះវត្តអារាមឈ្មោះថា ជាកន្លែងសម្រាប់ចិញ្ចឹមអក្សរសាស្ត្រ របស់ជាតិទុកឲ្យរស់នៅ ។ អក្សរសាស្ត្រនេះទុកជាពន្លឺរស្មីរបស់ជាតិ កាលបើបាត់អក្សរសាស្ត្រ ជាតិក៏អាចនឹងសាបសូន្យទៅជាលំដាប់ ដោយហេតុនេះពុទ្ធសាសនានៅប្រទេសយើងឈ្មោះថាជាសាសនាជួយជ្រោមជ្រែងរក្សាទុកនូវអក្សរសាស្ត្រជាតិ ។

បណ្ឌិតពុទ្ធសាសនិក ដែលបានរៀនក្នុងផ្លូវគន្ថធុរៈគឺរៀនគម្ពីរបាលីព្រះត្រៃបិដក បេះចាំយល់ស័ព្ទភាសាបាលីអាចប្រែពីបាលីមកជាភាសាខ្មែរបានដោយងាយ បានបោះពុម្ពផ្សាយចេញជាសៀវភៅធំតូចគរគោកសូមអញ្ជើញមើល ក្នុងពុទ្ធសាសនបណ្ឌិត្យ នឹងឃើញសៀវភៅខ្មែរជេរជាស ។ សៀវភៅខ្មែរផ្សាយផ្នែកពុទ្ធសាសនាចេញព្រោងព្រាតទាំងនេះ ប្រែនតែកើតអំពីស្នាដៃព្រះសង្ឃ ដែលបានរៀនក្នុងផ្លូវព្រះពុទ្ធសាសនា ។ ប្រទេសកម្ពុជាដែលមានវឌ្ឍនធម៌ចំរើនរុងរឿងរើបៗមកនេះ ដោយកម្លាំងរស្មីព្រះពុទ្ធសាសនាជាប្រាកដ ។

---

# បញ្ញាសជាតក

## ភាគទី ៤

បណ្ឌិតមហា ឈឹម - ស៊ុម សាស្ត្រាចារ្យ

នៅសាលាបាលីជាន់ខ្ពស់ ជាត់ឲ្យប្រែហើយពិនិត្យផ្ទៀងផ្ទាត់ដោយខ្លួនឯង

កាលដែលនៅជាភេទបព្វជិតពី ព.ស. ២៤៨៦, គ.ស. ១៩៤៣

(តមក)

---

## វីរិយបណ្ឌិតជាតក ទី ១៧

លោកអាចារ្យ ឈឹម - ស៊ុម វត្តលង្កាប្រែពីបាលី

---

ឯកទា កិរ សមយេ បញ្ចាលរាជា ឯករត្តកម្ពលំ មហោរដ្ឋស្ស រញ្ញោ បេសេសិ ។

*កិរ បានឮតរៀងៗមកថា សម័យមួយ ព្រះរាជាក្នុងដែនបញ្ចាល ទ្រង់បញ្ជូនសំពត់កម្ពលក្រហម ១ ទៅថ្វាយព្រះរាជាព្រះចៅដែនមហារដ្ឋ ។ ព្រះបាទមហារដ្ឋរាជ ទ្រង់ទស្សនាការឃើញសំពត់រត្តកម្ពលនោះហើយ ទ្រង់ត្រាស់ព្រះរាជឱង្ការថា ព្រះបាទបញ្ចាលរាជសម្លាញ់អញ បានបញ្ជូនសំពត់រត្តកម្ពលមានថ្លៃច្រើនមកឲ្យអញ; បើដូច្នេះមានតែអញបញ្ជូនរតនវត្ថុមានថ្លៃច្រើនទៅសងគេវិញ, តើអញនឹងបញ្ជូនរតនវត្ថុអ្វីអេះ ដែលមានថ្លៃច្រើនបំផុត? ទើបព្រះបរមក្សត្រទ្រង់ព្រះយោបល់យល់ឃើញថា រតនវត្ថុដទៃដែលនឹងមានដំឡៃស្មើនឹងពុទ្ធរតនៈគ្មានទេ, បើដូច្នេះ មានតែគាត្មាអញបញ្ជូនពុទ្ធរតនៈទៅឲ្យគេចុះ ។ លំដាប់នោះ*

ព្រះបាទមហាវជ្ជរាជ ទ្រង់ចាត់ឲ្យជាងដែដម្បារមាស ហើយឲ្យគូរភេសជា ព្រះពុទ្ធបដិមា ដ៏ល្អថ្លៃថ្លាគួរជាទីមនោរម្យមានទំហំ ១ ហត្ថ ផាត់ដោយ ថ្នាំជាតិហិង្គុល មានពណ៌ល្អស្រស់; កាលបើការកសាងព្រះបដិមា ហើយសព្វគ្រប់ជាស្រេច ស្ដេចទ្រង់បូជាដោយគ្រឿងសក្ការៈ មាន ប្រការផ្សេងៗ ទ្រង់ចាត់ចែងនាវា ដ៏កល់ព្រះពុទ្ធបដិមា ហើយព្រះរាជា ទ្រង់ចាត់រាជទូតឲ្យនាំទៅថ្វាយព្រះបាទបញ្ចាល ។ កាលពួករាជទូត រៀបចំនឹងបើកនាវាចេញទៅ ព្រះរាជាទ្រង់ក្រាបថ្វាយបង្គំព្រះពុទ្ធបដិមា ត្រាស់ព្រះរាជឱង្ការថា បពិត្រព្រះអង្គជាលោកនាយក, បពិត្រព្រះ អង្គជាលោកសរណៈ, តាមសេចក្ដីពិត កាលព្រះសាស្ដាទ្រង់គង់ព្រះ ជន្មនៅឡើយ ទ្រង់លះបង់នូវសេចក្ដីសុខល្អិតក្នុងភាពជាព្រះពុទ្ធ នឹងភាព ជាក្សត្រទ្រង់ស្វែងកាត់សំដៅទៅកាន់ទី ដែលមានវេនេយ្យជនប្រជុំគ្នា ព្រះអង្គទ្រង់ធ្វើវេនេយ្យជនទាំងនោះ ឲ្យបានសម្រេចប្រយោជន៍គ្រប់ ប្រការ, សេចក្ដីករុណារបស់ព្រះអង្គពីមុនយ៉ាងណា, ក៏ក្នុងថ្ងៃនេះ សូមឲ្យមានយ៉ាងនោះទៀត បពិត្រព្រះអង្គដ៏ចំរើន ព្រះបាទបញ្ចាល រាជសម្លាញ់ខ្ញុំព្រះអង្គ ជាមនុស្សមិច្ឆាទិដ្ឋិ សូមព្រះអង្គទ្រង់ដោះស្ដេច នោះ ឲ្យរួចអំពីមិច្ឆាទិដ្ឋិ បើព្រះអង្គនិមន្តទៅដល់នគរបញ្ចាល ហើយ, សូមព្រះអង្គធ្វើពុទ្ធបាដិហារ្យបង្កើតសេចក្ដីជ្រះថ្លា ដល់ព្រះបាទបញ្ចាល នោះឲ្យទាន់ ។ ព្រះបាទមហាវជ្ជរាជ ទ្រង់បួងសួងយ៉ាងនេះស្រេចហើយ ទ្រង់ចុះជូនដំណើរព្រះពុទ្ធបដិមា ត្រាតែដល់ទឹកត្រឹមព្រះសូរង ។ ខណៈ នោះ មហាសមុទ្រក៏ពេញដោយឧទកជាកគួរនាដូចជាមាស មាន

កញ្ឆាញ់លេកបោកបញ្ចេញឱភាស ភ្លឺពន្លឺមលលែមផ្ទេក ៗ, សព្វរតនាករ ដ៏ល្អរុងរឿងមានប្រការផ្សេង ៗ ច្រើនជាអនេក ក៏ផុះអណ្ដែតឡើងពីបាតសមុទ្រ បេញផុតមកប្រតិស្ឋាននៅលើទឹក ដើម្បីជាពុទ្ធបូជា ផ្ទៃសមុទ្រដលធារ ដែលវិចិត្រដោយកែវ ៧ ប្រការ ក៏ពបសាស្មើល្អដូចជាផ្ទៃសុវណ្ណភាជនៈ មានបទុមជាតិបញ្ចពណ៌ ដុះផុះលេចឡើងដោយល្អជាដួរជាចន្លោះ, ពួកនាគពជទាំងអស់ក៏ចេញអំពីនាគពិភព ជាមួយនឹងពួកនាគជាបរិវារ បូជាដោយគន្ធមាលា ច្រៀងសរសើរដោយសំឡេងដ៏ពីរោះអស្ចារ្យ ហក់ហែលហោមរោមជាបរិវារនៅនាកណ្ដាលសមុទ្រ, ទេព្ដាទាំងឡាយក៏រោយរាយទិព្វបុប្ផា ចុះមកអំពីអាកាស ខ្លះប្រគំដោយទិព្វតូរ្យតន្ត្រី ខ្លះបើកឆត្រលើកទង់ប៉ាំងសំពត់សុទ្ធសឹងវិចិត្រដោយមាស ហោមរោមពេញទាំងអាកាស គួរជាទីអស្ចារ្យ ។

ធម្មតាពុទ្ធានុភាព ជាសភាពដែលអ្នកផងគិតពុំបាន ប្រមាណមិនកើត; អម្បាលកាលដែលព្រះអង្គទ្រង់ចូលបរមនិព្វានទៅ នៅមានតែព្រះពុទ្ធបដិមា ម្ដេចទ្រង់មានអានុភាពអស្ចារ្យដល់ម្ល៉េះ, បើដូច្នោះចាំបាច់និយាយថ្វីដល់អង្គព្រះជិនស្រីកាលទ្រង់គង់ព្រះជន្មនៅ ! ។

រាជទូតទាំងឡាយ បានដល់នគរបញ្ចាល ក៏ចូលទៅក្រាបបង្គំគាល់ព្រះរាជា ដំណាលអំពីសេចក្ដីអស្ចារ្យ សព្វគ្រប់ប្រការ ។ រាជា តំ អច្ឆរិយំ សុត្វា ព្រះរាជាបានទ្រង់ព្រះសវនាការ នូវសេចក្ដីអស្ចារ្យដូច្នោះ ក៏ទ្រង់មានព្រះបីតិសោមនស្ស ស្រស់ស្រាយរីករាយក្នុងព្រះរាជហឫទ័យ ទើបព្រះចក្រីទ្រង់ព្រះចិន្ដានាការគិតថា សម្ងាញ់អញ ឲ្យជាងគូរព្រះពុទ្ធ

បដិមាធ្វើមហាសក្ការៈហើយ បញ្ជូនមកឲ្យអញ; ចំណែកខាងអាត្មាអញ ត្រូវតែធ្វើសក្ការៈឲ្យច្រើនជាងនេះជាទ្វេគុណ ហើយសឹមនាំព្រះពុទ្ធបដិមា អំពីនាវាមក ។ គ្រានោះព្រះរាជាទ្រង់តាក់តែងគ្រឿងសក្ការបូជា ច្រើន ជាអនេកប្រការ ក្សត្រាទ្រង់ចេញអំពីព្រះរាជមន្ទីរ មានចតុរង្គអង្គពល សេនីយ ភ្លេងប្រគុំតូរ្យតន្ត្រី នឹងបណ្ដាជននាម៉ឺនសព្វមុខមន្ត្រីហែហមរោម ជាបរិវារ, បណ្ដាជនទាំងអស់គ្នា សុទ្ធតែបញ្ចេញស័ព្ទពាក្យថាជ័យ មង្គល ដរាបតែដល់មាត់កំពង់ ទ្រង់ថ្វាយបង្គំព្រះពុទ្ធបដិមាដោយបញ្ចាង្គ-ប្រតិស្ឋានទ្រង់បានបូជាដោយទៀនធូបគន្ធមាលា ដោយព្រះរាជាទ្រង់ចុះ ទៅក្នុងទឹកប្រមាណត្រឹមព្រះសូរង, ទ្រង់ឃើញព្រះពុទ្ធបដិមា ក្សត្រា ទ្រង់មានព្រះរាជហឫទ័យរីករាយណាស់ ទើបត្រាស់ព្រះរាជឧទ្គារថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំសូមយកព្រះអង្គជាទីពឹងដរាបដល់អស់ជីវិត, ថ្ងៃ នេះខ្ញុំបានព្រះអង្គជាទីពឹងស្មើជីវិតហើយ, សូមព្រះដ៏មានព្រះភាគទទួល ជ្រាប ថាខ្ញុំព្រះករុណាជាឧបាសក ។

ដោយអំណាចព្រះរាជសទ្ធាព្រះបាទបញ្ចាល នឹងសេចក្ដីអធិដ្ឋាន ព្រះបាទមហារដ្ឋ ក៏ព្រះពុទ្ធបដិមានោះសំដែងបាដិហារ្យអណ្ដែតឡើងផុត ព្រះភ្នែនតែនព្រះបាទឡដ៏អាកាស; ឆព្វណ្ណរង្សីរស្មីទាំង ៦ ពណ៌ គឺខៀវ លឿង ក្រហម ស ហង្សបាទ នឹងពណ៌ចំរុះផ្សេងៗ ផ្សាយចេញភ្លៀល ភ្លាត់ប្រាក់អំពីព្រះពុទ្ធបដិមានោះ ។ រស្មីខៀវ ចេញមកត្រង់កន្លែង ដែលសមដោយពណ៌ខៀវ ឃើញសុទ្ធតែពណ៌ខៀវដូចគេប្រក់ដោយផ្កា ត្រកៀត នឹងផ្កានិលុប្បល ។ រស្មីលឿង ចេញមកត្រង់កន្លែងដែល

សមដោយពណ៌លឿង; ទិសាភាគទាំងមូលប៉ែកខាងស្មើលឿង ក៏មានពណ៌លឿងដូចគេស្រោបដោយទឹកមាស ឬ ដូចគេពាសដោយដម្បារសុវណ្ណ ។ រស្មីក្រហមចេញមកត្រង់កន្ទួនដែលសមដោយពណ៌ក្រហម; ទិសាភាគទាំងមូលប៉ែកខាងរស្មីក្រហម ក៏ដូចជាគេស្រោបដោយត្របកផ្កាចាប ។ រស្មីសចេញមកត្រង់កន្ទួនដែលសមដោយពណ៌ស; ទិសាភាគទាំងមូលប៉ែកខាងរស្មីស ក៏មានពណ៌សដូចគេពាសដោយដម្បារប្រាក់ ។ រស្មីហង្សបាទ ចេញមកត្រង់កន្ទួនដែលសមដោយពណ៌ហង្សបាទ; ទិសាភាគទាំងមូលប៉ែកខាងរស្មីហង្សបាទ ក៏ប្រាកដដូចជាផ្កាននោងព្រៃ ។ រស្មីចំរុះផ្ទេក ៗ ចេញមកត្រង់កន្ទួនដែលសមដោយពណ៌ចំរុះផ្ទេក ៗ; ទិសាភាគទាំងមូលប៉ែកខាងរស្មីចំរុះផ្ទេក ៗ ក៏ប្រាកដស្មើដោយផ្ទេកបន្ទោរ ៗ ឆព្វណ្ណរង្សីនោះ ក៏ផ្សាយផ្សព្វតាប់ជាប់ដល់មហាផែនដី ។ មហាប្រថពីមានកម្រាស់ ២ សែន ៤ ម៉ឺនយោជន៍ ក៏មានពន្លឺដូចជាដម្បារមាស; ទឹកក្នុងទីបមុទ្ទព្រែកស្ទឹងបឹងស្រះទាំងអស់មានពណ៌ដូចសន្ទឹកមាស ។ រស្មីនុភាសផ្សាយទៅខាងលើ រហូតដល់ឆកាមាវចរទេវលោក ទីងព្រហ្មលោក, ផ្សាយទៅជុំវិញ រហូតផុតអនន្តលោកធាតុ ។ ក្នុងទីជម្ពូទប៉ុណ្ណះគ់តមានពន្លឺព្រះចន្ទ ពន្លឺព្រះអាទិត្យ ឬ ពន្លឺទេវតា ផ្សាយឡើងបានសោះ មានត្រឹមតែឆព្វណ្ណរង្សីនៃព្រះបដិមាករនោះទាំងអស់ ផ្សព្វផ្សាយទៅគតសល់ចន្លោះទីជម្ពូទណាឡើយ; ទុកជាមហាព្រហ្ម ដែលអាចផ្សាយពន្លឺឲ្យភ្លឺពេញ ១ ម៉ឺនលោក-ធាតុបានក៏ត្រឡប់ជាឥតមានតេជះ ដូចជាអំពឹលអំពែកក្នុងវេលាដែល

ព្រះអាទិត្យរះឡើង ដូច្នោះ ។ គ្រានោះ សម្តេចសក្កទេវរាជ ព្រម ទាំងពពួកទេវបុត្តទេវធីតា បូជាដោយគ្រឿងគន្ធមាលា នាំគ្នាផ្គងអញ្ជលី ឋិតនៅឰដ៏អាកាស ។ ពួកមនុស្សម្នាមហាជន ចេញមកអំពីទិសទីគ្រប់ ជម្រៀន មូលមកគ្រៀបគ្រា, មនុស្សទាំងទេវតាបានឃើញគ្នាទៅវិញទៅ មកដោយជាក់ច្បាស់ ។

ព្រះរាជាទ្រង់ទស្សនាការ ឃើញបាដិហារ្យនោះ ក៏មានព្រះ រាជហឫទ័យរីករាយក្រៃពេក ទើបនិមន្តព្រះពុទ្ធបដិមាថា បពិត្រព្រះ អង្គដ៏ចំរើន, សូមព្រះអង្គនិមន្តមកគង់លើសុវណ្ណសិវិកានាទីនេះ ។ ខណៈនោះ ព្រះពុទ្ធបដិមាក៏ទ្រង់ចុះពីអាកាស មកគង់លើព្រះ សុវណ្ណសិវិកា ។ ព្រះរាជា ព្រមទាំងពពួកពលសេនា ក៏នាំព្រះ ពុទ្ធបដិមា ដោយសុវណ្ណសិវិកា ទៅដំកល់ក្នុងព្រះរាជមន្ទីរ ហើយបូជា ដោយទៀនធូបគន្ធមាលា; ព្រះរាជាទ្រង់រំពឹងពិចារណាចំពោះព្រះ ពុទ្ធគុណទ្រង់ពោលជាបទព្រះគាថា ថា

យោហំ ពុទ្ធញ្ច ធម្មញ្ច សង្ឃញ្ច សរណំ គតោ
ឧបាសកត្តំ ទេសេមិ សក្យពុទ្ធស្ស សាសនេ
មម ចិត្តំ បសាទេត្វា មោចេសិ ភវទុក្ខតោតិ ។

"ខ្ញុំព្រះករុណា សូមយកព្រះពុទ្ធព្រះធម៌ព្រះសង្ឃជាទីពឹង, សូម ប្រកាសខ្លួនជាឧបាសកក្នុងសាសនានៃព្រះសក្យពុទ្ធ, សូមព្រះអង្គញុំាង

ចិត្តខ្ញុំព្រះករុណាឲ្យជ្រះថ្លា ហើយដោះខ្ញុំព្រះករុណាឲ្យរួចអំពីសេចក្តីទុក្ខ ក្នុងគភ៌" ។

ព្រះរាជាមានព្រះសរីរៈពេញដោយបីតិប្រាំពណ៌ មានព្រះរាជអំណរក្រៃពេក ទើបទ្រង់ព្រះចិន្តានាគិតថា "សម្រាញ់អញបានឲ្យជាងសានព្រះពុទ្ធបដិមា មានសភាពយ៉ាងនេះ បើដូច្នេះគួរតែអាត្មាអញ សានព្រះពុទ្ធបដិមា យ៉ាងល្អថ្លៃថ្លាជាងនេះជាទ្វេគុណ, ទើបព្រះអង្គពាត់ឲ្យយកខ្លឹមចន្ទន៍ ឲ្យហៅជាងចម្លាក់មក ទ្រង់ត្រាស់ព្រះរាជបញ្ជាថា អ្នកឯងចូរយកខ្លឹមចន្ទន៍មានដំឡៃច្រើននេះ ទៅសានព្រះពុទ្ធបដិមា ។ ជាងចម្លាក់ក៏ទទួលព្រះរាជឱង្ការ យកខ្លឹមចន្ទន៍នោះទៅសានព្រះពុទ្ធបដិមា រួចស្រេចហើយចូលទៅក្រាបបង្គំទូលព្រះរាជាថា បពិត្រព្រះរាជសម្ភារ, ព្រះពុទ្ធបដិមា ទូលព្រះបង្គំជាខ្ញុំបានសានស្រេចហើយ ។ ព្រះរាជាទ្រង់ឲ្យយកព្រះពុទ្ធបដិមានោះមកដំកល់ទុកលើសាលាពាត់ឲ្យថែរក្សា មិនឲ្យប្រហែសធ្វេស ។ លំដាប់នោះ ព្រះរាជាឲ្យឃោសនាថា មនុស្សអ្នកនគរទាំងអស់ នរណាមានមាស សូម្បីតែបន្តិចបន្តួច ក៏ចូរយកមកចបព្រះពុទ្ធបដិមា ជាមួយនឹងព្រះរាជាតាមសទ្ធាចុះ ។

គ្រានោះ ព្រះពោធិសត្វឈ្មោះ វិរិយបណ្ឌិត ជាអ្នកកំសត់ទុគ៌តទ័លក្រនៅក្នុងនគរនោះដែរ ។ ភរិយាពោធិសត្វនោះ ឈ្មោះនាងសុជាតា, មានកូនប្រុសម្នាក់ឈ្មោះ វេវត្តកុមារ ។ ចំណែកខាងព្រះពោធិសត្វ បានឮសំឡេងឃោសនា ក៏គិតថា "អាត្មាអញ គួរតែធ្វើកុសលជាមួយនឹងព្រះរាជាក្នុងគ្រានេះ, ប៉ុន្តែបើអាត្មាអញទ័លក្រដល់ម៉្លេះ

ធ្វើម្ដេចនឹងបានមាស ! ល្ហើយចុះអាត្មាអញលក់ខ្លួន យកមាសមកទឹប ព្រះពុទ្ធបដិមាជាមួយនឹងព្រះរាជាចុះ"; លុះគិតស្រេចដូច្នោះក៏ទៅផ្ទះ និយាយនឹងកូនប្រពន្ធថា ម្នាលនាងសុជាតា, ហៃបារេវត្ត, ខ្ញុំលាអ្នកទាំងឡាយហើយ ។ នាងសុជាតាសួរថា បពិត្រស្វាមី, អ្នកអញ្ជើញទៅណា? ពោធិសត្វប្រាប់ថា ខ្ញុំត្រូវសំឡេងឃោសនា ក៏បង់ធ្វើកុសលជាមួយនឹងព្រះរាជា, ព្រោះហេតុនោះបានជាខ្ញុំបង់លក់ខ្លួន យកថ្លៃមកធ្វើកុសល ។ ភរិយាឮដូច្នោះហើយ ក៏ញាប់ញ័រអស់ដួងហឫទ័យ ដោយហេតុតែខ្លួនជាស្រីមានចិត្តទន់ ក៏មានទឹកភ្នែកហូរហៀម ពុំបណ្ដោយតាម ត្រឡប់បែរជានិយាយថា បពិត្រស្វាមី, អ្នកមានប្រសាសន៍ម្ដេចដូច្នោះ, ខ្លួនខ្ញុំ ជាខ្ញុំស្រីរបស់អ្នក, រេវត្ត ជាខ្ញុំប្រុសរបស់អ្នកស្រាប់, សូមអ្នកយកយើងទាំងពីរនាក់នេះទៅលក់ឲ្យអ្នកមានទ្រព្យណាមួយ, យកសំពត់ក៏ដោយ យកប្រាក់ក៏ដោយ យកមាសក៏ដោយ តាមតែអ្នកប្រាថ្នា, យកមកបាត់ការធ្វើបុណ្យតាមសេចក្ដីសប្បាយចុះ ។ ពោធិសត្វ ក៏និយាយដដែលៗពីរដងបីដង ក៏នៅតែជំនះមិនឈ្នះភរិយានោះសោះ, ទើបយល់ព្រមថា "សាធុ សាធុ ល្អហើយនាង, នាងឯង ក៏ប្រហែលជាកល្យាណមិត្ត ធ្លាប់បំពេញទានបារមី ជាមួយគ្នា ១ ពាន់ជាតិ ១ សែនជាតិមកហើយ"; ទើបពោធិសត្វនាំយកកូនប្រពន្ធទៅលក់ឲ្យអ្នកមានទ្រព្យ យកថ្លៃជាមាស មកប្រគល់ឲ្យជាងមាសថា ចូរអ្នកផែមាសនេះហើយ ឲ្យបានដម្បារសទ្ធិកស្មើន ៗ ឲ្យខ្ញុំ ។ កាលជាងមាសផែមាសស្រេច ពោធិសត្វបង់ទៅទឹបព្រះពុទ្ធបដិមា ក៏យកដម្បារមាសទៅឯសាលា.

និយាយនឹងមនុស្សអ្នករក្សាសាលាថា បពិត្រអ្នកទាំងឡាយដ៏ចំរើន, ខ្ញុំមកនេះដោយបំណងចង់ទឹបមាសព្រះពុទ្ធបដិមា ៗ អ្នករក្សាប្រាប់ថា ព្រះរាជាបំរុងនឹងទឹបព្រះពុទ្ធបដិមាក្នុងថ្ងៃឯណោះ, ឥឡូវនេះ អ្នកឯងទឹបមុនព្រះរាជាដូចម្ដេចបាន ៗ ពោធិសត្វឮសំដីនោះហើយ ក៏តក់ស្លុតរន្ធត់ក្នុងហឫទ័យ ទើបលាន់មាត់បញ្ចេញសំដីថា ឱ! បំណងរបស់អញខុសទទេទៅហើយតើ, ដំណើរនេះក៏ព្រោះតែអាត្មាអញជាមនុស្សកំសត់, មុខគួរឲ្យអាស្សូរចិត្តណាស់, ស្ទើរលះកូនប្រពន្ធឲ្យទៅនៅនឹងគេ! ឥឡូវនេះបែរជាឥតអំពើសោះ ៗ គ្រានោះ ពោធិសត្វពោះបីបានឮសំដីអ្នករក្សាសាលាឃាត់ដូច្នោះ ដោយហេតុតែមានសទ្ធាខ្លាំង ក៏ធ្វើហាក់ដូចជាមិនឮសោះ ខំប្រឹងចូលទៅកាន់សាលា ៗ អ្នករក្សាសាលានិយាយឃាត់ចាប់ទាញឲ្យចេញមកវិញ ៗ មនុស្សទាំងឡាយដទៃទៀត ខំជួយធ្វៀតរកឧបាយ និយាយប្រាប់តាមទំនងថា នែអ្នកវិរិយបណ្ឌិត, បើអ្នកចង់ទឹបមាសព្រះពុទ្ធបដិមាហ្នឹងណាស់, ចូរអ្នកឯងទៅក្រាបបង្គំទូលសូមអនុញ្ញាតព្រះរាជាសិន ៗ ពោធិសត្វក៏ទទួលពាក្យនោះថា " ពាក្យដែលអ្នកទាំងឡាយនិយាយនេះ ពេញជាត្រូវល្អណាស់," ហើយកាន់ដប្បរមាស ចូរទៅក្រាបបង្គំទូលព្រះរាជាថា បពិត្រព្រះសម្មតិទេព, ទូលព្រះបង្គំជាខ្ញុំចង់ទឹបមាសព្រះពុទ្ធបដិមា, សូមព្រះអង្គទ្រង់ព្រះរាជាអនុញ្ញាត ៗ ព្រះរាជា ទ្រង់មានព្រះរាជបំណងបម្រុងនឹងបញ្ចោតពោធិសត្វនោះ ក៏ទ្រង់ត្រាស់ព្រះរាជឧង្ការថា បើព្រះពុទ្ធបដិមា មានព្រះពុទ្ធដីកាចរចាជាមួយនឹងអ្នកឯង សឹម

អ្នកឯងនឹងទឹបមាសព្រះអង្គចុះ; បើព្រះអង្គមិនមានព្រះពុទ្ធដីកាទេ, អ្នកឯងកុំទឹបមាសព្រះអង្គឡើយ ។ ពោធិសត្វព្រះរាជឱង្ការនោះហើយ ក៏រីករាយសប្បាយក្នុងចិត្តថ្វាយបង្គំលាចេញមក យកមាសមកទូលលើក្បាលដើរទៅកាន់សាលា; អ្នករក្សាសាលាដឹងថា ព្រះរាជាទ្រង់ព្រះរាជទានឱកាស ក៏បណ្ដោយឲ្យចូលឥតមានហាមឃាត់ ។ ពោធិសត្វយកមាសទៅដំកល់ជិតព្រះពុទ្ធបដិមា លុតជង្គង់លើកហត្ថា ថ្វាយបង្គំប្រណម្យក្រាបទាបព្រះបាទា ពោលពណ៌នាសរសើរព្រះពុទ្ធបដិមាថា បពិត្រព្រះអង្គដ៏ចំរើន, ពីមុននេះ ខ្ញុំព្រះអង្គបានឮថា កាលដែលព្រះអង្គទ្រង់ត្រាច់រង្គាត់ក្នុងភពវដ្ដសង្សារ គឺកាលដែលព្រះអង្គនៅជាពោធិសត្វនៅឡើយ ព្រះអង្គតែងទ្រង់អនុគ្រោះដល់សត្វទាំងឡាយ, របស់អ្វីដែលមាន ព្រះអង្គតែងប្រទានឥតមានស្ដាយ, និយាយត្រឹមតែព្រះសិរ ដែលព្រះអង្គធ្លាប់កាត់ឲ្យទៅជាទាន បើប្រមូលមកគរជាគំនរ ប្រាកដជាធំជាងភ្នំព្រះសុមេរុ; ព្រះនេត្រច្រើនជាងផ្កាយ, ព្រះមំសៈច្រើនជាងផែនដី, ព្រះលោហិតច្រើនជាងទឹកសមុទ្រ, បើសត្វឯណាសុំសាច់បេះដូងដួងហឫទ័យ ឬសិរៈពាក់កណ្ដាលក្ដី សិរៈទាំងមូលក្ដី ព្រះអង្គតែងទ្រង់ប្រទានឥតមានសេសសល់ ដើម្បីឲ្យបានត្រាស់ជាព្រះពុទ្ធផង ដើម្បីសេចក្ដីសុខដល់សត្វទាំងឡាយផង: បពិត្រព្រះអង្គដ៏ចំរើន, បើពាក្យដែលខ្ញុំព្រះអង្គបានឮមកដូច្នេះជាពាក្យពិតប្រាកដមែន, សូមព្រះអង្គទ្រង់អនុគ្រោះបើកព្រះឱស្ឋ មានព្រះពុទ្ធដីកាជាមួយនឹងខ្ញុំព្រះករុណាកុំ

ខាន; បើព្រះអង្គពុំមានព្រះពុទ្ធដីកាជាមួយផងទេ, ខ្ញុំព្រះករុណានឹងស្លាប់ទៀបព្រះបាទាជាប្រាកដ ។

ខណៈនោះ ទេវតារក្សាផែនដី បានឮសំដីពោធិសត្វហើយ ក៏អត់ទ្រាំពុំបាន, ផ្ទែកចូលក្នុងព្រះពុទ្ធបដិមា ធ្វើអង្គព្រះពុទ្ធបដិមាឲ្យកំរើកឡើង ដូចជាកាលដែលគង់ព្រះជន្មនៅដូច្នោះ ។ ឆព្វណ្ណរង្សី (រស្មីទាំង៦ពណ៌) ក៏ផ្សាយចេញមក ភ្លៀលភ្លាត់ប្រាក់សព្វទិស ។ ទើបព្រះអង្គទ្រង់បើកព្រះឱស្ឋ មានព្រះពុទ្ធដីកាថា ល្អហើយវិរិយបណ្ឌិត, ចូរអ្នកឯងធ្វើតថាគត តាមសេចក្ដីពេញចិត្តចុះ ។ ព្រះសូរសៀងព្រះពុទ្ធរូបនោះ ក៏ឮផ្សាយទៅពេញនគរបញ្ចាលទាំងមូល ។ គ្រានោះពោធិសត្វយកមាសមកលៃស្មានមើល ឃើញថាមិនគ្រាន់ ទើបគិតទៅទៀតថា មាសនេះជាដំឡៃនៃកូននឹងប្រពន្ធ; ឥឡូវនេះបើខឹបមិនគ្រាន់, តើអាត្មាអញធ្វើដូចម្ដេចនឹងបានមាសពីណាមកបំពេញទៀត; ឱ! បើតែយ៉ាងនេះសមជាបំណងអាត្មាអញមិនសម្រេច; ឱ! លោកណាអើយមានអានុភាពខ្លាំងពូកែ អាចផែសាច់ខ្ញុំឲ្យទៅជាមាសកើត; ខ្ញុំនឹងប្រគល់ខ្លួនឲ្យពន្លះសាច់យកទៅផែតាមការ ។ គ្រាដែលព្រះពោធិសត្វកំពុងគិតដូច្នេះ ក៏មហាប្រឹថពីមានកម្រាស់ ២ សែន ៤ ម៉ឺនយោជន៍ករគ្រឹករំពើកឡើង បញ្ចេញបំពាយកំសួល ក្ដៅរំដួលដល់បណ្ឌុកម្ពលសិលា ទែនទិព្វអាសនៃសម្ដេចសក្កទេវរាជ ។ ព្រះឥន្ទ្រទ្រង់អាវជ្ជនាការពិចារណាជាបហេតុនោះហើយ ទ្រង់ហោះផ្ទោះចុះចាកទេវលោកមកមួយរំពេច និម្មិតព្រះអង្គជាជាងមាស ចូលទៅឈរទល់មុខគ្នានឹង

ពោធិសត្វ ។ ពោធិសត្វសួរថា អ្នកឯងជាអ្វី? ព្រះឥន្ទ្រឆ្លើយថា ខ្ញុំជាជាងមាស ។ ពោធិសត្វសួរថា អ្នកជាងឯងអាចផែសាច់មនុស្សឲ្យកើតជាមាសបានឬទេ? ព្រះឥន្ទ្រឆ្លើយថា ខ្ញុំអាចធ្វើបាន ។ ពោធិសត្វមានចិត្តរីករាយសោមនស្សនិយាយថា បើពិតដូច្នោះមែន, ខ្ញុំនឹងពន្លះសាច់ខ្ញុំ ឲ្យអ្នកជាងឯងផែក្នុងថ្ងៃនេះ ។ ព្រះឥន្ទ្រឆ្លើយថា សាធុ ល្អហើយ, ខ្ញុំនឹងធ្វើតាមពាក្យអ្នកឲ្យខាងតែបានសម្រេច ។ ពោធិសត្វគិតនឹងពន្លះសាច់ ក៏ជួនជារកកាំបិតពុំបាន, ទើបពោធិសត្វងើបមើលទៅខាងលើអាកាស ឃោសនាចំពោះទេវតាទាំងឡាយថា

ភោន្តោ ភោន្តោ ទេវសង្ឃា សុណន្តុ វចនំ មម
សព្ពេ អនាគតេ កាលេ ពុទ្ធោ ហេស្សាមិ នាយកោ
តមិនា មំសទានេន មម ចិត្តពលេន ច
មយ្ហំ បុញ្ញតេជេន សត្ថំ បតតុ សម្មុខាតិ ។

"បពិត្រពពួកទេវតាទាំងឡាយដ៏ចំរើន, សូមទេវតាទាំងឡាយស្ដាប់ពាក្យខ្ញុំ, បើខ្ញុំនឹងបានត្រាស់ជាព្រះពុទ្ធ ក្នុងកាលជាអនាគតមែន, សូមឲ្យគ្រឿងសស្ត្រាវុធធ្លាក់ចុះក្នុងទីចំពោះមុខ ដោយតេជះមំសទាននេះផង ដោយកម្លាំងចិត្តរបស់ខ្ញុំផង ដោយតេជះបុណ្យរបស់ខ្ញុំផងកុំខាន" ។

លំដាប់នោះ គ្រឿងសស្ត្រាក៏ធ្លាក់ពីលើអាកាស មកប្រតិស្ឋានក្នុងទីចំពោះមុខពោធិសត្វ ។ ពោធិសត្វ ចាប់យកគ្រឿងសស្ត្រា បម្រុងនឹងអារសាច់ ក៏អធិដ្ឋានម្ដងទៀតថា "ខ្ញុំសូមឲ្យមាសព្រះពុទ្ធបដិមា

ដកបដល់ពេញសព្វគ្រប់, បើមិនទាន់ពេញនៅឡើយទេ, សូមឲ្យខ្ញុំកុំអាលស្លាប់"; លុះអធិដ្ឋានដូច្នោះហើយ ក៏អារសាច់ហុចទៅឲ្យជាងមាស; ជាងមាសទទួលយកសាច់នោះទៅធ្វើកើតជាដម្បារមាស ល្មមបិទពាសព្រះពុទ្ធរូបបានហើយប្រគល់មកឲ្យពោធិសត្វវិញភ្លាម ៗ ពោធិសត្វឃើញដុំសាច់របស់ខ្លួន ដែលជាងមាសធ្វើកើតជាដម្បារមាសដូច្នោះ ក៏មានចិត្តរីករាយសោមនស្សជាកិយ្យោភាព ទើបគិតថា "បំណងរបស់អាត្មាអញសម្រេចហើយ"; ហើយយកមាសនោះទៅទឹបព្រះពុទ្ធបដិមា; កាលបើការទឹបនោះរួចស្រេចហើយ ក៏ក្រាបចុះទៀបព្រះបាទានៃព្រះពុទ្ធបដិមា សន្ធប់ភ្លាត់សញ្ញានៅក្នុងទីនោះ ៗ ទើបសម្ដេចព្រះសក្កទេវរាជ យកថ្នាំឱសថទិព្វ មកលាបសព្វសរីរាងកាយនៃពោធិសត្វ ហើយស្រោចស្រប់ដោយទឹកអប់ទិព្វ ៗ ដោយអានុភាពព្រះឥន្ទនឹងអានុភាពបុណ្យ ក៏ពោធិសត្វរស់រានមានជីវិតឡើងវិញ ៗ ព្រះឥន្ទពោលសរសើរពោធិសត្វថា ម្នាលមហាបុរស, ចូរអ្នកដឹងចុះថា អ្នកបានធ្វើបុញ្ញកម្មនេះ អ្នកនឹងបានត្រាស់ជាព្រះពុទ្ធក្នុងអនាគតជាប្រាកដ ៗ ពោធិសត្វ ឮពាក្យនោះហើយក៏សួរថា ម្នាលសំឡាញ់, អ្នកមកពីណា? ព្រះឥន្ទប្រាប់ថា ខ្ញុំមកពីឋានសួគ៌, ខ្ញុំជាតួអគ្គសក្កទេវរាជ មកកាន់សំណាក់អ្នកព្រោះហេតុតែអ្នកជាបុគ្គលមានសទ្ធាច្រើន ៗ ព្រះឥន្ទប្រាប់តែប៉ុណ្ណោះហើយ ក៏ប្រែភេទជាព្រះឥន្ទវិញ បញ្ចេញរស្មីភ្លឺរុងរឿងទៅឰដ៏អាកាស ដូចជាព្រះអាទិត្យក្នុងពេលពេញពន្លឺធំ, លាពោធិសត្វត្រឡប់ទៅឋានរបស់ព្រះអង្គវិញ ៗ

គ្រានោះ ព្រះរាជាព្រមទាំងបណ្ដាជនអ្នកនគរទាំងឡាយ មានសេចក្ដីរីករាយ ធ្វើសក្ការៈចំពោះពោធិសត្វ ។ ចំណែកខាងព្រះរាជាក៏អញ្ជើញពោធិសត្វឲ្យអង្គុយលើសុវណ្ណសិវិកា ទ្រង់ព្រះរាជទានសម្បត្តិផ្សេងៗ ជាច្រើនប្រការទៀត ។ ពោធិបត្នីព្រមទាំងបុត្រភរិយា សោយសម្បត្តិជាសុខគ្រប់ប្រការ, មានភូមទេវតា អាកាសទេវតា អភិបាលថែរក្សាសព្វកាលវេលា បុគ្គលមានសេចក្ដីសម្រិទ្ធ បរិបូណ៌ដោយភោគសម្ប័ទគ្រប់ជំពូក ឥតមានរោគអាពាធព្យាធិ អស់មួយជីវិត ។

ក្នុងកាលដែលពោធិសត្វជិតអស់ជន្មាយុ ទេវតាទាំងឡាយក្នុងឆកាមាវចរសួគ៌ បាននាំប្រាសាទមាស ៦ ពេញដោយស្រីទេពអប្សរចុះមកអំពីទេវលោកទាំង ៦ ជាន់ មកប្រតិស្ឋាននៅខាងលើអាកាស ហើយអញ្ជើញពោធិសត្វថា បពិត្រអ្នកជាទិវង្គត, សូមអ្នកអញ្ជើញមក, សូមអ្នកទៅត្រេកអរក្នុងទេវលោករបស់យើងឯណោះ ។ ពោធិសត្វសួរថា ចុះពោធិសត្វទាំងឡាយ ដែលបានកសាងពោធិសម្ភារហើយ តែងបានទៅកើតក្នុងឋានសួគ៌ជាន់ណា ? ទេវតាទាំងឡាយជម្រាបថា តែងបានទៅកើតក្នុងពិភពតុសិត ។ ពោធិសត្វថា បើដូច្នោះ ខ្ញុំនឹងទៅក្នុងពិភពតុសិតនោះឯង ។ ទេវតាទាំងឡាយ ក៏ទទួលលើកយកវិញ្ញាណក្ខន្ធរបស់ព្រះពោធិសត្វនោះ ដាក់លើរាជរថ ។ ពោធិសត្វក៏រលត់ផ្ដាច់ជីវិតិន្ទ្រិយ អំពីមនុស្សលោកនេះ ទៅកើតក្នុងពិមានមាស កំពស់ ១២ យោជន៍ ពេញដោយស្រីទេពអប្សរបរិវារកញ្ញានៅនាពិភពតុសិតឯណោះមួយរំពេច ដូចជាគេដេកលក់ហើយភ្ញាក់ឡើងក្លាយដូច្នោះ ។ សម្បត្តិ

ឯណាដែលពោធិសត្វបង់សោយ, ក៏សឹងសម្រេចឡើងព្រមឥតមានខ្វះ កន្ទះ ។ ពោធិសត្វបិតនៅក្នុងទិព្វសម្បត្តិនោះដោយសេចក្ដីរុងរឿងថ្លៃថ្លាណាស់ ឈ្នះអស់ទេវតាទាំងពួង ដោយពណ៌សម្បុរដោយយសបរិវារ ដោយឥស្សរភាព ។ ពោធិសត្វសោយសម្បត្តិក្នុងឋានសួគ៌មានសភាពដូច្នោះអស់កាលជាយូរអង្វែង, ទើបព្រះអង្គមានបំណងបំពេញព្រះបារមី ក៏ច្យុតស្រុតចុះចាកសួគ៌ាល័យ មកទ្រង់សំកតចាប់កំណើតកើតក្នុងមហារាជត្រកូលមានវ័យវឌ្ឍនាការចំរើនធំឡើង ទ្រង់បានសោយរាជសម្បត្តិ ជាស្ដេចចក្រពត្តិ គ្រប់សង្កត់សកលមណ្ឌលប្រថពី ត្រួតត្រាលើបណ្ដាជនប្រុសស្រី ដោយទឹកព្រះរាជហឫទ័យប្រកបដោយធម៌មេត្តា ឥតប្រើអាជ្ញា ឥតប្រើគ្រឿងសស្ត្រាឡើយ, ទ្រង់រក្សាអាណាប្រជានុរាស្ត្រ ដោយសង្គហវត្ថុទាំង ៤ ប្រការ, ពួកព្រះរាជា ដែលជាប្រទេសរាជក្នុងទិសទាំង ៤ ក៏ព្រះអង្គផ្ដល់ឲ្យនូវសេចក្ដីសុខក្សេមក្សាន្តឥតឲ្យមានទុក្ខព្រួយឡើយ, ហើយព្រះអង្គតែងទ្រង់បំពេញនូវពោធិសម្ភារដើម្បីឲ្យបានត្រាស់ប្រាជ្ញាសព្វញ្ញុតញ្ញាណ ។ តពីនោះមក ព្រះអង្គតែងអន្ទោលទៅក្នុងទេវលោកនឹងមនុស្សលោក បំពេញព្រះបារមីដរាបដល់បានសម្រេចគ្រប់ប្រការ ទ្រង់បានទៅកើតក្នុងពិភពតុសិត, ច្យុតអំពីពិភពតុសិត បានមកកើតក្នុងសក្យត្រកូលជាអង្គព្រះអាទិច្ចវង្ស ទ្រង់លះបង់រាជសម្បត្តិ កាត់ព្រះរាជហឫទ័យ ចេញទៅទ្រង់ព្រះផ្នួសធ្វើបធានកិរិយាអស់ ៦ វស្សា ហើយចូលទៅកាន់ពោធិមណ្ឌល ឡើងគង់លើរតនបល្ល័ង្កជាមង្គល កំចាត់បង់នូវមារព្រមទាំងពលដ៏ច្រើនដេរ

ជាសក្រមាស់ ៣០ យោជន៍ ។ ទើបពពួកទេវតាក្នុង ១ ម៉ឺនចក្រវាឡ មូលមកប្រជុំគ្នាក្នុងចក្រវាឡមួយ បើកទ្វារលើកទង់សំយុងកម្រងមាលា បាចសាចផ្កា ពាសពេញទាំងអាកាស ដាសពាសដល់ផែនប្រឹថពី ។ ទេវតានិងព្រហ្មទាំងឡាយពួកខ្លះ កាន់ផ្លិតចាមរពាសលំអដោយផែនសុវណ្ណ មានដងស្រោបកាន់វិចិត្រដោយកែវឥន្ទនីល បក់ផាត់ថ្វាយពីខាងលើអាកាស ។ គ្រឿងបូជាទាំងឡាយច្រើនដេរដាស ចង្អៀតពេញទាំងផ្ទៃអាកាសស្ទើរតែគ្មានកន្លែងសល់ចន្លោះ ពួកព្រហ្មទាំងអស់ក៏ផ្គងអញ្ជលីដាក់លើសិរសា នាំគ្នាច្រៀងសរសើរពោធិសម្ភារ ដោយសំឡេងដ៏ពីរោះក្បោះក្បាយ ទាំងព្រឹក្សាលតាវល្លិផងទាំងឡាយក៏បញ្ចេញបុប្ផាផលទាំងចង្កោមទាំងផ្កាយ ផ្សាយក្លិនក្រយាសាយសព្វទិសានុទិស ទាំងបទុមជាតិបញ្ចពណ៌ ក៏ដុះផុះទំលាយចេញដែនប្រឹថពីរីកស្គុះស្គាយផ្សាយក្លិនទៅសព្វទិសទី បូជាព្រះជិនស្រី ក្នុងពេលដែលព្រះអង្គជិតបានត្រាស់ ។ ព្រះបរមពោធិសត្វ ទ្រង់បាននូវបុទ្ធិដ៏វិសេសគ្រប់យ៉ាង ទ្រង់បាននូវសក្ការបូជាដ៏វិសេស ទ្រង់បាននូវសម្បត្តិដ៏វិសេសគ្រប់ប្រការ ដោយអានិសង្សនៃការកសាងព្រះពុទ្ធបដិមា ។

សេចក្ដីពិតថា បុគ្គលអ្នកកសាងព្រះពុទ្ធបដិមាដែលកំពុងអន្ទោលទៅក្នុងវដ្ដសង្សារ រមែងបានសោយផលអានិសង្សនៃព្រះពុទ្ធបដិមាមិនចេះអស់ មិនចេះរលស់ ដរាបតែដល់ព្រះនិព្វានជាទីបំផុត; ព្រោះហេតុនោះបានជាអង្គសម្ដេចព្រះសម្ពុទ្ធ ទ្រង់ត្រាស់សំដែងថា បុគ្គលឯណាបានកសាងព្រះពុទ្ធរូប, បុគ្គលនោះមិនដែលទៅកើតក្នុងទុគ្គតិទេ, តែង

តែទៅកើតក្នុងសុគតិ ហើយជាអ្នកមានលាភដ៏ប្រសើរ មានសម្បុរស្រស់ មានរូបល្អ ជាទីស្រឡាញ់នៃជនានុជន មានពួកនារីដ៏ប្រសើរ បម្រើសព្វទិវារាត្រី ជាអ្នកមានសីលាចារវត្ត មានគុណសម្បត្តិ បានជាអ្នកប្រាជ្ញពេញបណ្ឌិត្យដ៏ក្លៀវក្លា មានយស មានគំនិតប្រាជ្ញាដ៏មុះមុត ទោះបើប្រាថ្នាជាព្រះពុទ្ធ ឬសាវ័ករបស់ព្រះពុទ្ធ ក៏នឹងបានសម្រិទ្ធិបំណងដូចសេចក្ដីប្រាថ្នា; នេះជាផលនៃការកសាងព្រះពុទ្ធរូប ។

ទេសនាវសានេ គ្រាកាលសម្ដេចព្រះបរមសាស្ដា ទ្រង់ត្រាស់សំដែងព្រះធម៌ទេសនាចប់សព្វគ្រប់ហើយ (១) ទ្រង់ត្រាស់ប្រកាសអរិយសច្ចទាំង ៤ ប្រការ ហើយទ្រង់ប្រជុំជាតកថា ព្រះបាទមហារដ្ឋរាជ បេរវិលវិញមក បានជាសារីបុត្ត, ព្រះបាទបញ្ចាលរាជ បានជាអានន្ទ, រាជទូតបានជាមោគ្គលាន, ព្រះឥន្ទ្រ បានជាអនុរុទ្ធ, វិរិយបណ្ឌិត បានត្រាស់ប្រាជ្ញាសព្វញ្ញុតញ្ញាណ គឺអង្គតថាគតជាលោកនាថហ្នឹងឯង; អ្នកទាំងឡាយចូរចាំទុកនូវជាតក យ៉ាងនេះចុះ ។

ចប់ វិរិយបណ្ឌិតជាតក ទី ១៧

(មានត)

---

១ ជាតកនេះ ខុសពីជាតកទាំងពួង ព្រោះចាប់និយាយរឿងឡើងតែម្ដង មិនប្រាប់ថាអ្នកណាសំដែងរឿងនោះ, ដល់មកសេចក្ដីបញ្ចប់ទើបប្រាប់ថាព្រះបរមសាស្ដាសំដែង, ប្រហែលលោកអ្នកតែងជាតកនេះ ភ្លេចថាទេដឹង ?

# រឿងធម្មទ្ធជបណ្ឌិត

ក្នុងគម្ពីរខុទ្ទកនិកាយ ទុកនិបាត

## លោក គាំ-ឌុំ

លេខាធិការការិយាល័យសារមន្ទីរអាល់បែរសារ៉ូ

ប្រែនិងរៀបរៀង

(តចប់)

---

ព្រះពោធិសត្វត្រឡប់ទៅផ្ទះវិញ ដល់ព្រឹកឡើងស្រស់ស្រូបអាហាររួចហើយក៏ម្នីម្នាទៅឯព្រះរាជវាំង ក៏បានឃើញនាយខ្វាន់ប្រកេសឈ្មោះឆត្តបាណិនៅក្នុងទីនោះដែរ ពោធិសត្វស្ទុះទៅចាប់ដៃហើយសួរថា នែឆត្តបាណិសំឡាញ់ ឮថាលោកប្រកបដោយអង្គ ៤ មែនឬ? ។

ឆត្តបាណិ — ចុះនរណាប្រាប់លោកថាខ្ញុំប្រកបដោយអង្គ ៤ ហ្នឹង? ។

ពោធិសត្វ — ព្រះឥន្ទ្រជាស្តេចទេវតាប្រាប់ខ្ញុំណា៎ះសំឡាញ់ ។

ឆត្តបាណិ — ចុះហេតុអ្វីបានជាព្រះឥន្ទ្រប្រាប់លោក? ។

ព្រះពោធិសត្វអធិប្បាយប្រាប់សព្វគ្រប់តាមដំណើររួចហើយ នាយឆត្តបាណិក៏ប្រាប់ទៅតាមត្រង់ថា អើសំឡាញ់ យើងប្រកបដោយអង្គ ៤ មែន ។

វេលានោះ ព្រះពោធិសត្វក៏ចាប់ដៃនាយឆត្តបាណិនាំទៅក្រាបទូលព្រះរាជាថា សូមទ្រង់ព្រះមេត្តាប្រោស ព្រះមហារាជ នាយឆត្តបាណិនេះប្រកបដោយអង្គ ៤ បើព្រះអង្គសព្វព្រះទ័យរកឧយ្យានបាល, សូមព្រះអង្គទ្រង់យកនាយឆត្តបាណិនេះធ្វើជាឧយ្យានបាលចុះ ។ ព្រះរាជា

ក៏ត្រាស់សួរទៅនាយឆត្តបាណិថា នែនាយ ឮថាអ្នកប្រកបដោយអង្គ ៤ មែនឬ? ។

ឆត្តបាណិ — សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គប្រកបដោយអង្គ ៤ មែន ។

ព្រះពុទ្ធ — ចុះអ្នកបានប្រកបដោយអង្គ ៤ ដូចម្តេចខ្លះទៅ? ។

នាយឆត្តបាណិក្រាបបង្គំទូលដោយព្រះគាថាថា:

អនុស្សុយ្យកោ អហំ ទេវ អមជ្ជបាយកោ អហំ
និស្នេហកោ អហំ ទេវ អក្កោធនរសធិដ្ឋិតោតិ ។

បពិត្រព្រះសម្មតិទេពមហារាជ ទូលព្រះបង្គំពុំបួស្យា គឺមិនប្រច័ណ្ឌប្រពន្ធ ១ ទូលព្រះបង្គំពុំទទួលព្រះពានទឹកស្រវឹង ១ ទូលព្រះបង្គំពុំស្រឡាញ់ (របស់ដទៃ) ១ ទូលព្រះបង្គំពុំបេះក្រោធខឹង ១ ទូលព្រះបង្គំប្រកបដោយអង្គ ៤ នេះ ដែលបានតាំងចិត្តរៀរជាស្រឡះហើយ ។

ព្រះពុទ្ធ — អើឆត្តបាណិ អម្បាញ់មិញអ្នកបាននិយាយថា ទូលព្រះបង្គំពុំប្រច័ណ្ឌប្រពន្ធទេ មែនឬឆត្តបាណិ? ។

ឆត្តបាណិ — សូមទ្រង់ព្រះមេត្តាប្រោស ទូលព្រះបង្គំពុំប្រច័ណ្ឌប្រពន្ធមែន ។

ព្រះពុទ្ធ — អើឆត្តបាណិ! ចុះអ្នកឃើញហេតុដូចម្តេចបានជាអ្នកមិនប្រច័ណ្ឌប្រពន្ធ? ។

នាយឆត្តបាណិ កាលដែលនឹងក្រាបទូលហេតុដែលខ្លួនមិនប្រច័ណ្ឌ

ប្រពន្ធឲ្យព្រះរាជាទ្រង់ព្រះសណ្ដាប់នោះ បាននាំយកនូវអតីតនិទានរបស់ខ្លួនដោយព្រះគាថាមួយបទថា:

ឥត្ថិយា ការណា រាជ ពន្ធាបេសិ បុរោហិតំ
សោ មំ អត្ថេ និវេសេសិ តស្មាហំ អនុស្សយ្យកោតិ ។

បពិត្រព្រះមហារាជ ព្រោះហេតុតែស្ត្រីប្រពន្ធ បានជាទូលព្រះបង្គំប្រើរាជបុរសឲ្យចាប់បុរោហិតចង ( ប៉ងទឹងសំឡាប់ ) តែបុរោហិតនោះ បានញុំាងទូលព្រះបង្គំឲ្យតាំងនៅក្នុងប្រយោជន៍វិញ ព្រោះហេតុនោះបានជាទូលព្រះបង្គំពុំប្រច័ណ្ឌប្រពន្ធ ។

សេចក្ដីពិស្ដារនៃរឿងនេះថា "បពិត្រព្រះមហារាជ សូមទ្រង់ព្រះមេត្តាប្រោស កាលពីដើមទូលព្រះបង្គំកើតជាព្រះរាជាឈ្មោះព្រហ្មទត្តក្នុងក្រុងពារាណសីនេះ កាលនោះព្រះពោធិសត្វកើតជាបុរោហិតនៃព្រះរាជានោះ ។

ថ្ងៃមួយ ព្រះរាជានោះទ្រង់ព្រះរាជទានពរដល់ព្រះអគ្គមហេសីថា នែនាងទេវី នាងត្រូវការបង់បានអ្វី ចូរនាងនិយាយមកចុះ យើងនឹងឲ្យពរនាងតាមគាប់ចិត្ត ។ នាងទេវីឮហើយមានចិត្តត្រេកអរក៏ក្រាបបង្គំទូលសុំពរថា សូមទ្រង់ព្រះមេត្តាប្រោស ពរដទៃខ្ញុំម្ចាស់ពុំពិបាកនឹងរកឡើយ ខ្ញុំម្ចាស់សុំតែពរមួយយ៉ាង គឺតាំងពីថ្ងៃនេះតទៅសូមកុំឲ្យព្រះអង្គត្រូវការរមិលមើលពួកស្ត្រីដទៃ ដោយអំណាចកិលេសកាមឡើយ ។ ព្រះរាជានោះពុំអាចនឹងទទឹងទាស់ពាក្យសុំដែលនាងទេវីនោះទូលសុំបានទេ ទ្រង់ក៏ទទួលព្រមតាម ហើយតាំងពីថ្ងៃនោះទៅព្រះអង្គលែងត្រូវការរាប់រក

ពួកស្រ្តីស្នំទាំង ១៦.០០០ សូម្បីស្រីណាម្នាក់ដោយអំណាចកិលេសកាមសោះឡើយ ។

សម័យមួយនោះ មានចោរខ្មាំងបះបោរនៅស្រុកត្រង់ព្រំប្រទល់ដែនរបស់ព្រះរាជានោះ ពួកយោធាទាហានដែលនៅចាំរក្សាព្រំប្រទល់ដែនបានធ្វើសង្គ្រាមតយុទ្ធនឹងពួកចោរខ្មាំងនោះពីរបីគ្រាមិនឈ្នះ ទើបបញ្ជូនសំបុត្រទៅក្រាបទូលព្រះរាជា ។ ជ្រាបហើយទ្រង់មានព្រះរាជបំណងនឹងយាងទៅក្រាបសត្រូវក្នុងទីនោះដោយព្រះអង្គឯង ក៏ទ្រង់រៀបចាត់ចែងប្រមូលពួកពល រួចហើយទ្រង់ត្រាស់ហៅនាងទេវីនោះមកមានព្រះបន្ទូលថា នែនាងទេវី យើងនឹងទៅបច្ចន្តគ្រាមដើម្បីធ្វើសង្គ្រាមតយុទ្ធនឹងសត្រូវផ្សេងៗ ក្នុងទីនោះ ជាតិជាស្ត្រីនឹងទៅក្នុងទីដូច្នោះផងនាំឲ្យលំបាកគេរក្សាណាស់ បើដូច្នេះ ចូរនាងនៅចុះកុំទៅផងឡើយ ។ នាងទេវីនោះអង្វរសុំទៅជាមួយផងពុំបានហើយ នាងក៏ក្រាបបង្គំទូលសុំថា បើព្រះអង្គពុំទ្រង់អនុញ្ញាតឲ្យខ្ញុំម្ចាស់ទៅជាមួយផងទេ ខ្ញុំម្ចាស់ក៏ព្រមនៅដែរ ប៉ុន្តែសូមព្រះអង្គប្រើមនុស្សម្នាក់ៗ ឲ្យត្រឡប់មកសួរឲ្យដឹងសុខទុក្ខរបស់ខ្ញុំម្ចាស់គ្រប់តែព្រះរាជដំណើរ ដែលព្រះអង្គយាងទៅបានចម្ងាយ ១ យោជន៍ៗ ។ ព្រះរាជាក៏ព្រមទទួលតាមពាក្យនាងសុំ ទ្រង់ទុកតែព្រះពោធិសត្វជាបុរោហិតឲ្យនៅចាំព្រះនគរ ទ្រង់ក៏នាំពួកពលជាច្រើនយាងចេញទៅ ហើយបញ្ជូនបុរសម្នាក់ៗ ឲ្យត្រឡប់មកសួរឲ្យដឹងសុខទុក្ខរបស់នាងទេវី នឹងទូលនាងទេវីឲ្យដឹងអំពីសុខទុក្ខពុំមានរោគរបស់ព្រះអង្គគ្រប់តែព្រះរាជដំណើរ ដែលទ្រង់យាងទៅបានចម្ងាយ ១ យោជន៍ៗ ។ ចំណែក

ឯនាងទេវី កាលបើបានឃើញបុរសដែល ព្រះកជាបញ្ជូនទៅហើយនោះ តែងតែហៅបុរសនោះឲ្យមកធ្វើអសទ្ធម្មនឹងខ្លួនតែគ្រប់ៗគ្នា ។ ព្រះកជាទ្រង់យាងទៅចម្ងាយផ្លូវ ៣២ យោជន៍ បានបញ្ជូនបុរសឲ្យទៅសួរនាងទេវីចំនួន ៣២ នាក់ដែរ ឯនាងទេវីក៏បានប្រព្រឹត្តធ្វើអសទ្ធម្មជាមួយនឹងបុរសទាំងអស់នោះដូចគ្នា ។

ព្រះកជាលុះបានកំកបសត្រូវនៅបច្ចន្តគ្រាមរួចហើយ វេលាដែលទ្រង់យាងត្រឡប់មកព្រះនគរវិញបានបញ្ជូនមនុស្ស ៣២ នាក់ឲ្យមកសួរនាងទេវីតាមចំនួនដូចមុន ឯនាងទេវីក៏បានប្រព្រឹត្តក្បត់ព្រះកជាជាមួយនឹងបុរសទាំងនោះដូចមុនទៀត រួមបុរសទាំងអស់ជា ៦៤ នាក់ ។ ព្រះកជាយាងមក ទ្រង់បញ្ឈប់កងទ័ពពជ័យយោធានៅខាងក្រៅព្រះកជកំពង់ទ្រង់ផ្ញើសំបុត្រទៅប្រាប់ព្រះពោធិសត្វ ឲ្យតុបតែងស្អិតស្អាងសំអាតព្រះនគរឲ្យស្រេចជាមុន ។

ឯព្រះពោធិសត្វក៏ប្រាសសំអាតព្រះនគរ លុះប្រាសជំរះព្រះកជនិវេសនដ្ឋានរួចហើយទើបទៅប្រាសដល់ទីព្រះដំណាក់នៃនាងទេវីជាខាងក្រោយ ។

ឯនាងទេវីបានឃើញព្រះពោធិសត្វបរិបូណ៌ដោយរូបសម្បត្តិសឹងតែល្អឆើត នាងអត់សង្កត់ចិត្តពុំបាន ក៏មានព្រះសវនីយ៍ហៅព្រះពោធិសត្វថា នែព្រាហ្មណ៍ ចូរអ្នកអញ្ជើញឡើងមកសម្រាន្តលើទីសយនាជាមួយនឹងយើង ។ ព្រះពោធិសត្វឃាត់ថា កុំព្រះនាងម្ចាស់, ព្រោះព្រះកជាជាទីគោរពរបស់ខ្ញុំ ខ្ញុំខ្លាចអំពើអកុសល ខ្ញុំពុំហ៊ានធ្វើអំពើយ៉ាងនេះឡើយ ។

នាងទេវី — ចុះព្រះរាជាមិនជាចៃគោរពរបស់មហាគលិកទាំង ៦៤ នាក់ទេឬ អ្នកទាំងនោះមិនខ្លាចអំពើអកុសលទេឬ ព្រះរាជាជាទីគោរពអើតែអ្នកម្នាក់ឯង អ្នកខ្លាចអំពើអកុសលអើតែម្នាក់ឯង ។

ពោធិសត្វ — អើនាង បើមហាគលិកទាំងនោះបានធ្វើយ៉ាងនេះក៏ស្រេចនៅលើរូបគេចុះ ចំណែកខ្ញុំ ។ ពុំហ៊ានធ្វើយ៉ាងនេះឡើយ ។

នាងទេវីប្រលោមលោមព្រះពោធិសត្វអស់ចិត្តហើយ ក៏បែរជាគម្រាមទៅវិញថា ចុះអ្នកឯងនិយាយច្រើនអីម៉្លេះ បើអ្នកពុំព្រមតាមពាក្យយើងទេ យើងនឹងក្រាបទូលព្រះរាជាឲ្យកាត់ក្បាលអ្នកហើយ ។

ពោធិសត្វ — កុំថាឡើយកាត់ក្បាលខ្ញុំត្រឹមតែមួយជាតិនេះ ទុកជាកាត់ក្បាលខ្ញុំដល់មួយពាន់ជាតិក៏ដោយ ក៏ខ្ញុំពុំធ្វើអំពើយ៉ាងនេះឡើយ ។ នាងទេវីដឹងថាមិនសម្រេចដូចសេចក្ដីប្រាថ្នាហើយ ក៏ចូលទៅក្នុងបន្ទប់របស់ខ្លួន ហើយខ្វារក្រចកខ្វាំសរីរៈឲ្យមានស្នាមលោតជាប់ដោយក្រចក រួចយកប្រេងលាបខ្លួនស្លៀកសំពត់ដែលសៅហ្មងមិនស្អាតហើយប្រាប់ពួកទាសីថា បើព្រះរាជាសួររកយើងឲ្យក្រាបទូលថា យើងឈឺ ។

ព្រះពោធិសត្វលុះបានគុបតែងសំអាតរូបហើយ ក៏បេញទៅទទួលព្រះរាជា ។ យាងចូលទៅធ្វើប្រទក្សិណព្រះនគរហើយ ក៏យាងឡើងទៅលើប្រាសាទត្រាស់សួររកនាងទេវី លុះទ្រង់បានឮពួកទាសីក្រាបបង្គំទូលថា នាងទេវីទ្រង់អផ្សុកដូច្នោះ ព្រះរាជាក៏យាងចូលទៅក្នុងបន្ទប់បរោសអង្អែលខ្លួននាងហើយត្រាស់សួរថា នែនាងទេវី ចុះនាងពុំសប្បាយឬអ្វី ? ។ នាងទេវីស្ងៀមឈឹងពុំក្រាបទូលតបសោះឡើយ លុះព្រះរាជា

ត្រាស់សួរជាគំរប់ ៣ ដងហើយ ទើបនាងងៀងព្រះនេត្រាមើលព្រះរាជា ហើយក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ព្រះករុណាជាម្ចាស់ជីវិត ព្រះអង្គទ្រង់គង់ព្រះជន្មាយុនៅឡើយ អម្បាលស្ត្រីប្រហែលដូចជាខ្ញុំម្ចាស់ ជាស្ត្រីមានព្រះអង្គជាព្រះស្វាមី ពុំសមបីបុរោហិតដែលព្រះអង្គទុកឲ្យ នៅរក្សាព្រះនគរ មកបោសសំអាតទីព្រះដំណាក់នេះហើយ ហ៊ានមក ប្រហារប្រពាយប្រគប់ខ្ញុំម្ចាស់ដែលពុំព្រមដោយតាមគាត់ទាល់តែបាន បំពេញសេចក្តីប្រាថ្នារបស់ខ្លួនហើយទើបចេញទៅឡើយ ។

ព្រះរាជាឮហើយទ្រង់ព្រះក្រោធប្រឡេតខ្លាំងញ័រព្រះកក្រហាក់ ដូចដុំអំបិលដែលគេដាក់ទៅក្នុងព្រះអគ្គី ទ្រង់យាងចេញអំពីទីសិរីសយនា មានព្រះឧង្ការត្រាស់ហៅពួកអ្នករក្សាទ្វារទឹងពួកមហាតលិកជាដើមមកថា ចូរព្រះស្តែងពលគ្នាទៅចាប់បុរោហិតចងស្លាបសេកនាំចេញអំពីនគរទៅឯ អាឃាតនដ្ឋានកាត់ក្បាលវាសម្លាប់ចោលទៅ ។ ឯរាជបុរសទាំងនោះក៏នាំ គ្នាទៅចាប់ព្រះពោធិសត្វចងស្លាបសេក ហើយបណ្តើរអាក្រាសធ្វើវជ្ឈ-គេរីបរក៏តាមជាលំដាប់ព្រះនគរ ។ ព្រះពោធិសត្វពិចារណាយល់ឃើញ ថា "មុខជានាងទេវីកំណាចញុះញង់ព្រះរាជាជាប្រាកដ បើដូច្នោះអញ នឹងដោះខ្លួនឲ្យរួចដោយកម្លាំងប្រាជ្ញាខ្លួនអញឲ្យបានក្នុងថ្ងៃនេះ" ទើបព្រះ ពោធិសត្វនិយាយទៅរករាជបុរសទាំងនោះថា អ្នកទាំងឡាយកុំអាល សម្លាប់ខ្ញុំ. សូមនាំខ្ញុំទៅថ្វាយដល់ព្រះរាជាសិនសឹមសំឡាប់ចុះ ព្រោះ ខ្ញុំជារាជកម្មិកបុរស មានការងារជាច្រើនដែលខ្ញុំបានធ្វើហើយ ខ្ញុំក៏បាន ដឹងទីទុកដាក់របស់ជាច្រើន, ខ្ញុំជាអ្នកចាត់ចែងព្រះរាជទ្រព្យ ប្រសិន

បើអ្នកទាំងឡាយ ពុំបាននាំខ្ញុំទៅថ្វាយព្រះរាជាទេ មុខជាទីវិនាស ទ្រព្យជាច្រើនពុំខាន កាលបើខ្ញុំបានក្រាបទូលព្រះរាជមតិកថ្វាយព្រះរាជារួចហើយ សឹមអ្នកទាំងឡាយធ្វើតាមអំពើជាខាងក្រោយចុះ ។ ឯរាជបុរសទាំងនោះក៏នាំព្រះពោធិសត្វទៅថ្វាយព្រះរាជា ។ បានឃើញហើយទ្រង់ត្រាស់សួរថា អើព្រាហ្មណ៍ចុះអ្នកឯងហេតុអ្វីក៏ពុំមានខ្មាសដល់យើងសោះ ព្រោះហេតុអ្វី បានជាអ្នកហ៊ានធ្វើអំពើអាក្រក់យ៉ាងនេះ? ។

ពោធិសត្វ — សូមទ្រង់ព្រះមេត្តាប្រោស ព្រះមហារាជជាអម្ចាស់ជីវិតលើត្បូង ទូលព្រះបង្គំកើតក្នុងសោត្ថិយត្រកូល សត្វមានជីវិតសូម្បីត្រឹមតែស្រមោចខ្មៅ ស្រមោចក្រហម ក៏ទូលព្រះបង្គំពុំដែលសម្លាប់, ទ្រព្យដែលម្ចាស់គេពុំបានឲ្យសូម្បីត្រឹមតែស្មៅមួយទង ក៏ទូលព្រះបង្គំពុំដែលយក, ស្ត្រីរបស់អ្នកដទៃ ក៏ទូលព្រះបង្គំពុំដែលបើកភ្នែកមើលដោយអំណាចលោភតណ្ហា, ពាក្យកុហកសូម្បីត្រឹមតែដោយអំណាចប្រាថ្នាទីងសើចលេង ក៏ទូលព្រះបង្គំពុំដែលនិយាយ, ទឹកស្រវឹងសូម្បីត្រឹមតែក្រេបផឹកដោយចុងស្បូវ ក៏ទូលព្រះបង្គំពុំដែលទទួលព្រះទានឡើយ, ទូលព្រះបង្គំពុំមានទោសកំហុសអ្វីនឹងព្រះអង្គទេ គឺនាងទេវីទេតើជាស្រីពាលចិត្តសាហាវចាប់ដៃទូលព្រះបង្គំដោយលោភតណ្ហា ទូលព្រះបង្គំប្រកែកយ៉ាងណាក៏ពុំព្រមតាមត្រឡប់ជាគម្រាមទូលព្រះបង្គំវិញ រួចហើយខ្វាររាំធ្វើអាក្រក់ដោយខ្លួនឯង សំដែងឲ្យឃើញច្បាស់ប្រាប់ទូលព្រះបង្គំហើយចូលទៅសម្ងំនៅក្នុងបន្ទប់ ឯទូលព្រះបង្គំជាអ្នកឥតទោសឡើយ មានតែមហាតលិកទាំង ៦៤ នាក់ ដែលយកសំបុត្រមកថ្វាយនាងទេវីនោះ

ទើបមានទោសកំហុសមែន សូមព្រះករុណាជាអម្ចាស់ជីវិតលើត្បូងទ្រង់ត្រាស់ហៅអ្នកទាំងនោះមកសួរឲ្យដឹងថា សំដីអ្នកទាំងនោះបានធ្វើតាមនាងទេវីដែរឬពុំបានធ្វើទេ ។ ព្រះរាជាត្រាស់ប្រើឲ្យរាជបុរសចាប់ មហាតលិកទាំង ៦៤ នាក់នោះចងហើយត្រាស់សួរនាងទេវីថា នាងឯងបានធ្វើអំពើលាមកជាមួយនឹងមហាតលិកទាំងអស់នេះមែន ឬពុំបានធ្វើទេ? ។

នាងទេវី– សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំម្ចាស់បានធ្វើមែន ។

ព្រះរាជាក៏ឲ្យចាប់នាងទេវីចងស្ពាយសេក ហើយត្រាស់បង្គាប់ឲ្យរាជ-បុរសកាត់ក្បាលមហាតលិកទាំង ៦៤ នាក់ជាមុន ។

វេលានោះ ព្រះពោធិសត្វជាបុរោហិត បានក្រាបទូលសូមទោសនឹងព្រះរាជាថា បពិត្រព្រះមហារាជ មហាតលិកទាំងនោះពុំមានទោសទេ ព្រោះនាងទេវីបង្គាប់ឲ្យធ្វើអំពើអសទ្ធម្មតាមអធ្យាស្រ័យរបស់នាង ហេតុនោះ សូមព្រះអង្គទ្រង់ព្រះរាជទានទោសដល់មហាតលិកទាំងនុ៎ះ ចំណែកនាងទេវីក៏ពុំមានទោសដែរ ព្រោះធម្មតាស្ត្រីរមែងមិនឆ្អែតស្កប់ស្កល់ដោយមេថុនធម្មដូចគ្នាទាំងអស់ ហេតុនោះ សូមព្រះអង្គទ្រង់ព្រះរាជទានទោសដល់នាងផង ។

ព្រះពោធិសត្វបានញុំាងព្រះរាជាឲ្យទទួលព្រះរាជហឫទ័យអភ័យទោសដោះលែងមហាតលិកទាំង ៦៤ នាក់នោះ ព្រមទាំងនាងទេវីឲ្យរួចចាកទោសដោយប្រការផ្សេងៗ ហើយឲ្យតាំងនៅក្នុងដំណែងតាមឋានៈរបស់ខ្លួនទាំងអស់វិញ (១) ។

---

១ រឿងដែលពោលមកនេះ មានពិស្តារក្នុងពន្លមោក្ខជាតកហាំសិវគ្គ ក្នុងឯកនិបាត, ដែលស្រង់មកនិយាយក្នុងធម្មទូជជាតកនេះជាសេចក្ដីសង្ខេប ។

នាយឆត្តបាណិក្រាបទូលព្រះរាជាតទៅទៀតថា បពិត្រព្រះមហារាជ កាលនោះឯងទ្រង់ព្រះបន្ទូលព្រះរាជាទ្រង់ត្រិះរិះថា "យើងបានលះបង់លែងរើរកនាងស្រី ១៦.០០០ ចេញហើយ នៅសង្គ្រោះចំពោះតែនាងទេវីនេះម្នាក់ឯងប៉ុណ្ណោះដោយកិលេសកាម ក៏នៅតែមិនអាចនឹងឲ្យនាងទេវីឆ្អែតស្កប់ស្កល់ដោយកាមបាន បើក្រោធនឹងចំពោះពួកស្រីដែលគេតែងតែបំពេញសេចក្តីប្រាថ្នាបានដោយក្រយ៉ាងនេះ ក៏ដូចជាក្រោធនឹងនឹងសំពត់ដែលស្លៀកដណ្តប់ប្រឡាក់សៅហ្មង ហើយបន្ទោសសំពត់ថា ហេតុអ្វីក៏ប្រឡាក់? ពុំនោះសោត ដូចជាក្រោធនឹងនឹងអាហារដែលបរិភោគរលួយរលាយទៅជាលាមកហើយបន្ទោសអាហារថា ហេតុអ្វីក៏រលួយទៅជាលាមក" លុះទ្រង់យល់ដូច្នេះហើយ ទើបទ្រង់អធិដ្ឋានតាំងទុកក្នុងព្រះទ័យថា តាំងពីថ្ងៃនេះទៅ បើយើងពុំទាន់បានសម្រេចអរហត្តត្រឹមណាទេ ការឫស្យាប្រច័ណ្ឌប្រពន្ធព្រោះតែកិលេស សូមកុំឲ្យកើតឡើងដល់យើងបានត្រឹមណោះដែរ ។ តាំងពីកាលនោះមកព្រះរាជានោះក៏លែងប្រច័ណ្ឌទៅ ។ បពិត្រព្រះមហារាជ អាស្រ័យហេតុនេះឯងបានជាទូលព្រះបង្គំពុំប្រច័ណ្ឌប្រពន្ធ ។

ព្រះរាជាទ្រង់ត្រាស់សួរតទៅទៀតថា អើឆត្តបាណិសំឡាញ់ ចុះអ្នកឃើញអារម្មណ៍ដូចម្តេច បានជាអ្នកពុំផឹកទឹកស្រវឹង? ។

នាយឆត្តបាណិ កាលនឹងក្រាបទូលហេតុដែលខ្លួនមិនផឹកទឹកស្រវឹងឲ្យព្រះរាជាទ្រង់ព្រះសណ្តាប់នោះ បាននាំយកនូវអតីតនិទានរបស់ខ្លួនដោយព្រះគាថាមួយបទថា:

បមត្តោហំ មហារាជ    បុត្តមំសានិ ខាទសឹ
តស្ស សោកេនាហំ ផុដ្ឋោ    មជ្ជបានំ វិវជ្ជយិន្តិ ។

បពិត្រព្រះមហារាជ ទូលព្រះបង្គំជាមនុស្សស្រវឹងបានស៊ីសាច់កូនរបស់ខ្លួន ទូលព្រះបង្គំត្រូវសេចក្ដីសៅសោកព្រោះកូននោះមកប៉ះពាល់ហើយ ក៏បានវៀរស្រឡះនូវការផឹកទឹកស្រវឹងចោលចេញទៅ ។

សេចក្ដីពិស្ដារនៃរឿងនេះថា បពិត្រព្រះមហារាជ កាលពីដើមទូលព្រះបង្គំកើតជាព្រះរាជកូនក្រុងពារាណសីហ្នឹងដែរ ជាអ្នកផឹកទឹកស្រវឹងពុំអាចវៀរបង់បាន ហើយជាអ្នកស៊ីសាច់ ពុំអាចបរិភោគអាហារដែលគ្មានសាច់បានឡើយ ។ ក្នុងថ្ងៃឧបោសថ អ្នកនគរតែងតែមិនសម្លាប់សត្វជាធម្មតា ឯអ្នកធ្វើព្រះស្ងោយបានសំចៃសាច់ទុកខ្វះពីថ្ងៃទី ១៣ នៃបក្ខគឺថ្ងៃ ១៣ កើតឬ ១៣ កេច ឯសាច់នោះឯងដោយហេតុទុកដាក់មិនល្អឆ្កែក៏ស៊ីអស់ទៅ ។ អ្នកធ្វើព្រះស្ងោយដល់ថ្ងៃឧបោសថហើយរកសាច់ពុំបាន គ្រាន់តែចំអិនព្រះស្ងោយមានរសឆ្ងាញ់ផ្សេងៗរួចហើយពុំហ៊ានយកឡើងទៅលើប្រាសាទថ្វាយដល់ព្រះរាជាឡើយ ក៏ចូលទៅក្រាបទូលនាងទេវីថា បពិត្រព្រះទេពីម្ចាស់ ថ្ងៃនេះទូលព្រះបង្គំរកសាច់ពុំបាន ទូលព្រះបង្គំពុំហ៊ានយកព្រះស្ងោយដែលពុំមានសាច់ទៅថ្វាយព្រះរាជាទេ បើដូច្នេះឲ្យទូលព្រះបង្គំធ្វើដូចម្ដេច? ។ នាងទេវីក៏ប្រាប់ឧបាយថា នែអ្នកនាយ មិនអីទេ បុត្តរបស់ខ្ញុំជាទីស្រឡាញ់សព្វព្រះរាជហឫទ័យនៃព្រះរាជាណាស់ បើព្រះអង្គបានឃើញហើយមុខជាជាប់ព្រះទ័យតែនឹងក្រសាល

បមត្តោហំ មហារាជ បុត្តមំសានិ ខាទសឹ
តស្ស សោកេនាហំ ផុដ្ឋោ មជ្ជបានំ វិវជ្ជយិត្តិ ។

បពិត្រព្រះមហារាជ ទូលព្រះបង្គំជាមនុស្សស្រវឹងបានស៊ី សាច់កូនរបស់ខ្លួន ទូលព្រះបង្គំត្រូវសេចក្ដីសៅសោកព្រោះ កូននោះមកប៉ះពាល់ហើយ ក៏បានវៀរស្រឡះនូវការផឹកទឹក ស្រវឹងចោលចេញទៅ ។

សេចក្ដីពិស្ដារនៃរឿងនេះថា បពិត្រព្រះមហារាជ កាលពីដើមទូលព្រះបង្គំកើតជាព្រះរាជកុមារក្រុងពារាណសីហ្នឹងដែរ ជាអ្នកផឹកទឹកស្រវឹង ពុំអាចវៀរបង់បាន ហើយជាអ្នកស៊ីសាច់ ពុំអាចបរិភោគអាហារដែល គ្មានសាច់បានឡើយ ។ ក្នុងថ្ងៃឧបោសថ អ្នកនគរតែងតែមិនសម្លាប់សត្វ ជាធម្មតា ឯអ្នកធ្វើព្រះស្ងោយបានសំចៃសាច់ទុកខ្លះពីថ្ងៃទី ១៣ នៃបក្ខគឺ ថ្ងៃ ១៣ កើតឬ ១៣ រោច ឯសាច់នោះឯងដោយហេតុទុកដាក់មិនល្អឆ្កែ ក៏ស៊ីអស់ទៅ ។ អ្នកធ្វើព្រះស្ងោយដល់ថ្ងៃឧបោសថហើយរកសាច់ពុំ បាន ក្រាន់តែចំអិនព្រះស្ងោយមានរសឆ្ងាញ់ផ្សេងៗ រួចហើយពុំហ៊ាន យកឡើងទៅលើប្រាសាទថ្វាយដល់ព្រះរាជាឡើយ ក៏ចូលទៅក្រាបទូល នាងទេវីថា បពិត្រព្រះទេពីម្ចាស់ ថ្ងៃនេះទូលព្រះបង្គំរកសាច់ពុំបាន ទូល ព្រះបង្គំពុំហ៊ានយកព្រះស្ងោយដែលពុំមានសាច់ទៅថ្វាយព្រះរាជាទេ បើ ដូច្នេះឲ្យទូលព្រះបង្គំធ្វើដូចម្ដេច? ។ នាងទេវីក៏ប្រាប់ឧបាយថា នែអ្នក នាយ មិនអីទេ បុត្តរបស់ខ្ញុំជាទីស្រឡាញ់សព្វព្រះរាជហឫទ័យនៃព្រះរាជា ណាស់ បើព្រះអង្គបានឃើញហើយមុខជាជាប់ព្រះទ័យតែនឹងក្រសាល

ប្រឡែងថើបដញ្ចប់ព្រះរាជបុត្តពុំដឹងព្រះអង្គថា ព្រះស្វាយមានសាច់ឬពុំ
មានសាច់ឡើយ ហើយចាំខ្ញុំស្អិតស្អាងព្រះរាជបុត្តឲ្យទៅអង្គុយលើព្រះ
ឧរុ (ភ្លៅ) ព្រះរាជាជាមុនសិន សឹមអ្នកយកព្រះស្វាយទៅថ្វាយក្នុង
វេលាដែលព្រះអង្គកំពុងត្រសាលលេងជាមួយនឹងព្រះរាជបុត្តចុះ ។ លុះ
ព្រះនាងទេវីនិយាយយ៉ាងនេះ រួចហើយក៏ប្រដាប់ស្អិតស្អាងបុត្តរបស់ខ្លួន
ដោយគ្រឿងស្អាងជាបិលន្ធនកុមារ រួចនាំយកទៅថ្វាយព្រះរាជា ៗ ទ្រង់
ឲ្យអង្គុយនៅលើភ្លៅ ។ ឯអ្នកធ្វើព្រះស្វាយក៏បានឱកាសនាំយកព្រះ
ស្វាយ ទៅថ្វាយក្នុងពេលដែលព្រះរាជាកំពុងត្រសាលជាមួយនឹងព្រះ
រាជបុត្តនោះ ។ ព្រះរាជាកំពុងតែស្រវឹងសុរាខ្លាំង លុះទ្រង់ទតទៅពុំ
ឃើញមានសាច់ក្នុងចានព្រះស្វាយ ក៏ទ្រង់ត្រាស់សួរថា វ៉ឺនាយព្រះ
ស្វាយ ចុះឯណាសាច់? ។ នាយព្រះស្វាយក្រាបបង្គំទូលថា
សូមទ្រង់ព្រះមេត្តាប្រោសថ្ងៃនេះជាថ្ងៃឧបោសថ ទូលព្រះបង្គំរកសាច់ពុំ
បាន ព្រោះគេមិនសម្លាប់សត្វ ។ ព្រះរាជាត្រាស់ថា "អើរុំ! អម្បាល
ប្រហែលអញហើយនៅតែគេរកសាច់ឲ្យបានដោយកម្រទៀត" ត្រាស់
តែប៉ុណ្ណោះហើយ ក៏ចាប់មួលកព្រះរាជបុត្តសំឡាញ់ដែលអង្គុយនៅលើ
ព្រះឧរុព្រះអង្គ ទាល់តែក្ស័យជីវិត ហើយបោះទៅឲ្យអ្នកធ្វើព្រះស្វាយ
ត្រាស់ថា ចូរឯងយកទៅចំអិនមកឲ្យអញជាឆាប់ៗ ។ អ្នកធ្វើព្រះ
ស្វាយបានយកទៅចំអិនរួចយកមកថ្វាយព្រះរាជា ៗ ក៏ទ្រង់សោយព្រះ
ស្វាយ ជាមួយនឹងសាច់បិយបុត្តរបស់ព្រះអង្គក្នុងកាលនោះទាល់តែ
អស់ទៅ ។ ដោយហេតុតែខ្លាចអំណាចបារមីព្រះរាជាដែលហួស

ប្រមាណ ពុំមានទេវតាណាម្នាក់ហ៊ានកន្ទក់កន្ទេញក្រាបទូលរឿងនោះសោះឡើយ ។ ឯព្រះរាជាលុះសោយស្រេចហើយក៏ចូលទៅកាន់ទីព្រះបន្ទំផ្ទំស្កប់ស្កល់ ដល់វេលាព្រឹកព្រាងបច្ចូសសម័យទ្រង់តើនឡើងស្វាងសេចក្តីស្រវឹងផឹងព្រះអង្គហើយ ទ្រង់ត្រាស់ទីងនាងទេវីថា ចូរនាងយកព្រះរាជបុត្រមកឲ្យយើង ។ គង់កាលនោះសោកនាងទេវីក៏ស្រក់ទឹកព្រះនេត្រា អាក់អួលកន្ទក់កន្ទេញ ចូលទៅក្រាបទៀបព្រះបាទានៃព្រះរាជា ។ ឃើញដូច្នោះហើយ ទ្រង់ត្រាស់សួរថា ចុះនាងកន្ទក់កន្ទេញអ្វីនាង? ។ នាងទេវីក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោសពីថ្ងៃម្សិលម៉ិញព្រះអង្គសម្លាប់ព្រះរាជបុត្រ ហើយចំអិនសោយជាមួយនឹងព្រះស្ងោយទៅហើយ ។ ព្រះរាជាឮហើយក៏ទ្រង់ព្រះកន្សែងសោកស្តាយព្រះរាជបុត្រសុតព្រះទ័យកើតសេចក្តីសង្វេគ ទើបពិចារណាឃើញថា "វិយោគទុក្ខនេះ កើតឡើងដល់យើងព្រោះតែផឹកសុរា" លុះទ្រង់ឃើញទោសផឹកសុរាហើយ ក៏ទទួលតាំងយកកំទេចដីជិតព្រះកន្ត្រាតាំងព្រះចិន្តាបេថ្កាជាតាំងពីថ្ងៃនេះទៅ បើយើងនៅមិនទាន់បានសម្រេចព្រះអរហត្តត្រឹមណាទេ យើងក៏នឹងមិនផឹកសុរាដែលជាគ្រឿងធ្វើឲ្យវិនាសយ៉ាងនេះត្រឹមនោះដែរ ។ តាំងពីដើមតាំងពីកាលនោះមក ព្រះរាជានោះក៏លែងសោយទឹកស្រវឹងទៅ ។

បពិត្រព្រះមហារាជ អាស្រ័យហេតុនេះឯងបានជាទូលព្រះបង្គំពុំទទួលព្រះរាជទានទឹកស្រវឹង ។

ព្រះរាជាទ្រង់ត្រាស់សួរតទៅទៀតថា អើឆត្តបាណី សំឡាញ់ ចុះអ្នកឃើញអារម្មណ៍ដូចម្ដេចបានជាអ្នកពុំមានសេចក្ដីស្រឡាញ់ ? ។

នាយឆត្តបាណីកាលដែលនឹងក្រាបទូលហេតុដែលខ្លួនពុំមានសេចក្ដីស្រឡាញ់ឲ្យព្រះរាជាទ្រង់ព្រះសណ្ដាប់នោះ បាននាំយកនូវអតីតនិទានរបស់ខ្លួនដោយព្រះគាថាមួយបទថា

កិតវាសោ នាមាហំ រាជា បុត្តោ បច្ចេកពោធិ មេ
បត្តំ ភិន្ទិត្វា ចវិតោ និស្នេហោ តស្ស ការណាតិ ។

(សូមទ្រង់ព្រះមេត្តាប្រោស) ទូលព្រះបង្គំកើតជាព្រះរាជាឈ្មោះកិតវាសៈ ព្រះរាជបុត្ររបស់ទូលព្រះបង្គំបានបោកបំបែកបាត្ររបស់ព្រះបច្ចេកពោធិ ហើយក៏ច្យុតស្លាប់ទៅ ព្រោះហេតុតែបុត្រវិយោគទុក្ខនោះ បានជាទូលព្រះបង្គំពុំមានសេចក្ដីស្រឡាញ់ ។

សេចក្ដីពិស្ដារនៃរឿងនេះថា បពិត្រព្រះមហារាជ កាលពីដើមទូលព្រះបង្គំកើតជាព្រះរាជាឈ្មោះកិតវាសៈ សោយរាជ្យនៅក្នុងក្រុងពារាណសី ។ ព្រះរាជានោះមានព្រះរាជបុត្រមួយអង្គ កាលដែលព្រះរាជបុត្រនោះទ្រង់សម្ភព (ប្រសូត) មក ពួកព្រាហ្មណ៍អ្នកទាយលក្ខណៈបានឃើញលក្ខណៈព្រះរាជបុត្រនោះហើយក៏ក្រាបទូលព្រះរាជាថា បពិត្រព្រះមហារាជ ព្រះរាជកុមារនេះបើពុំមានទឹកសម្រាប់សោយទេនឹងក្ស័យព្រះជន្មពុំខាន ។ ព្រះរាជបុត្រនោះព្រះនាម ទុដ្ឋកុមារ លុះចំរើនវ័យបានដឹងក្ដីឡើងកាលណា ព្រះរាជាបានតាំងឲ្យធ្វើជាឧបរាជ ។ ព្រះរាជាទ្រង់សព្វព្រះហឫទ័យនឹងព្រះរាជកុមារនោះណាស់ តែងយាងនាំបណ្ដើរ

ពីមុខពីក្រោយគ្រសាលលេងជាធម្មតា ។ ដោយខ្លាចក្រែងព្រះរាជកុមារនោះក្ស័យព្រះជន្មព្រោះពុំមានទឹកសម្រាប់សោយ ព្រះរាជាទ្រង់ឲ្យជីកស្រះបោក្ខរណីខាងក្នុងព្រះនគរនៅប្របទ្វារទាំង ៤ ទិស ទឹងឲ្យជីកក្នុងទីផ្សេង ៗ ជាច្រើនទៀត មិនតែប៉ុណ្ណោះទ្រង់ត្រាស់ឲ្យធ្វើមណ្ឌបជាច្រើនត្រង់ទីមានផ្លូវត្រែឡែងកែងជាដើម ហើយឲ្យដំកល់ពាងទឹកទុកសម្រាប់នៅគ្រប់មណ្ឌបទាំងអស់នោះផង ។

មានថ្ងៃមួយ ព្រះរាជកុមារនោះទ្រង់ស្អិតស្អាងគ្រឿងប្រដាប់ហើយនៅវេលាព្រឹកទ្រង់យានទៅគ្រសាលឧទ្យាន ដល់ពាក់កណ្ដាលផ្លូវបានជួបនឹងព្រះបច្ចេកពុទ្ធមួយអង្គកំពុងនិមន្តមកពីទ្រង់បិណ្ឌបាត ។ អស់ពួកមហាជនដែលតាមហែហមព្រះរាជកុមារទៅនោះ លុះបានឃើញព្រះបច្ចេកពុទ្ធហើយ ក៏នាំគ្នាទៅថ្វាយបង្គំប្រណម្យអញ្ជលីហើយសរសើរតែកល់គ្នា ។ ឯព្រះរាជកុមារឃើញដូច្នោះហើយក៏មានព្រះចិន្ដាថា "មហាជនទាំងអម្បាលនេះសឹងមានដំណើរទៅជាមួយនឹងអញ ពុំសមបើនាំគ្នាទៅថ្វាយបង្គំប្រណម្យអញ្ជលីសរសើរ ចំពោះសមណៈត្រងោលនេះទៅវិញសោះ" ព្រះរាជកុមារនោះក្រោធខឹងហើយក៏យាងចុះអំពីដំរីចូលទៅរកព្រះបច្ចេកពុទ្ធហើយសួរថា នែសមណៈ លោកនិមន្តបិណ្ឌបាតបានអាហារដែរឬ? ។ — ថ្វាយព្រះពរបាន ។ កាលដែលព្រះបច្ចេកពុទ្ធប្រាប់ដូច្នេះហើយ ស្រាប់តែព្រះរាជកុមារនោះគញ្ចក់យកបាត្រអំពីព្រះហស្តព្រះបច្ចេកពុទ្ធបោកទៅលើផែនដី ហើយជាន់ឈ្លីញាំញីកំទេចទាំងភត្តាហារផង ។ ព្រះបច្ចេកពុទ្ធសំឡឹងមើលព្រះភក្ត្រព្រះរាជកុមារ

នោះដោយទឹកក្នុងព្រះទ័យថា ឱ សត្វនេះវិនាសហើយតើហ្ន៎ ។ ឯព្រះរាជកុមារក៏និយាយទៅរកព្រះបច្ចេកពុទ្ធវិញថា នែសមណៈ យើងជាព្រះរាជបុត្ររបស់ព្រះបាទ កិតវាសៈ ព្រះនាមទុដ្ឋកុមារ លោកខឹងខឹងយើងហើយបើកភ្នែកសំឡក់មើលយើងប៉ុនខឹងធ្វើយើងយ៉ាងម៉េច? ។

ឯព្រះបច្ចេកពុទ្ធលុះបានឃើញបាត្របែកខ្ទេចខ្ទីអស់ហើយ លោកក៏ហោះទៅតាមអាកាសវេហាស៍ ទៅកាន់ញកភ្នំនន្ទមូលកបពិតជិតព្រៃហិមវន្តទិសខាងជើង ។ ឯបាបកម្មនោះឯងក៏ឆេះរោលរាលដល់ព្រះរាជកុមារក្នុងខណៈនោះភ្លាម ព្រះរាជកុមារមានសរីរៈក្តៅក្រហាយដូចជាគេយកទៅប្រកក្នុងហឹប ស្រែកថាក្តៅណាស់ៗ ហើយក៏ដួលនៅក្នុងទីនោះភ្លាម ។ ឯទឹកទាំងអម្បាលម៉ានដែលមាននៅក្នុងស្រះជាដើមនោះៗ ក៏រីងអស់ទៅ ប្រឡាយទឹកទាំងឡាយដែលហូរទៅកាន់ស្រះនោះៗទៀត ក៏រីងស្ងួតហួតហែងអស់ទៅ ឯព្រះរាជកុមារក៏ដល់នូវក្ស័យជីវិតក្នុងទីនោះភ្លាមហើយទៅកើតក្នុងអវីចិនរក ។

រីឯព្រះរាជាសោកកាលបើបានជ្រាបថាព្រះរាជបុត្រព្រះអង្គក្ស័យព្រះជន្មដូច្នោះហើយ ទ្រង់ក៏ខ្វួលក្តុលក្តៅសោយសោកព្រោះបុត្រវិយោគមកគ្របសង្កត់ ទើបកំណត់ព្រះទ័យពិចារណាថា សេចក្តីសោយសោករបស់យើងនេះកើតឡើងព្រោះតែបុត្រដែលជាទីស្រឡាញ់ ប្រសិនបើសេចក្តីស្រឡាញ់ពុំមានដល់យើងទេ សេចក្តីសោយសោកក៏ពុំកើតមានឡើយ ទើបទ្រង់អធិដ្ឋានតាំងប្រាថ្នាថា តាំងពីថ្ងៃនេះទៅសេចក្តីស្រឡាញ់ចំពោះវត្ថុអ្វីនីមួយ ទោះមានវិញ្ញាណក្តី ឥតវិញ្ញាណក្តីកុំបីកើតមានដល់

យើងឡើយ ។ តាំងពីកាលនោះមក ព្រះរាជានោះក៏លែងស្រឡាញ់របស់ដទៃ ។

បពិត្រព្រះមហារាជ អាស្រ័យហេតុនេះឯងបានជាទូលព្រះបង្គំពុំមានសេចក្ដីស្រឡាញ់ ។

ព្រះរាជាទ្រង់ត្រាស់សួរតទៅទៀតថា អើឆត្តបាណីសំឡាញ់ ចុះអ្នកឃើញអារម្មណ៍ដូចម្ដេចបានជាអ្នកមិនចេះក្រោធខឹង ? ។

នាយឆត្តបាណី កាលដែលនឹងក្រាបទូលហេតុដែលខ្លួនមិនចេះក្រោធខឹងថ្វាយព្រះរាជាទ្រង់ព្រះសណ្ដាប់នោះ បាននាំយកនូវអតីតនិទានរបស់ខ្លួនដោយព្រះគាថាមួយបទថា

អរកោ ហុត្វា មេត្តចិត្តំ សត្ត វស្សានិ ភាវយឹ
សត្តកប្បេ ព្រហ្មលោកេ តស្មា អកោធនោ អហន្តិ ។

(បពិត្រព្រះមហារាជ) ទូលព្រះបង្គំកើតជាតាបសឈ្មោះអរកៈ បានចំរើនមេត្តាចិត្តអស់ ៧ ឆ្នាំ បានទៅកើតក្នុងព្រហ្មលោកអស់ ៧ កប្បដែរ ព្រោះហេតុនោះបានជាទូលព្រះបង្គំពុំចេះក្រោធខឹង ។

សេចក្ដីពិស្ដារនៃរឿងនេះថា បពិត្រព្រះមហារាជ កាលពីដើមទូលព្រះបង្គំកើតជាតាបសឈ្មោះអរកៈ បានចំរើនមេត្តចិត្តអស់ ៧ ឆ្នាំ បានទៅកើតក្នុងព្រហ្មលោកអស់ ៧ សំវដ្ដវិវដ្ដកប្បដែរ បានជាទូលព្រះបង្គំពុំចេះក្រោធខឹង ព្រោះបានសាងសន្សំបុណ្យមេត្តាភាវនាមកអស់កាលជាយូរអង្វែងយ៉ាងនេះឯង ។

កាលបើនាយឆត្តបាណីខ្ទាទ់ប្រកេស ក្រាបទូលអំពីអង្គទាំង ៤ របស់

ខ្ញុំយ៉ាងនេះហើយ ព្រះរាជាក៏ទ្រង់ឲ្យឥង្គិតសញ្ញា (ឧបាយឲ្យស្គាល់ហេតុមានព្រិចភ្នែកជាដើមឬឲ្យសំឡៀប) ដល់ពួករាជបរិស័ទ ។

ខណៈនោះឯង អស់ទាំងអាមាត្យនិងព្រាហ្មគហបតីជាដើម នាំគ្នាក្រោកប្រញាប់ឡើងស្រែកសន្ធាប់ទៅរកសេនាបតីថា "វ៉ីអាស៊ីសំណូក អាចោរកំណាច អាឯងព្រោះតែមិនបានសំណូក បានជាប៉ងនឹងសំឡាប់ធម្មទ្ធជបណ្ឌិត" លុះពោលដូច្នេះហើយ ក៏ព្រួតគ្នាចាប់ដៃចាប់ជើងកាឡក-សេនាបតី នាំចុះចេញអំពីព្រះរាជនិវេសនដ្ឋាន វាយបំបែកក្បាលដោយដុំថ្មនិងដំបងដែលកាន់នៅដៃគ្រប់គ្នាពាល់តែក្ស័យជីវិត ហើយចាប់ជើងអូសយកទៅចោលលើគំនរសម្រាម ។

តាំងពីថ្ងៃនោះទៅ ព្រះរាជាក៏ទ្រង់សោយរាជ្យ ប្រកបដោយធម៌ លុះទ្រង់ទិវង្គតទៅក៏បានទៅកើតតាមយថាកម្ម ។

លុះព្រះសាស្តាទ្រង់សំដែងព្រះធម្មទេសនានេះចប់ហើយ ទ្រង់ប្រជុំជាតកថា: កាលនោះ កាឡកសេនាបតី គឺទេវទត្ត, ឆត្តបាណិកប្បកៈ គឺសារីបុត្ត, ឯធម្មទ្ធជបណ្ឌិត គឺអង្គតថាគត ។

(ជាតកនេះ ទ្រង់សំដែងប្រារព្ធ អំពីទេវទត្ត ព្យាយាមនឹងសំឡាប់ព្រះអង្គកាលដែលទៅជាពោធិសត្វ តែពុំអាចនឹងធ្វើពោធិសត្វសូម្បីឲ្យគ្រាន់តែតក់ស្លុតបានឡើយ) ។ ចប់ ។

## ផ្នែកអក្សរសាស្ត្រ

# ពិធីបំបួសនាគជាតិភូមា

ដោយ ម៉ូង - ហ្ទិន - អ៊ូង

( Les cérémonies d'initiations birmanes
par Maung Htin Aung)

អ្នកប្រែរៀបរៀង: ញ៉ែម - ឌឹម លេខាធិការនៅពុទ្ធសាសនបណ្ឌិត្យ

---

សព្វថ្ងៃនេះ នៅប្រទេសភូមាមានពិធីបុណ្យពីរយ៉ាងដែលមានរបៀបប្រហែលគ្នានឹងបុណ្យបំបួសនាគដែរ គឺពិធីស៊ិនយូ (Shinbyu) ១, ពិធីមង្គលបោះត្របៀក ១ ។ ពិធីស៊ិនយូ ធ្វើនៅពេលដែលយុវជនចូលបួសជាសាមណេរ ។ ពិធីបោះត្របៀក ធ្វើនៅពេលយុវនារីជាតិភូមាបោះត្របៀកពាក់ការ ។

ពួកពុទ្ធិកយុវជន ត្រូវចូលបួសជាសាមណេរ មុនពេលដែលមានអាយុគ្រប់ការ ។ នៅបច្ចុប្បន្នកាលនេះ យុវជនចូលកាន់ផ្នួសជាសាមណេរ ត្រូវមានអាយុពី ៥ ឆ្នាំទៅ ១៥ ឆ្នាំ ។ នៅពេលនោះ គេមានប្រគេនចង្ហាន់លោក, អញ្ជើញបងប្អូនញាតិមិត្តជិតឆ្ងាយមកជាអធិបតី ។ ឱកាសធ្វើបុណ្យបំបួសនាគនេះហើយ ជាឱកាសប្រកបទៅដោយសុខសួស្ដីជោគជ័យមង្គលនឹងដោយសេចក្ដីរុងរឿង ។ មានតូរ្យតន្ត្រីលេងបទចរលីលា, ព្រោះបណ្ដាបទភ្លេងជាតិភូមា បទចរលីលាជាបទមានចង្វាក់វែង ៗ ហើយរុងរឿងផង ។ នៅពេលនោះ យុវជនត្រូវកោរក្បាល រួចក្រោយពេលដែលគេសូត្រធម៌បំបួសចប់ អ្នកនោះឯងឡើងពេញជាសាមណេរ

(novice) ។ មកដល់ត្រង់នេះ ទើបបុណ្យនេះ មានសភាពដូចគ្នានឹងបុណ្យបំបួសនាគក្នុងព្រះពុទ្ធសាសនាមែន ។ គឺថា កាលណាគ្រហស្ថផ្លាស់ភេទទៅជាបព្វជិតគេត្រូវធ្វើពិធីបុណ្យជាពីរផ្នែក : មួយផ្នែកគឺបុណ្យបញ្ចូលគ្រហស្ថឲ្យទៅជាសាមណេរ, មួយផ្នែកទៀត គឺបុណ្យបំបួសសាមណេរឲ្យទៅជាភិក្ខុ ។ ជាតិកួមាបានយកបុណ្យផ្នែកទីមួយ នៃព្រះពុទ្ធសាសនានេះ ទៅភ្ជាប់នឹងបុណ្យស៊ុនយូ ។ ឯពិធីខាងក្រោយ មានក្រឹត្យវិន័យតឹងតែងជាងបុណ្យស៊ុនយូ ។ បុគ្គលណាក៏ដោយពុំអាចអនុញ្ញាតឲ្យជនដែលពុំទាន់មានអាយុគ្រប់ ២០ ឆ្នាំឧបសម្បទាជាភិក្ខុបានឡើយ ។

ដូច្នេះ សឲ្យឃើញថាមង្គលបុណ្យទាំងឡាយរបស់ជនជាតិកួមាមានស៊ុនយូជាដើម បើគេពិនិត្យមើលបែបផែនខាងក្រៅនៃបុណ្យឃើញថាជាបុណ្យពុទ្ធសាសនាមែន ។, ប៉ុន្តែនៅក្នុងខ្លះមានរបៀបរៀបចំប្លែកដែលជារបៀបធ្លាប់មានតាំងពីមុនពុទ្ធសម័យមកទៀត គឺថា យុវជនត្រូវនៅផ្ទះយ៉ាងតិចត្រឹមប្រាំពីរថ្ងៃ ក្រោមការត្រួតត្រាយ៉ាងតឹងរ៉ឹងនៃបង ៗ មុនថ្ងៃធ្វើបុណ្យ, ព្រោះគេយល់ថាខ្មោចបិសាច មានចិត្តប្រណែននឹងអនាគតកិត្តិគុណនៃយុវជន, ហើយរកមុខជាធ្វើឲ្យយុវជននោះបាក់ដៃបាក់ជើង ឬរបួសខាននៅបំពេញកិច្ចកុសលនេះ ។ បន្ទាប់មក នៅព្រឹកថ្ងៃបុណ្យយុវជនត្រូវតែងតួជាស្តេច, ប៉ាំងក្លស់មាស, ជិះសេះ រួចគេដង្ហែព័ទ្ធជុំវិញទីក្រុងឬភូមិ ។ នៅពេលដែលក្បួនហែបានចូលទៅក្នុងភូមិយ៉ាងសប្បាយ, ពួកកម្លោះៗ ដែលជួយដើរដង្ហែក៏ស្រែកថា: "ស៊ីវ" (Shew) បានសេចក្តីថា: "ត្រជាក់ត្រជុំ" ។ ជារឿយ ៗ អ្នកដើរមុខក្បួនស្រែកថា:

- សូមឲ្យស្រែចំការទាំងឡាយមានទឹកបរិបូណ៌ ។
យុវជនទាំងឡាយក៏ស្រែកព្រមគ្នាឡើងថា " ស៊ីវ "

- សូមឲ្យជ្រោះព្រែកមានទឹកបរិបូណ៌ ។

- " ស៊ីវ " ។

- សូមឲ្យទឹកដោះម្ដាយនៃយុវជនអ្នកបួសនោះមានទឹកបរិបូណ៌ ។

- " ស៊ីវ " ។

- សូមឲ្យទឹកដោះបងស្រីប្អូនស្រីនៃយុវជននោះមានទឹកបរិបូណ៌ ។

- " ស៊ីវ " ។

លុះក្បួនដង្ហែបានទៅដល់ផ្លូវចូលពីខាងកើត ឬ ខាងលិចភូមិ, គេត្រូវឈប់ប្រហែលប្រាំនាទី ។ នៅពេលនោះ ប្រុសកំឡោះត្រូវអង្គុយត្រង់ខ្នងហើយគ្មានធ្វើចលនាអ្វីទាំងអស់, ព្រោះគេទុកអ្នកនោះដូចជាអ្នកតាតាស់ស្រុក ។ មកដល់ត្រង់នេះ ផ្នែកពិធីនេះហៅថាជាពិធីគោរពអ្នកតាណាត (Nat) ។

បន្ទាប់មក គេក៏ដង្ហែប្រុសនោះតម្រង់ទៅផ្ទះឪពុកម្ដាយ ។ ក្រោយពេលដែលយុវជនទៅដល់ផ្ទះ កំឡោះៗ ក៏នាំងបបួលគ្នាឃ្លាំចាំលួចយកប្រុសនោះ, បើកាលណាគេលួចបានហើយ គេក៏នាំប្រុសនោះយកទៅលាក់ទុក លុះត្រាតែឪពុក - ម្ដាយនឿយណាយនឹងអំពើនេះក៏យកលុយទៅលោះកូនយកមកវិញ ។

លុះប្រទេសភូមាត្រូវរួបរួមគ្នាជាមួយនឹងចក្រភពអង់គ្លេស, ការផ្លាស់ប្ដូរផ្សេងៗ ក៏កើតមានឡើងនៅគ្រប់សង្គម ។ ពិធីស៊ិនយូក៏ក្លាយ

ទៅជាបុណ្យសក្ដិមួយយ៉ាងជាក់ច្បាស់ គេតែងធ្វើឡើងនៅពេលដែលកូនក្មេងមានអាយុ ១៥ ឬ ១៦ ឆ្នាំ ។ នៅសម័យនោះ វត្តទាំងឡាយនៅក្នុងភូមិ សម្រាប់ព្រះសង្ឃគង់នៅផង សម្រាប់ធ្វើជាសាលារៀនផង ។ ដូច្នេះ យុវជននោះមិនមែនជាក្មេងដទៃពុំដែលស្គាល់វត្តក៏នោះឡើយ ។ នៅប្រទេសភូមា ក្មេងអាយុ ៦ ឆ្នាំ ត្រូវទៅនៅវត្ត, ពេលថ្ងៃ រៀនមេទន្ទេញ, ពេលព្រឹកតាមលោកបិណ្ឌបាតតាមវិថីក្នុងភូមិ, ពេលល្ងាចលេងប្រឡែងជាមួយនឹងក្មេងឯទៀត ក្នុងទីធ្លាវត្ត ។ ពេលរៀបពិធីធ្វើបុណ្យបួសគឺជាពេលដែលក្មេងឈប់ទៅសាលា, ឬពេលក្មេងបញ្ចប់ការសិក្សា ។ ពួកកញ្ញាទាំងឡាយ ពុំបានចាប់ភ្លឹកដល់បុរសរបៀបនោះសោះ ស្រាប់តែឃើញរៀបពិធីស៊ីនយូតែម្តង, ប៉ុន្តែឥឡូវនេះមិនមែនមានកញ្ញាតែម្នាក់ពីរទេ ដែលរង់ចាំមើលផ្លូវបុរសបែបនេះដែលត្រឡប់មកពីវត្តវិញ ព្រោះយុវតីមានសេចក្តីសង្ឃឹមផ្សេងៗ ដូចមានទំនុកច្រៀងមួយនៅជាប់ដល់សព្វថ្ងៃ ដូចតទៅនេះ:

" នៅមុខគេហស្ថាននារី
" មានមែកផ្កាសត្ថា - ភូ (Sattha-phu) មួយពីរកំពុងផ្កា
" សត្វសេកទាំងឡាយខំខ្វល់ខ្វាយចឹកពាំស៊ី ។
" ឱសត្វសេកពណ៌លឿងចុំ ! ខ្ញុំសូមអង្វរឲ្យអ្នកទុកផ្កានេះខ្លះ
" ពីព្រោះបុប្ផានេះត្រូវនៅចាំប្រុសស្នេហ៍ខ្ញុំត្រឡប់មកពីវត្តវិញ
" នៅពេលនោះខ្ញុំនឹងបេះផ្កាទៅចងលំអគាត់ " ។

យុវជនកាលធ្វើបុណ្យរួច ក៏ទៅបួសជាសាមណេរអស់រយៈមួយ ឬ

ពីរខែ, លុះសឹកមកជាគ្រហស្ថ, អ្នកក៏ធ្វើខ្លួនដូចជាយុវជនឯទៀត ៗ ដែរ គឺដើរលេងសប្បាយហ៊ឺហាតាមធម្មតា ៗ ស្រីជំទង់ៗ ក៏លបលួចស្រឡាញ់បណ្ឌិតថ្មីនេះណាស់ ៗ ចាប់ពីពេលនោះមក បុរសក៏ខំរកស៊ីចិញ្ចឹមជីវិតខ្លួន, បងៗ ក៏បង្ខំឲ្យរកប្រពន្ធកូន ដើម្បីនឹងបង្កើតគ្រួសារថ្មី ៗ ប៉ុន្តែ បើធៀបទៅនឹងក្មេងនៅក្នុងភូមិជាមួយគ្នា ឃើញថាបុរសនេះនៅវ័យក្មេងណាស់ គួរតែទៅបួសម្តងទៀត ៗ

បើសិនជាពិធីស៊ុនយូ ជាគ្រឿងសំគាល់ប្រាជ្ញានឹងគំនិតមារយាទរបស់យុវជននោះ ពិធីទីពីរ ក៏ជាគ្រឿងសំគាល់នៃសេចក្តីក្លាហាននឹងសេចក្តីជាប់ចិត្តរបស់គេសុខចិត្តទៅធ្វើជាបព្វជិត ៗ ពិធីទីពីរនេះ គឺពិធីសាក់ខ្លួន ៗ ជាតិភូមាមានរបៀបសាក់ពីរយ៉ាង យ៉ាងសាក់ជាការលំអ, យ៉ាងសាក់មន្តអាគម គឺថា ទីមួយជាការបង្ហាញនូវអត្តពល, ទីពីរជាការបង្ហាញនូវការខ្លាំងពូកែកាប់មិនមុតដុតមិនឆេះ ៗ បំពោះពួកកំឡោះ សាក់លើកដំបូង គ្រាន់តែជាការលំអនឹងជាការនិយមរបស់សង្គមប៉ុណ្ណោះ, ឯសាក់លើកទីពីរដែលនឹងមានធ្វើឡើងនៅពេលខាងក្រោយ ទើបពេញជាសាក់ប្រកបដោយមន្តអាគមមែន ៗ ការសាក់នេះបណ្តាលឲ្យឈឺចាប់ជាខ្លាំង យុវជនត្រូវខាំមាត់អត់ធ្មត់ទ្រាំមិនស្រែក ទោះឈឺយ៉ាងណាក៏ដោយ, ព្រោះថាបើសិនជាយុវជនភ្ញាត់មាត់ថ្ងូរ ឬស្រែក ពួកកឿនដែលនៅជុំវិញមុខជានឹងសើចគិលឡើង ហើយមុខជានឹងនិយាយកំប្លុកកំប្លែងធ្វើត្រាប់សើចលេងអស់ពេលជាច្រើនថ្ងៃ ៗ

ចុះហេតុអ្វីបានជាយុវជនចាំបាច់ស្លៀកពាក់ដូចស្តេច ចាំបាច់ជិះលើ

ខ្លះសេះនៅពេលធ្វើពិធីស៊ិនយូ? មុននឹងឆ្លើយនូវបញ្ហានេះ, យើងសូមបញ្ជាក់ឲ្យដឹងថា បើពួកយុវជនជាតិកូមាជិះសេះនៅពេលដែលស្តេចកំពុងគង់លើសេះដែរ, ឬតែងខ្លួនដូចជាស្តេចដែរនោះៗ មិនត្រឹមតែប្លែកភ្នែកអ្នកដទៃទេ គឺថែមទាំងខុសនឹងច្បាប់អាណាចក្រទៀតផង ។ សង្គមជាតិកូមាជាសង្គមគ្មានវណ្ណៈ, គ្មានពួក, ជាសង្គមមានស្តេចគ្រងរាជ្យនឹងគណៈរដ្ឋមន្ត្រីសម្រាប់ត្រួតត្រាកិច្ចការផ្សេង ៗ ។ ប៉ុន្តែ ព្រះមហាក្សត្រិយ៍ប្រទេសកូមាចូលជ្រៀតជ្រែកក្នុងការរដ្ឋបាន លុះត្រាតែមានបរិយាកាសស្អុះស្អាប់រវាងព្រះអង្គនឹងគណៈរដ្ឋមន្ត្រី, ឬរវាងគណៈរដ្ឋមន្ត្រីនឹងប្រជារាស្ត្រ ។ ដោយហេតុនេះហើយ, បានជាសំលៀកបំពាក់ស្តេចនឹងសំលៀកបំពាក់អ្នកហែហមមានពណ៌ខុសគ្នា ។ កាលណាស្តេចយាងទៅគង់ប្រថាប់មុខប្រជាជន, ព្រះអង្គឥតត្រូវការគង់លើសេះ ឬ ដំរី ឬ លើវមាសឡើយ ព្រះអង្គយាងដោយព្រះបាទផ្ទាល់ ទ្រង់គ្រឿងដោយពាក់កងមាស, កាន់ដាវរំលេចដោយក្បាច់របនាផ្សេងៗ, ពាក់ព្រះសុពណ៌បាទមាសជាសញ្ញានៃនគរ ។ មិនតែប៉ុណ្ណោះ មានមន្ត្រីបាំងខ្លស់ថ្វាយទៀត ។ នរណាមួយស្លៀកពាក់របៀបនេះនឹងត្រូវមានទោសឧក្រិដ្ឋ, លើកលែងតែយុវជនដែលត្រូវធ្វើពិធីស៊ិនយូ, នឹងពួកលេងល្ខោន ទើបមានច្បាប់អនុញ្ញាត ។

ដើម្បីនឹងដោះស្រាយសំនួរថា: ហេតុអ្វីបានជាយុវជនត្រូវស្លៀកពាក់ដូចស្តេចគ្រងរាជ្យ? ប្រជាជនកូមាបានឆ្លើយថា បានជាយុវជនធ្វើដូចនេះព្រោះយុវជនចង់ធ្វើតាមព្រះសិទ្ធត្ថ: ដែលជាស្តេចមួយព្រះអង្គ

បានតែហោលដីភោពុងរឿងឧត្តុងឧត្តមដើម្បីទៅបំពេញផល, លុះត្រាតែបានត្រាស់ជាព្រះពុទ្ធ ។ ហេតុនេះ យុវជនដែលស្លៀកពាក់ដូចស្តេចគ្រងកជ្យ គឺជាអ្នកលេងតួរឿងនៃព្រះសិទ្ធត្ថៈ ។ ប៉ុន្តែ សេចក្តីអធិប្បាយមកប៉ុណ្ណោះ គឺជាគំនិតកើតមានមកខាងក្រោយទេ ព្រោះគេចង់ញាំងបុណ្យព្រះពុទ្ធសាសនាមែនៗ ឱ្យទៅជាបុណ្យមុនពុទ្ធសម័យ ។ ដូច្នោះបានជានៅប្រទេសភូមា គេមានធ្វើបុណ្យព្រះពុទ្ធសាសនាជាច្រើនដែលមានលំនាំទៅតាមបុណ្យដែលកើតឡើងមុនពុទ្ធសម័យទៅទៀត ។

ពាក្យ "ស៊ុន" ប្រែថា "ភិក្ខុ" ប៉ុន្តែបើប្រែថា គ្រូ, នាយ, ចៅហ្វាយ ឬ ម្ចាស់ផែនដី ក៏បាន ។ ដោយពិត បើតាមក្បួនអក្ខរាវិរុទ្ធសព្វថ្ងៃនៃពាក្យ ស៊ុន, អ្នកប្រាជ្ញភូមាបានបដិសេធពាក្យនេះថា មិនមែនមានន័យថាស្តេចផងទេ, គឺមានន័យតែមួយគត់គឺ "ភិក្ខុ" ។ ប៉ុន្តែអក្ខរាវិរុទ្ធនេះជាពាក្យទើបតែនឹងបង្កើតថ្មី, បើតាមសំដីគេនិយាយធម្មតា, ពាក្យនេះមានន័យថា ភិក្ខុ ក៏បាន, ស្តេច ក៏បាន ។ ដូចនេះ ពាក្យ "ស៊ុនយូ" បានសេចក្តីថា "ធ្វើជាភិក្ខុ, ធ្វើជាស្តេច" ។ យុវជនដែលទើបនឹងបួសរួចបានឈ្មោះថា "ស៊ុន-ឡុង" (Shin-Laung) គឺអ្នកដែលចង់ទៅជាភិក្ខុ ឬអ្នកដែលចង់ទៅជាស្តេច ។ អ្នកនិពន្ធបានអធិប្បាយរួចម្តងមកហើយថា: សង្គមភូមាគ្មានប្រកាន់វណ្ណៈ ប្រកាន់បក្សពួកទេ ។ ពិតមែនតែម្ចាស់ផែនដីនឹងរដ្ឋមន្ត្រីព្រះអង្គទ្រង់គង់, នឹងឋិតនៅខ្ពស់លើប្រជាជនទាំងអស់ ប៉ុន្តែប្រជាជនទាំងឡាយអាចសង្ឃឹមថាថ្ងៃណាមួយនឹងបានទៅជាស្តេចផែនដី ។ ម្យ៉ាងទៀត ដោយពួកមន្ត្រី

មហាក្សត្រសុទ្ធតែជាអភិជនជ្រើសតាំងឡើងដោយចំណេះប្រាជ្ញា, មិនមែនជ្រើសតាំងឡើងតាមពូជអំបូរនោះទេ, ហេតុនេះ ជនណាក៏ដោយឲ្យតែមានសមត្ថភាពគ្រប់គ្រាន់ ក៏អាចទៅជាអ្នកជាន់ខ្ពស់ម្នាក់សម្រាប់ដឹកនាំប្រជាជន ។ សៀវភៅប្រវត្តិសាស្ត្រកូមា (folklore) មាននិយាយពីសាវតារក្មេងកំសត់ទុគ៌តជាច្រើនដែលបានទៅជាស្ដេចផែនដី, និយាយពីពួកតែងសាវតារផ្សេង ៗ ដែលគ្មានជាប់ពូជអំបូរស្ដេចសោះ ក៏បានទៅជាស្ដេចផែនដីដែរ ។ មួយទៀត ក្នុងពង្សាវតារកូមា មាននិយាយថា ស្ដេចផែនដីត្រូវប្រជាជនបោះឆ្នោតរើសជាសាកល ។ របៀបនេះ មានធ្វើរហូតមកទល់នឹងការវិបល្លាសរបៀបគ្រប់គ្រងនៃអាណាចក្រកូមាក្នុង គ. ស. ១៨៨៦ ។ ដូច្នេះ កាលណាយុវជនកូមាណាមានវ័យគ្រប់ការ, យុវជននោះអ្នកផងអាចរំពឹងថាមុខជាបានទៅជាស្ដេចនគរខ្លួននៅពេលណាមួយ ។ ឯអាវុធសម្រាប់ស្ដេច ដែលគេពាក់នៅពិធីសុំនយូ ជានិមិត្តដែលគេសំគាល់បានថាកូនក្មេងមានវ័យគ្រប់ការហើយ ។

ពិធីធ្វើបុណ្យគោរពទេវតា, អារក្សបិសាច (ណាត) មានដើមកំណើតមុន ព. ស. ទៅទៀត ។ សព្វថ្ងៃនេះនៅក្នុងភូមិភាគជាច្រើននៃប្រទេសកូមាផ្នែកខាងលើ យុវជនឈប់ចង់គោរពអ្នកតា (ណាត) ឈប់គោរពរូបនាគពជហើយ ។ តែមុនពេលដែលអ្នកប្រាជ្ញ អាណាវរ៉ាតា (Anavratha) បានផ្សាយព្រះពុទ្ធសាសនាឲ្យទៅជាសាសនារបស់រដ្ឋពេញទី, ប្រជាជនកូមាគោរពប្រណិប័តន៍រូបតំណាងអ្នកតាណាត

ទឹងពស់នាគពជណាស់ ព្រោះគេទុករូបទាំង ២ នេះដូចជាទេវតា ឬជាព្រះរបស់គេ ។ នៅផ្លូវពីខាងកើតដែលចូលទៅកាន់ភូមិមួយ ៗ មានសង់រូបណាគជាឆ្មាំទ្វារទឹងរូបនាគពជ ពីព្រោះណាគមានកំណើតជាប់ទាក់ទងជាមួយទឹងនាគពជ ។ អំណើះពីអ្នកប្រាជ្ញអាណាវ៉ែតាទៅ, រូបនាគពជគំរលាយបាត់អស់ទៅ នៅសល់តែរូបណាគដែលជាប់ទាក់ទងលាយឡំនឹងព្រះពុទ្ធសាសនា ។ ក្រោយមក ដើម្បីទុកកន្លែងសង់វិហារនៅពីខាងកើតភូមិវិញ, រូបណាគឆ្មាំទ្វារកំលើកយកទៅសង់ពីទិសខាងលិចវិញ ។ ដោយហេតុតែរូបតំណាងនោះវិនាសទៅ, បានជាយុវជនត្រូវឈប់ឈរទ្រឹង ១ ស្របក់នៅផ្លូវចូលទៅក្នុងភូមិពីខាងកើត ដើម្បីធ្វើជាតំណាងរូបដែលគេបំបាត់ចោលនោះ ។

ពាក្យ "ស៊ីវ" ដែលពួកយុវជនតែងស្រែកនៅពេលដង្ហែស៊ិនយូ ជាពាក្យមានដើមកំណើតមកពីសំស្ក្រឹតថា ស្រី (SRI) ។ ពួកហោរ-សាស្ត្រណេ្ត ដែលបានចូលមកថ្វាយបង្គំស្តេចភូមាពីសតវត្សរ៍ទី ១ នៃ គ.ស. បានយកពាក្យនេះមកប្រើនៅគ្រប់ពេលរៀបធ្វើពិធីផ្សេងៗ តែដោយទៀងទាត់បំផុត គឺពេលអភិសេកស្តេចផែនដី ។ ពាក្យនេះបានសាយចេញពីផ្ទៃព្រះពជរាំង រហូតដល់យកទៅប្រើពាសពេញក្នុងពិធីស៊ិនយូ ហើយគេទុកពាក្យនេះជាពាក្យថ្លៃថ្នូរមានសិរីសួស្តីផង ។ ពួកហោរាសាស្ត្រណេ្ត បានកំណត់ថ្ងៃខែឲ្យជាតិភូមាធ្វើបុណ្យស៊ិនយូ ។ ហេតុដូច្នេះ គេអាចធ្វើបុណ្យស៊ិនយូបាន លុះណាតែពួកហោរាសាស្ត្របានគន់គូរកំណត់ពេលឲ្យជាមុនសិន ។

ពាក្យ "ស៊ីវ" មានន័យថា "ត្រជាក់ត្រជុំ" ប៉ុន្តែនៅក្នុងដំបន់រងស្ងួតខ្លះ នៃប្រទេសភូមាផ្នែកខាងលើ គឺអាណាចក្រនៃប្រជាជនដើមជាតិភូមា ដ៏សើមៗ ទឹងដីមានជីវជាតិ ពីដើមដូចម្តេច ឥឡូវនៅតែដដែល ៗ ពិធីស៊ិនយូតាមទំលាប់មក ច្រើនធ្វើនៅខែតាបូង (កុម្ភៈ, មីនា) នៃប្រក្រតិទិនភូមា គឺនៅពេលគេច្រូតកាត់ស្រូវ ដែលព្រះធរណីកំពុងហួតហែង ហើយគេសង្ឃឹមថា មុខជាទឹងមានភ្លៀងធ្លាក់នៅពេលប្រាំបួនឬដប់អាទិត្យក្រោយមក ៗ ដូច្នេះពាក្យ "ស៊ីវ" គឺជាសេចក្តីអង្វរបន់ស្រន់ឲ្យភ្លៀងធ្លាក់ ហើយពាក្យនេះក៏ទៅជាពាក្យទិព្វមួយតែងផ្តល់ផលប្រយោជន៍ឲ្យ ៗ

តាំងពីមុនកើតពង្សាវតារម្ល៉េះ, ស្រីៗ មានបោះត្រចៀកគ្រប់គ្នា, ប្រុសៗ ក៏មានធ្វើដូច្នោះដែរ ប៉ុន្តែមិនមែនជាទំនៀមទំលាប់ជាប់ខាតទួទៅនោះទេ ពួកខត្តិយវង្សទើបត្រូវតែបោះត្រចៀក: នេះជាការតម្រូវរបស់ស្តេច ៗ នៅក្នុងភូមិ ការបោះត្រចៀកឥតមានរៀបធ្វើពិធីអ្វីទេ, ប៉ុន្តែនៅក្នុងព្រះបរមរាជវាំង ពិធីនេះត្រូវតែមានជាការចាំបាច់ ៗ ក្សត្រិយ៍ទាំងឡាយ អាចរៀបអភិសេកឡើងសោយរាជ្យបាន លុះត្រាតែបានបំពេញពិធីនេះសិន ចំណែកស្តេចផែនដីត្រូវធ្វើពិធីនេះនៅមុនពេលអភិសេក ៗ តាមទំនៀមទំលាប់ស្តេច, គ្រួសារស្តុកស្តម្ភត្រូវធ្វើពិធីនេះនៅក្នុងព្រះរាជធានី មិនមែនធ្វើនៅតាមភូមិទេ ហើយកិច្ចនេះគ្រាន់តែប្រជុំនារីក្មេងអ្នកមានៗ ដែលមានត្រចៀកបោះនឹងម្ជុលមាស មកអង្គុយនៅមុខភ្ញៀវទាំងឡាយ ៗ ក្នុងពិធីនេះគ្មានជាប់ទាក់ទងនឹងសាសនា

ប៉ុន្តែក្រោយមក លុះអ្នកប្រាជ្ញអាណាវ៉ក់តា បាននាំលទ្ធិព្រះពុទ្ធ-សាសនាចូលមកផ្សាយក្នុងប្រទេសភូមា ។ ក៏ទទួលស្គាល់សាសនានេះតាមផ្លូវការដោយពិតប្រាកដ ។ រួចគេក៏សង្កេតឃើញមានធ្វើពិធីបបួសស្ត្រីដែរ ។ សាវតារមាននិយាយថា ពួកយុវនារី, មុននឹងរៀបការត្រូវបញ្ជូនទៅកន្លែងសមណៈអារីស (Aris) សិន, ព្រោះសមណៈនេះគេគ្រាន់តែយកឈ្មោះព្រះពុទ្ធមកធ្វើជាភស្តុតាងប៉ុណ្ណោះទេ តែគេបានប្រកាសខ្លួនគេជាមនុស្សខូចកាច ។ ពួកនេះប្រើច្បាប់ស្តេចត្រាញ់, ស្ត្រីណាមួយក៏ដោយមុននឹងការត្រូវទៅវិហារសិនដើម្បីជំរះចិត្តក្រមុំចេញ ។ ទំលាប់នេះហៅថាពិធីផ្កាដំបូង (Première fleur) ឬ ពិធីទៅព្រះវិហារ ។ ការនេះឃើញថាពិតមែន, តែបើតាមគំនិតខ្ញុំជាអ្នកនិពន្ធយល់ថាអំពើនេះជាសេចក្តីឃោសនានយោបាយនៃលោកអាណាវ៉ក់តាទេ ដើម្បីបំបាត់ពួកអារីសចោល ។

ពួកសមណៈអារីសរៀនអំពើអាបធ្មប់, ថ្វេចថ្វើហើយនឹងហោរាសាស្ត្រ ។ ឯសាសនារបស់គេ លាយឡំជាមួយនឹងព្រះពុទ្ធសាសនាបន្តិច ជាមួយនឹងកិច្ចការផ្សេងៗ នៃរូបអ្នកតានាគកជបន្តិច ហើយគេគោរពរូបភាពអារក្សបីសាចណាគបន្តិច ។ មិនតែប៉ុណ្ណោះ ពួកនេះធ្វើការជំទាស់នឹងលោកអាណាវ៉ក់តានឹងលទ្ធិព្រះពុទ្ធសាសនា ដែលគាត់បានយកមកផ្សាយ ។ គាត់ក៏គ្មានមធ្យោបាយអ្វីក្រៅពីធ្វើទុក្ខពួកនោះ ហើយនឹងចុះដៅក្នុងសាវតារនៃការជាន់ឈ្លីព្រះពុទ្ធសាសនានូវពួកកំណាចនោះ ។ ប៉ុន្តែពួកអារីសបានទៅជាចៅហ្វាយនៃប្រជាជនភូមា, ចៅហ្វាយដោយចរិយា

សាស្ត្រនិងសាសនាអស់ពេលជាច្រើនសតវត្សរ៍ ។ អត្ថបទសារតាវចិន នៅឆ្នាំ ៨០០ ក្រោយ គ.ស. បានអធិប្បាយពីអាណាចក្រផ្នែកខាងលើ នៃប្រទេសភូមា ដែលជាកំណើតសីលធម៌, កំណើតក្បួនហោរាសាស្ត្រ ហើយដែលជាកន្លែងមានព្រះវិហាររាប់រយ នៃព្រះពុទ្ធសាសនាសង់ នៅនោះ ។

អត្ថបទដដែលនេះ បានបន្ថែមសេចក្តីទៀតថា: ពួកកុមារីកាលអាយុបានប្រាំពីរឆ្នាំ ក៏កោរសក់ក្បាលរួចត្រូវទៅនៅវត្តដែរ ។

ការប្រតិបត្តិនេះរឹតតែមានអានុភាពឡើង លុះត្រាតែពួកអារីសត្រូវផ្លាស់ប្តូរយកពួកពុទ្ធសមណៈប៉ែកខាងត្បូងមកជំនួសវិញ, ប៉ុន្តែដោយសារតែការឃោសនាបាក់ដោតនិងការអន្តរាយផ្សេងៗ សមណៈទាំងនោះក៏កាន់វិន័យតឹងតែងលែងទទួលយុវនារីឲ្យនៅអាស្រ័យក្នុងវត្តទៀត ។

តាមសេចក្តីដែលខ្ញុំបានអធិប្បាយតាំងពីដើមមកនេះ, ចំពោះបុណ្យបំបួសនាគភូមា, ខ្ញុំសូមជូនយោបល់ផ្ទាល់ខ្លួនរបស់ខ្ញុំដូចតទៅនេះ ៖

១) ជាតិភូមាក៏ដូចជាជាតិឯទៀតដែរ មានពិធីធ្វើបុណ្យបួសជាប់ទាក់ទងជាមួយនឹងមន្តអាគមផង ជាមួយនឹងសាសនាផង ។ ប៉ុន្តែមានពិធីមួយទៀតសម្រាប់ស្ត្រីផ្សេង សម្រាប់បុរសផ្សេង, ពិធីនេះមានសភាពស្មុគស្មាញហើយក៏កំបុកកំប៉ុកណាស់ ដូចគ្នានឹងពិធីពីជំនាន់បុរាណសម័យ ។

២) ចំណែកពួកសមណៈអារីស នៅទីក្រុងប៉ាកាន (Pagan) ដោយសារការរុករានរបស់គេនៅក្នុងនគរភ្យូ (Phu) ពិធីជាន់ចាស់របស់

គេក៏បានកែប្រែទៅជាពិធីពុទ្ធសាសនា ៗ ប៉ុន្តែនៅមានពិធីសម្រាប់ស្ត្រីផ្សេងបុរសផ្សេងដដែល ៗ

៣) ក្រោយការសន្ធត់សន្ធិននៃសង្គម: អាវិស, ពិធីបំបួសស្ត្រីក៏បាត់ត្រឹមនោះទៅ ៗ ឯពិធីបោះត្រចៀក គ្រាន់តែនៅមានតែមិនរីកសាយទេ ចំណែកឯពិធីស៊ុនយូវិញទើបនៅជាប់ដល់សព្វថ្ងៃនេះ ៗ

---

## អ្នកមានទ្រព្យរាប់ជាអ្នកប្រសើរ

២ – សេចក្តីពិត, ក្នុងលោកនេះ កិច្ចការណាដែលមិនសម្រេចដោយទ្រព្យ កិច្ចការនោះមិនមានសោះឡើយ ព្រោះហេតុនោះ អ្នកមានប្រាជ្ញាគប្បីប្រសិទ្ធិទ្រព្យសម្បត្តិឲ្យកើតឡើងដោយសេចក្តីខ្នះខ្នែង ៗ

នរជនណាមានទ្រព្យ នរជននោះឈ្មោះថាមានមិត្រ, ឈ្មោះថាមានផៅពង្ស, ឈ្មោះថាជាមនុស្សក្នុងលោក, ឈ្មោះថាជាបណ្ឌិត ៗ

បញ្ចតន្ត្រៈ

កណ្ឌទី ២២

# ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នករាជការឆ្លាសបើបានអាន
នឹងបេះឧបាយកលបំណាន
ទាំងមានសន្ដានស្នេហាជាតិ ។

គួនអ៊ូបានស្ដាប់កំព្រិះរិះយូរណាស់ លុះយល់ឃើញត្រូវក៏ឆ្លើយថា អ្នកនិយាយនោះគួរហើយ ឯទោសដែលមាន ៣ ប្រការលើខ្លួនខ្ញុំនោះ អ្នកនឹងឲ្យខ្ញុំធ្វើយ៉ាងម្ដេច? ។ គៀវលៀវឆ្លើយថា "មហាឧបរាជឲ្យទាហានឡោមព័ទ្ធអ្នកជាច្រើនត្រួតណាស់ បើអ្នកមិនសុំក្របូលទៅផងទេ ឃើញជាជីវិតអ្នកនឹងអន្តរាយក្នុងគ្រានេះជាអសារឥតប្រយោជន៍ សុំឲ្យអ្នកទៅនៅនឹងមហាឧបរាជសិនចុះ អ្នកនឹងបានប្រយោជន៍ ៣ ប្រការ:

ប្រការ ១— ដែលអ្នកបានស្បថស្បាន់ទុកនឹងឡៅពី, គៀវហ៊ុយថា នឹងជួយគ្នាទំនុកបំរុងផែនដី សេចក្ដីសត្យក្នុង១នេះ ក៏នឹងបានគង់នៅឋិតថេរបេរកាលតទៅ ។

ប្រការ២.— ខ្លួនអ្នកក៏នឹងបានទៅពិភក្ដិរក្សាបងថ្លៃទាំង ២ នាក់មិនឲ្យមានសេចក្ដីអន្តរាយដោយហេតុផ្សេងៗ ។

ប្រការ ៣ — ខ្លួនអ្នកក៏មានប្ដីដែលទាំងមានសតិបញ្ញា នឹងបានគិតការទំនុកបំរុងព្រះចៅហៀនគេឲ្យសោយរាជសម្បត្តិតទៅ ខ្ញុំឃើញមានប្រយោជន៍ ៣ ប្រការដូច្នេះ ទើបមករំលឹកសតិអ្នក ចូរអ្នកត្រិះរិះតាមគួរចុះ ” ។

គួនអ៊ូឆ្លើយតបថា ដែលអ្នកថាមានប្រយោជន៍ដល់ខ្លួនយើង ៣ ប្រការនោះក៏មែនពិតហើយ តែយើងសុំប្ដេជ្ញាទុក ៣ ប្រការ បើមហាឧបរាជយល់ព្រម យើងនឹងសុំដោះក្រសចេញ ហើយនឹងចុះទៅគំនាប់មហាឧបរាជ តែថាបើសេចក្ដីដែលយើងសុំប្ដេជ្ញានោះខ្វះតែខាងណានីមួយ យើងក៏ស៊ូស្លាប់ក្នុងគ្រានេះ ទោះបីនរណាគរហានិន្ទាថាដូចម្ដេច យើងក៏អស់គិតហើយ តាមចិត្តចុះ ។

គៀវលៀវសួរថា មហាឧបរាជនោះចិត្តជាអ្នកធូរទូលាយពេះពាយនឹងមនុស្សទាំងពួងណាស់ រមែងគប់សមាគមនឹងអ្នកមានជំរេះប្រាជ្ញា បើអ្នកនឹងនិយាយប្រការម្ដេច មុខជាមហាឧបរាជនឹងព្រម តើខប្ដេជ្ញារបស់អ្នក ៣ ប្រការ គឺអ្វីខ្លះ ?

គួនអ៊ូឆ្លើយតបថា “ពីដើមយើងបានស្បថស្បាទ់គ្នាជាមួយនឹងឡៅពី គៀវហ៊ុយថានឹងជួយទំនុកបំរុងព្រះចៅហៀនគេ ទ្រង់អាណាប្រជានុរាស្ត្រឲ្យបាននៅជាសុខក្សេមក្សាន្តតទៅ ឥឡូវបើយើងនឹងទៅនៅធ្វើការជាមួយនឹងមហាឧបរាជនោះ យើងត្រូវសុំឲ្យខ្លួនយើងនឹងនៅជាខ្ញុំព្រះចៅហៀនគេដដែលប្រការ ១ ។

មួយទៀត យើងសុំប្រណិប័តន៍រក្សាបងថ្លៃយើងទាំង ២ នាក់ នឹងកុំឲ្យអ្នកឯណាចូលចេញជាទីមើលងាយឲ្យដល់មាត់ទ្វារទីលំនៅបាន ហើយ

ទឹងសុំបៀវត្សរបស់ទ្បាតីដែលធ្លាប់បានព្រះរាជទាននោះ   មកឲ្យបងថៃ្ង យើងទាំង២តទៅ នេះប្រការទី ២ ។

"ប្រការទី ៣ បើយើងបានដឹងឮថា ទ្បាតីទៅនៅទីឯណា ទោះបី យើងមិនបានជួបលោកមហាឧបរាជក្តីណា      យើងក៏សុំទៅរកទ្បាតី វេលានោះ  សូម្បីមហាឧបរាជទឹងឃាត់ហាមយើង ៗ ក៏ពុំព្រមស្តាប់ឈប់ ខានឡើយ  ។

វិសេចក្តីទាំង ៣ ប្រការនេះ  ចូរអ្នកនាំទៅដំកបស្នើទឹងមហាឧបរាជ ចុះ  បើយល់ព្រមតាមខបួជានេះហើយ    យើងនឹងរៀបខ្លួនទៅនៅផង កុងវេលានេះ"  ។

តៀវលៀវកឹលាគួនអ៊ូឡើងសេះចុះទៅជួបទឹងចូឆូ   ហើយពណ៌នា រឿងរ៉ាវដែលបាននិយាយទឹងគួនអ៊ូនោះឲ្យស្តាប់គ្រប់ប្រការ  ។

ចូឆូបានស្តាប់គ្រប់ប្រការក៏អស់សំណើច   ហើយនិយាយទឹងតៀវ លៀវថា  ដែលគួនអ៊ូមិនព្រមទៅទឹងយើងនោះ  ព្រោះយើងគ្រាន់តែជាទី មហាឧបរាជ   គួនអ៊ូព្រមជាខ្ញុំព្រះចៅហៀនតេក៏ដូចជាបាវយើងដែរ  បើ យើងបង្គាប់បញ្ជាការអ្វីជាផ្លូវរាជការ   គួនអ៊ូក៏មិនត្រូវទទឹងតាស់បាន  ខ ដែលគួនអ៊ូថា  ទឹងសុំប្រណិប័តន៍រក្សាបងថ្លៃទាំង ២  មិនឲ្យអ្នកឯណាប្លែក ប៉ុមចូលទៅដល់ទ្វារទីលំនៅនោះយើងក៏ព្រម   សព្វថ្ងៃនេះកុំថាតែករិយា ទ្បាតីឡើយ  សូម្បីករិយាតូចចុះទៅ  យើងក៏មិនត្រូវចូលចិត្តឲ្យធ្វើផ្តេស ផ្តាសសោះ      ដែលគួនអ៊ូសុំបៀវត្សរ៍ទ្បាតីមកឲ្យបងថ្លៃចាយរាយប្រើ ប្រាស់នោះ   យើងនឹងឲ្យទ្វេឡើងទៀត,   តែខដែលគួនអ៊ូដឹងថាទ្បាតី

នៅទីណាតំបន់ណា ហើយគួនអ៊ូទឹងទៅគេគ្នាមិនបាច់លះយើងនោះ ( ចូចូ
ក្រីក្បាល ) យើងមិនយល់ពែមសោះ បើគួនអ៊ូសុំប្ដេជ្ញា យ៉ាងនេះហើយ
យើងយកមកចិញ្ចឹមរក្សាទុកឲ្យមានកំឡាំងទឹងបានជាប្រយោជន៍អ្វី ។

តៀវលៀវឆ្លើយថា "មហា ខុ.បពជមិនជ្រាបទេឬ ក្នុងនិទានអ៊ុយៀងដែល
មានមកពីបុរាណថា "ពីដើមអ៊ុយៀងនៅទឹងតុងហាងចៅហ្វាយស្រុក,
"តុងហាងចិញ្ចឹមរក្សាអ៊ុយៀងជាជំនួសខ្លួនប្រើប្រាស់ លុះនៅមកមាន
"ឈ្មោះឃីប៉េកចៅហ្វាយស្រុកមួយនោះលើកកងទ័ពទៅសម្លាប់តុងហាង
"ស្លាប់ ឃីប៉េកក៏បានអ៊ុយៀងទៅចិញ្ចឹមរក្សា ហើយតាំងអ៊ុយៀងឲ្យធ្វើ
"នាហ្មឺនទីប្រឹក្សា អ៊ុយៀងក៏បានសេចក្ដីសុខជាយូរតមក ក្រោយនោះ
"សៀងជូចៅហ្វាយស្រុកហាន់កុក លើកទ័ពទៅច្បាំងសម្លាប់ឃីប៉េកស្លាប់
"អ៊ុយៀងមានកំហឹងចងអាឃាតព្យាបាទនឹងសៀងជូ ក៏ទៅដល់ស្រុកហាន់
"កុក ហើយចូលទៅលាក់ខ្លួនពួនក្នុងទីកំបាំង ប្រាថ្នាដើម្បីនឹងធ្វើសៀងជូ
"ឲ្យដល់នូវសេចក្ដីស្លាប់ សៀងជូចាប់បានអ៊ុយៀងដល់ ២ គ្រាមិនបាន
"យកទោស ឲ្យលែងអ៊ុយៀងទៅវិញ លុះខាងក្រោយមកអ៊ុយៀងក៏លប
"ចូលទៅនៅលាក់ខ្លួនដល់ទីខាងក្នុង ប្រាថ្នានឹងសម្លាប់សៀងជូឲ្យបាន
"សៀងជូក៏ចាប់ខ្លួនបានទៀត ទើបសួរចំឡើយអ៊ុយៀងថា អ្នកឯងមកធ្វើ
"ប្រទូសរ៉ាយយើងៗចាប់បានដល់ ២ គ្រាហើយ យើងមិនបានយកទោស
"លែងខ្លួនទៅវិញ ខ្លួនមិនបានចូលក្នុងគុកឬ បានជាមកធ្វើយើងទៀត
"យើងក៏ចាប់បាន, ដែលខ្លួនមកចងចិត្តគិតព្យាបាទយើងទាំងម្ល៉េះ ពីព្រោះ
"ហេតុអ្វី? ។ អ៊ុយៀងឆ្លើយថា ពីដើមខ្ញុំបាទនៅទីពឹងតុងហាងៗចិញ្ចឹម

“ ខ្ញុំបាទជាជំនួសប្រើប្រាស់ លុះឃីប៉េកលើកទ័ពទៅសម្លាប់គុនហានឃី-
“ ប៉េកក៏យកខ្លួនខ្ញុំបាទទៅតាំងជានាហ្មឺនទីប្រឹក្សា បានសេចក្តីសុខជា
“ អង្វែងតមក ត្រានេះលោកលើកទ័ពទៅសម្លាប់ឃីប៉េកជាចៅហ្វាយមាន
“ គុណលើខ្ញុំ បានជាខ្ញុំតាំងចិត្តគិតខឹងនឹងលោក ខំរះរកទំនងនឹងប្រទូសរ៉ាយ
“ លោកឲ្យបាន ប្រយោជន៍នឹងតបស្នងសងគុណឃីប៉េកជាចៅហ្វាយខ្ញុំ
“ ដែលលោកចាប់ខ្លួនខ្ញុំបាន ២ ដងហើយលែងទៅវិញ ខ្ញុំក៏មិនអស់សេចក្តី
“ ក្តៅ បានជាលបចូលមកនៅចាំធ្វើអន្តរាយលោកទៀត លោកក៏ចាប់
“ បាន ខ្ញុំក៏ដឹងថាទោសខ្ញុំដល់ស្លាប់ហើយ តាមតែលោកនឹងប្រោស
“ មេត្តាចុះ ។ សៀងជូថា យើងនឹងលែងខ្លួនឲ្យរួចទៅវិញវេលានេះ ខ្លួននឹង
“ នៅធ្វើយើងទៀតឬទេ? ។ អ៊ុយៀងថា បើលោកលែងខ្ញុំទៅទៀត ខ្ញុំក៏
“ នៅចាំចិត្តនឹងគិតធ្វើលោក ត្រាតែសម្រេចទើបខ្ញុំបាត់ខឹង បើលោក
“ អាណិតខ្ញុំ ៗ សុំអាវលោកដែលពាក់នៅខ្លួននោះឲ្យមានចុះ ទើបខ្ញុំអស់
“ កំហឹងនឹងមិនធ្វើលោកទៀតឡើយ, ។ សៀងជូបានស្តាប់ដូច្នោះ
“ ហើយក៏គិតថា អ៊ុយៀងនេះមានសេចក្តីសត្យកតញ្ញូ ក៏ចង់បាន
“ អ៊ុយៀងទុកទើបដោះអាវឲ្យអ៊ុយៀង ៗ ក៏គំនាប់ទទួលយកអាវមកហើយ
“ ក៏ហូតក្រប៊ីចេញរួចក៏កាប់អាវនោះដាច់ជា ៣ កំណាត់ ហើយជំរាប
“ សៀងជូថា ខ្ញុំបាទបានតបគុណឃីប៉េករួចហើយ, អ៊ុយៀងក៏យក
“ ក្រប៊ីនោះ អារកខ្លួនឯងស្លាប់នៅទីនោះ” ។ ឯចិត្តគួនអ៊ូនោះបើ
អ្នកឯណាមានគុណហើយ ក៏មានកតញ្ញូនឹងអ្នកនោះដូចចិត្តអ៊ុយៀង

ឯទៀតពីនឹងគួនអ៊ូនោះមិនមែនបងប្អូនបង្កើតនឹងគ្នាក៏មែន តែមានសេចក្ដីករុណាស្រឡាញ់គ្នាដូចបងប្អូនរួមឧទរជាមួយ ព្រោះបានស្បថស្បាន់នឹងគ្នា គ្រានេះទៀតពីក៏ទៅជាអ្នកតូចចិញ្ចឹមគួនអ៊ូមិនពេញខាត គួនអ៊ូក៏ទៅមានកតញ្ញូនឹងទៀតពី បានជាជាប់ចិត្តជិតដោយមិនបានបោះបង់ចោល ដូចយ៉ាងមហាឧបកជមានករុណាជាជាងទៀតពីជាច្រើន បើបានគួនអ៊ូមកចុកទំនុកបំរុងឲ្យដល់ខាត មុខជាគួនអ៊ូនឹងមានចិត្តកតញ្ញូដល់លោកជាច្រើនឡើងទៀត ” ។

ចូចូនិយាយនឹងតៀវលៀវថា ដែលអ្នកនាំសេចក្ដីមកប្រៀបធៀបដូច្នេះត្រូវណាស់ ចូរអ្នកស្រូតប្រញាប់ទៅប្រាប់គួនអ៊ូចុះ ថាដែលសុំប្ដេជ្ញាសេចក្ដីទាំង ៣ ប្រការនោះយើងព្រមតាមហើយ អ្នកចូរនាំយកខ្លួនគួនអ៊ូចុះមកជួបនឹងយើងជាប្រញាប់ៗ តៀវលៀវក៏លាចូចូឡើងទៅប្រាប់គួនអ៊ូៗ គួនអ៊ូឆ្លើយថា បើមហាឧបកជយល់ព្រមដូច្នោះហើយ អ្នកចូរវិលទៅប្រាប់ឲ្យកងទ័ពដែលឡោមព័ទ្ធយើងទុកនោះ ឲ្យថយទៅវិញឲ្យអស់ យើងនឹងចុះទៅឲ្យដំណឹងបងថ្លៃយើងទាំង ២ នាក់សិន បើមិនមានសេចក្ដីអន្តរាយទេ សឹមចូលទៅគំនាប់មហាឧបកជជាក្រោយ ។ តៀវលៀវក៏ចុះទៅជំរាបចូចូតាមសំដីគួនអ៊ូ ។ ចូចូបានស្ដាប់ដូច្នោះក៏ប្រើបំរើសេះទៅបង្គាប់ទាហានដែលឡោមព័ទ្ធគួនអ៊ូនោះឲ្យលើកកងទ័ពថយមកវិញ ។

## ដំណឹងតាមខ្យល់ក្នុងកន្តារៈ

# លោក ផេង-ជ្រឹវ សាស្ត្រាចារ្យនៅសាលាគរុវិជ្ជាភ្នំពេញ

### ប្រែពីភាសាបារាំងមកជាភាសាខ្មែរ

(តមក)

---

លុះព្រឹកមកដល់ គេឮស្នូរសន្ធឹកស្បែកជើងគឹងគ្រឿងអាវុធនាទីលានក្រាលថ្មមុខក្នុងផ្ទះរបស់លោកតាអៃយ៉ាដ ចំណែកនៅក្បែររបងពួកទាហានប្រចាំការក្នុងក្រុងកាស៊ិ-កាពប៉ូលី ជិះសុទ្ធតែសេះមកតំនាប់ទៅហ្វាយថ្មីដោយបាញ់កាំភ្លើងជាច្រើនណាត់ ៗ

អ្នកបំរើម្នាក់មកជូនដំណឹងលោកតាកាស៊ីដ ដែលចេញពីភូមិដើម្បីស្ទឹងស្នាធំជំរះចិត្ត ខាងក្រោយថ្ងៃសៅហ្មងកន្លងទៅថាៈ

– នាយទាហានគួរតែមកច្រើនណាស់ ៗ

លោកតាអៃយ៉ាដឲ្យសញ្ញាដល់កូនទាំងពីរ រួចទើបជនទាំងបីនាក់នាំគ្នាដើរទៅទទួលលោកមូហាម្មេតណាបចី ៗ លោកនេះមានអនុសេនីយ៍ឯកម្នាក់អនុសេនីយ៍ទោពីរនាក់ អនុសេនីយ៍ត្រីបីនាក់ជូនមកផង ៗ

លោកមានបំណងសំដែងការអុកធុក ជំសមគួរចំពោះយោបល់របស់លោក ដ្បិតក្នុងប្រាជ្ញលោក គឺជាការស្រុះស្រួលដើម្បីបញ្ជូនកូនប្រុសច្បង នៃលោកតាកាស៊ីដទៅកាន់សេចក្តីស្លាប់ ៗ

លោកវរសេនីយ៍ត្រីព្រមទាំងបរិវារ នាំគ្នាចូលទៅកាន់សាលកិត្តិយសៗនៅខាងក្រៅ ពួកទាហានបាញ់កាំភ្លើងបន្តឥតឈប់ ៗ លោកវរសេនីយ៍ត្រីនិយាយដោយសំដីយ៉ាងខ្លាំង ហើយបែរចំពោះមករកមុក្តារថាៈ

– គឺក្រុមទាហានប្រចាំការនោកាសិ កាពប៊ូលីបាញ់កាំភ្លើងគំនាប់ឯង ។ មុក្តារស្នួរថា:

– រឿងនេះដូចម្តេច? តើមាន...

– ប្រាកដមែន មុក្តារបេន-អៃយ៉ាដ! ពួកទាហានទាំងនោះបញ្ចេញមតិយកឯងជានាយរបស់គេ អញទាំងឯងជាមេតម្រុតទ័ពបំនួសរស្រៀមបេន-គាប់ជាឡ:ដែលអាក្សត់សម្លាប់ពីថ្ងៃមុន ។ រួចឈប់ដកដង្ហើមឲ្យស្រួល ទើបលោកវរសេនីយ៍ត្រីចាប់ដាវតម្រុត ដែលនាយទាហានហុចមកឲ្យប្រគល់ចំពោះអ្នកកំឡោះជាកូនលោកតាកាអ៊ីដអៃយ៉ាដ ហើយស្រែកដោយសំឡេងរំពងអស្ចារ្យថា:

– លោកអនុសេនីយ៍ទោ មុក្តារបេន-អៃយ៉ាដលោកត្រូវអញ្ជើញទៅកាន់កងទ័ពវេលាព្រឹកស្អែកជាកុំខាន ។

រួចលោកបែរមករកអ៊ីស្មាអ៊ីល ហើយប្រាប់ថា:

– ចំណែកឯណោះ អនុសេនីយ៍ឯក អ៊ីស្មាអ៊ីល-បេន-អៃយ៉ាដ លោកត្រូវនាំកងទ័ពអូដ្ឋទៅបន្ទាយមួយឈ្មោះកស្រ្កាម៉ិត ។

លោកវរសេនីយ៍ត្រីគំនាប់លោកតាអៃយ៉ាដតាមរបៀបទាហាន រួចក៏ដឹកពលទៅកាន់បន្ទាយមួយអន្ទើនឹងនាយទាហានវិញ ចំណែកកាំភ្លើងមិនទាន់ឈប់បាញ់នៅឡើយ ។

ខណៈនោះ កាលលោកតាអៃយ៉ាដ នៅតែឯងជាមួយនឹងបុត្រទាំងពីរដែលជោគរសនាអាក្រក់ ធក់កន្ទ្រាក់ចេញពីដើមទ្រូង លោកមានមុខផ្ទប់ស្រពោនរកថាអ្វីមិនកើត ។ លោកនឹកឃើញថាខ្លួនលោក

ជាបុគ្គលឯកោ  អនាថាអស់សង្ឃឹមលើបុត្រសំឡាញ់ទាំងពីរដែលបំរុងនឹងផ្ដើមគំនិតនឹងជីវិតទាំងមូល សេចក្ដីទុក្ខគ្មានទីបំផុតរុករានទន្ទ្រានដួងព្រលឹងរបស់លោក ។ លោកក្រោបលើស្មានៃអ៊ីស្មាអ៊ីល រួចទាញមុក្ការមកឱបនាដើមទ្រូងហើយតាំងបង្ហូរទឹកភ្នែកដោយស្ងៀមស្ងាត់ ។ ក្នុងផ្ទះដែលធ្លាប់ជាទីអាស្រ័យនៅដោយសិរីសួស្ដី ឥឡូវស្រមោលនៃសេចក្ដីទុក្ខចាំងចូលមកហើយ ។

---

### វគ្គទី ៨

## បន្ទាយកស្សាម៉ុត

កងទាហានអ៊ីស្មាអ៊ីលធ្វើដំណើរចេញទៅក្នុងវេលាយប់ ។

អ៊ីស្មាអ៊ីលចេញទៅទាំងទុក្ខធំ គេដូចជារសេះរសោះខ្លួនព្រាណដោយទុក្ខវេទនាខ្លាំងក្រៃពេក គេរកតែកម្លាំងនឹងទៅចួបគូស្នេហាមិនកើត ។

ឱ! គួរឲ្យរហែកដើមទ្រូងពេកណាស់ នៅក្នុងទីលានក្រាលថ្មកែវកាលសត្តអួដ្ឋ គេរៀបចំចងគ្រឿងប្រដាប់ដាក់កែបរួចហើយ ។ គេនឹងឡើងជិះវេលាណា គេបានឮស័ព្ទបម្រៀងរបស់នាងឡូឡាស្រួយស្រែះថា:

– " សេចក្ដីស្នេហារបស់ស្ត្រី គឺជាម្ហូបនៃគ្នោតលើវាលខ្សាច់...

ប្រាកដមែន គឺជាការរយៈថ្មើមប្រមាត់ដោយពិត រួចផលនេត្រហៀរហូរមួយរំពេច ប៉ុន្តែគេត្រឡប់សង្កត់ចិត្តទៅវិញ គេមិនត្រូវការតម្រាប់អ្នកទន់ខ្សោយមិនគួរដល់វង្សត្រកូលរបស់គេ ។ កាលដែលសត្វអូដ្ឋចេញដើរទ្រែកៗទៅ គ្មានអារម្មណ៍អ្វីដ៏ធំមកសំដែងឲ្យឃើញក្នុងដួង

វិញ្ញាណ ក្រៅពីធម្មជាតិមួយដ៏អស្ចារ្យគឺឡូឡាឡើយ ។ ម្ល៉ោះហើយ ចិត្តានុភាពរបស់គេក៏ត្រឡប់លិចចុះទៅក្នុងសេចក្ដីអន់ខ្សោយវិញ ។

ត្រូវបេះស្រឡាញ់ដើម្បីឲ្យដឹងថា ការបាត់មុខបែបយ៉ាងណាទៅ ។

ខ/ មានអ្នកខ្លះពេល ចូលចិត្តថាការបែកចេញពីគ្នាជាចំណុចយ៉ាងប្រសើរដល់សេចក្ដីស្នេហា ហើយថាគេមិនសូវឃើញគ្នា គេរិតស្រឡាញ់គ្នាណាស់ ។ បើគេប្រទះម្ដង ទើបគេនឹងដឹងថា . . . ។

មានស្រីជាច្រើន លុះបានគ្នាក្រម តាមសេចក្ដីខាងលើ ទៅឯខាងផ្ទះឪពុកម្ដាយប្រាំបីថ្ងៃ ស្រាប់តែសេចក្ដីស្នេហាយ៉ាងប្រសើរទៅឯណាបាត់អស់រកមិនឃើញ ។

មានប្រុសជាច្រើន គិតតែត្រៀមខ្លួនទៅក្នុងត្រៀមការហេតុក្នុងពួកបាប-មិត្រដែលគិតតែក្បត់ចិត្តគ្នាឯង បានទៅចួបនឹងប្រពន្ធដោយពេលដោយខណៈ ហើយមិនបានរួមស្មគ្គសង្វាសដោយញឹកញាប់ ឱប្រុសល្ងង់កំ-សត់ ។ ការបាត់មុខជាទុក្ខកំណាចជាងទុក្ខទាំងពួង ។ ពាក្យទំនៀមរបស់កវីបណ្ឌិតនេះ ត្រូវជានិច្ច ប៉ុន្ដែចំពោះបុគ្គលណាដែលស្រឡាញ់គ្នាទៅវិញទៅមក ។

អ៊ីស្ការ៉ុល មិនយូរប៉ុន្មាន ក៏ប្រាសចាកសេចក្ដីសោកស្រណោះ ព្រោះការលំបាកតាមផ្លូវនឹងសេចក្ដីនឿយហត់ក្នុងដំណើរ តែងតែទាញចិត្តគេឲ្យប្រុងប្រយ័ត្នជានិច្ច ។

(មានត)

# រឿងបល្ល័ង្កទិព្វ សាមសិបពីររឿង

រឿងព្រេងឥណ្ឌៀ

## លោកសមិន ម្ចាស់ធម: តែង

## លោក វ៉ាយ-ប៊ុក ក្រមការ ប្រែរៀបរៀង

(តមក)

---

## និទាននៃរូបទេពនិម្មិតទី ១១

មានមួយថ្ងៃ, ព្រះបាទភោជ:ទ្រង់មានព្រះរាជបំណងចង់ធ្វើបុណ្យរាជាភិសេក ទ្រង់ស្ដេចចូលទៅជិតបល្ល័ង្កទិព្វដើម្បីនឹងគង់ ។ ក្នុងខណ:នោះ រូបទេពនិម្មិតទី ១១ ក្រាបបង្គំទូលថា "បពិត្រព្រះបាទភោជ: សូមទ្រង់ព្រះសណ្ដាប់ ស្ដេចអង្គណាដែលនឹងគង់នៅលើបល្ល័ង្កទិព្វនេះបាន លុះត្រាតែស្ដេចអង្គនោះមានកិត្តិនាមដូចព្រះបាទវិក្រមាទិត្យ ។ ព្រះបាទភោជ:ទ្រង់មានព្រះបន្ទូលសួរទៅរូបទេពនិម្មិតថា: 'តើកិត្តិនាមព្រះបាទវិក្រមាទិត្យនោះ យ៉ាងណាទៅ?" ។ រូបទេពនិម្មិតក៏ក្រាបបង្គំទូលថា:

នៅក្នុងរដ្ឋព្រះបាទវិក្រមាទិត្យ មានមន្ត្រីធំម្នាក់នាម ភទ្រសេន (Bhadrasena) ដែលអនិច្ចកម្មក្រោយបានប្រមូលនូវភោគទ្រព្យមករក្សាទុកជាច្រើន ។ លោកមានបុត្រម្នាក់ឈ្មោះ បុរន្ទ: (Purandara) បុត្រនេះបានចាយទ្រព្យសម្បត្តិនោះអស់គ្មានសល់ ។ ពួកអ្នកនៅជិតខាងមិនបានឃាត់ហាមបុត្រាលោកនោះ ថាកុំឲ្យចាយទ្រព្យសម្បត្តិ

បែបនេះសោះឡើយ ។ មានកល្យាណមិត្តនៃបិតាបុត្រានោះម្នាក់ បានមកជួបនឹងបុរន្ទរៈហើយពោលថាៈ "ឱបុត្រានៃមិត្តខ្ញុំ សម្បត្តិទ្រព្យដែលមិត្តខ្ញុំបានរក្សាទុក ដោយសេចក្ដីព្យាយាមផ្សេងៗ សម្បត្តិទ្រព្យទាំងនេះមិនស្ថិតស្ថេរ (តាមធម្មជាតិរបស់វា) ទេ ឯងយកទ្រព្យសម្បត្តិនេះ ទៅចាយដោយឥតបើគិត ។ កិត្តិយសនៃមនុស្សគឺត្រូវរក្សាទុកនូវទ្រព្យសម្បត្តិនោះ, ព្រះនាងលក្ស្មី (Laxmi) បានទូន្មានប្រៀនប្រដៅតាមសៀវភៅសាស្ត្រៈថាឲ្យរក្សាទ្រព្យសម្បត្តិ, ព្រះវិស្ណុបានជាគ្រូព្រះនាងលក្ស្មីដោយពលភាព ហើយទៅជាមហាកដិកពលោក, ព្រះនាងលក្ស្មីបដិសន្ធិកើតពីសមុទ្រ, បានជាសមុទ្រនោះឈ្មោះថារត-នាករ (Ratnâkar អណ្ដូងរតនៈ) ។ គន្ធព្វកើតពីឧទរព្រះនាងលក្ស្មី ដោយហេតុនេះ បានជាគន្ធព្វគោរពព្រះនាងលក្ស្មី ស្មើនឹងព្រះព្រហ្ម នឹងអាទិទេពឯទៀត ។ ចូរឯងគិតឲ្យមែនទែន; ត្រូវឯងយល់ថា កិត្តិយសបន្តិចបន្តួចនៃមនុស្ស នៅក្រោមបង្គាប់បញ្ជានៃព្រះនាងទេពធីតាលក្ស្មីទាំងអស់ ។ ព្រោះហេតុនេះ ខ្ញុំថាសម្បត្តិទ្រព្យនោះគឺជាព្រះនាងលក្ស្មីនោះឯង, យើងមិនត្រូវចាយទ្រព្យនោះឲ្យហួសហេតុទេ" ។

បុរន្ទរៈ បានស្ដាប់នូវឱវាទព្រាហ្មណ៍ ក៏ពោលតបទៅវិញថាៈ "ឱព្រាហ្មណ៍,ចូរអ្នកស្ដាប់ខ្ញុំ, អ្វីដែលត្រូវតែមកដល់ ក៏ត្រូវតែមកដល់ដូចទឹកដូង ទោះបីសេចក្ដីព្យាយាមឃាត់ទាំងយ៉ាងណាក៏ដោយ ។ ដូចយ៉ាងទ្រព្យសម្បត្តិដែលត្រូវវិនាស, ក៏ត្រូវតែអស់ទៅៗ តើទ្រព្យសម្បត្តិនោះអស់ទៅតាមផ្លូវណា? គ្មានអ្នកណាអាចបញ្ជាក់បាន; ដូចគ្រាប់ផ្លែ (ខ្វិត)

(Kapitha) ដែលជំរើបរិភោគ ។ បើទុកណាជាគេព្យាយាមរក្សាទុកនូវទ្រព្យសម្បត្តិនោះយ៉ាងណាក៏សេចក្តីព្យាយាមនោះឥតប្រយោជន៍" ។

បុរទ្ធរៈ ក្រោយដែលមិនព្រមស្តាប់ពាក្យព្រាហ្មណ៍, ក៏តាំងតែចាយទ្រព្យសម្បត្តិនោះតទៅទៀតរាល់តែថ្ងៃ ទាល់តែធ្លាក់ខ្លួនក្រលំបាកដុនដាប; គ្មានអ្នកណាទៅជិតគាត់, យល់គាត់ថាជាអ្វីឡើយ ។ បុរទ្ធរៈ ត្រូវគេប្រមាថមើលងាយគ្រប់ៗគ្នា, គាត់ព្រួយលំបាកខ្លាំង ទើបគិតថា: "ព្រៃដែលខ្វានទឹងសត្វសាហាវនៅ, ព្រៃដែលមានគល់ឈើជាទីនៅ, មានស្លឹកឈើផ្លែឈើជាអាហារ, មានសម្បកសម្រាប់ធ្វើគ្រឿងស្លៀកពាក់, មានស្មៅជាគ្រែដេក គឺជាកន្លែងដែលមនុស្សគ្មានភោគទ្រព្យនៅអាស្រ័យ, មនុស្សបែបនេះនឹងមានដម្លៃអ្វី បើនៅជិតបងប្អូនញាតិមិត្ត ដែលកើតក្រមដោយមានភោគទ្រព្យ" ។ ដល់គិតយ៉ាងដូចនេះ បុរទ្ធរៈ ក៏ធ្វើដំណើរទៅកាន់បរទេសទៅ ។

បុរទ្ធរៈ កាលត្រាច់ទៅតាមភូមិភាគ ក៏បានទៅដល់ទីក្រុងមួយដែលនៅជិតភ្នំ លាលយៈ (Malaya) ហៅថា នគរបិតបុរៈ (pitapura) នៅក្នុងនគរនោះ ពេលយប់គេបានឮនូវសូរសព្ទ នៃស្រីយំស្រែកគួរឲ្យអាសូរពន់ពេក ។ ដល់ព្រឹកឡើង បុរទ្ធរៈក៏សួរអ្នកនៅក្នុងក្រុងថា ពីយប់មិញ ខ្ញុំឮស្ត្រីយំស្រែក តើដោយហេតុអ្វី? ។ ពួកអ្នកនៅក្នុងភូមិតបថា: "យើងបានឮស្ត្រីយំស្រែកដែរ តែយើងមិនដឹងជាហេតុអ្វីបានជាស្ត្រីនោះស្រែកយំ ។ កាលស្ត្រីនោះយំស្រែករាល់យប់យ៉ាងនេះ, យើងខ្លាចក្រែងមានគ្រោះថ្នាក់ដល់យើង, យើងក៏ភ័យជានិច្ច" ។

កាលណាបុរទ្វារៈវិលត្រឡប់មកកាន់ប្រទេសខ្លួនវិញ, ២-៣ ថ្ងៃក្រោយមក ក៏ចូលទៅក្រាបបង្គំទូលព្រះបាទវិក្រមាទិត្យអំពីរឿងនេះ ។ ព្រះអង្គទ្រង់ព្រះសណ្ដាប់ហើយ ទ្រង់មានព្រះរាជហឫទ័យចង់ជ្រាបនូវរឿងនេះឲ្យច្បាស់លាស់, ហើយដើម្បីនឹងឲ្យស្គាល់ជាក់លាក់នូវហេតុនៃទុក្ខស្ត្រីនេះ ទ្រង់ក៏ហោះទៅតាមអាកាសដោយព្រះសុពណ៌បាទពិសិដ្ឋទៅកាន់ទីក្រុងបិតបុរៈ នាំយកបុរទ្វារៈទៅជាមួយផង ។ ដល់ទ្រង់ស្ដេចយាងទៅដល់ ទ្រង់ក៏ស្វែងរកស្ត្រីនេះ ។ នៅឆ្ងាយបន្តិចពីទីក្រុង, ក្នុងព្រៃធំ, ទ្រង់បានទតទៅឃើញស្ត្រីនោះយំ ។ ក្នុងពេលដែលស្ត្រីនោះស្រែកទ្រហោយំ, ទ្រង់ក៏ស្ដេចយាងទៅក្នុងព្រៃនោះកាន់តាំងព្រះខ័នថ្ងស្ដេចយាងឆ្ពោះទៅកាន់ស្ត្រីនោះ ។ ដល់ទ្រង់ស្ដេចយាងទៅជិតស្ត្រី, ទ្រង់បានទតឃើញកសសៈ មានមុខសម្បើមអស្ចារ្យ, បានវាយស្ត្រីនោះយ៉ាងខ្លាំងដោយឥតមេត្តា ។ ព្រះបាទវិក្រមាទិត្យទ្រង់បានទតឃើញ, ទ្រង់មានព្រះរាជហឫទ័យករុណាអាសូរដល់ស្ត្រីនោះពន់ពេក, ក៏មានព្រះរាជឱង្ការទៅកាន់កសសៈថា នៃកសសៈកំឡៅ ហេតុម្ដេចក៏ឯងវាយស្ត្រីខ្សោយនេះ? តើឯងជាអ្វី? មកនេះ, វាយនឹងអញ, បើឯងចិត្តគ្រាន់បើ ។ កសស បានស្ដាប់នូវព្រះបន្ទូលព្រះមហាក្សត្រិយ៍ ក៏ខឹងជាខ្លាំង ហើយស្ទុះចេញមកច្បាំងនឹងទ្រង់ ។ ដល់ទ្រង់តយុទ្ធនឹងកសស.មួយស្របក់, ទ្រង់ក៏កាត់ក្បាលកសសៈនឹងព្រះខ័នថ្ងបាន ។ ក្នុងមួយរំពេច, ស្ត្រីនោះសប្បាយចិត្តដូចជាស្លាប់ហើយមានជីវិតរស់ឡើងវិញ ក៏ចូលទៅជិតទ្រង់ធ្វើអញ្ជលិកម្មហើយសរសើរទ្រង់ថា:

"បពិត្រមហារាជ, ដែលព្រះអង្គទ្រង់ពិឃាតកសសៈនេះ, ដោយសម្លាប់ពស់, ដូចជាគ្រុឌ ដែលសំដែងសេចក្ដីល្អ ព្រះអង្គឈ្មោះថាបានព្រះរាជទាននូវជីវិតឱ្យដល់ខ្ញុំម្ចាស់ ។ តើខ្ញុំម្ចាស់នឹងធ្វើអ្វីដើម្បីតបស្នងនូវព្រះតេជៈព្រះគុណព្រះអង្គ? ខ្ញុំម្ចាស់គ្មានកូនប្រុស, គ្មានកូនស្រីទេ ។ បើខ្ញុំម្ចាស់មានកូនប្រុសស្រី ខ្ញុំម្ចាស់នឹងថ្វាយព្រះអង្គជាខ្ញុំបម្រើព្រះបាទាព្រះអង្គ" ។ ក្រោយដែលបានក្រាបបង្គំទូលថ្វាយខ្លួនចំពោះព្រះអង្គ, ស្ត្រីនោះក៏ក្រាបជិតព្រះបាទាព្រះអង្គ ។ ដល់នាងក្រោកឡើង, នាងក្រាបបង្គំទូលទ្រង់ថា: "តាំងពីថ្ងៃនេះទៅ, សូមព្រះអង្គទុកខ្ញុំម្ចាស់ជាទាសីរបស់ព្រះអង្គ, ខ្ញុំម្ចាស់មានថូមាសប្រាំបួនរយ, ខាងក្នុងថូនោះពេញទៅដោយដុំមាស, សូមព្រះអង្គទុកសម្បត្តិនេះជាព្រះរាជទ្រព្យរបស់ព្រះអង្គ" ។ ព្រះបាទវិក្រមាទិត្យ ទ្រង់ព្រះសណ្ដាប់នូវវាចាបុះបូលរបស់ស្ត្រី, ទ្រង់ព្រមទទួលនូវសម្បត្តិទាំងនេះ តែទ្រង់បានប្រគល់ឱ្យដល់ស្ត្រីនឹងបុរទ្ធៈនោះវិញ ។ ដល់ទ្រង់បានបាត់បែងបុរទ្ធៈឱ្យបាននូវស្ថានភាពបែបនេះ, ទ្រង់ក៏ហោះទៅលើអាកាសដោយព្រះសុពណ៌បាទពិសិដ្ឋ វិលត្រឡប់មកកាន់ព្រះរាជនិវេសនដ្ឋានវិញ ។

រូបទេពនិម្មិតទី ១១ កាលបានក្រាបបង្គំទូលព្រះបាទភោជៈនូវនិទាននេះ រួចទូលថា: "បពិត្រព្រះបាទភោជៈ ទ្រង់បានជ្រាបនូវសប្បុរិសធម៌នៃព្រះបាទវិក្រមាទិត្យហើយ បើទ្រង់មានសប្បុរសបែបនេះ, ទើបទ្រង់អាចនឹងគង់លើបល្ល័ង្កទិព្វនេះបាន ។ ព្រះមហាក្សត្រភោជៈ

ដល់ទ្រង់ព្រះសណ្ដាប់នូវកថានៃរូបទេពនិម្មិត ទ្រង់ក៏បោះបង់មិនបាន ធ្វើពិធីរាជាភិសេកក្នុងថ្ងៃនេះ ។

## និទាននៃរូបទេពនិម្មិតទី ១២

មានកាលមួយថ្ងៃ ព្រះមហាក្សត្រិយ៍ភោជៈទ្រង់ស្ដេចយាងចូលទៅជិតបល្ល័ង្កទិព្យដើម្បីនឹងធ្វើរាជាភិសេក ។ រូបទេពនិម្មិតទី ១២ ពោលថា "ឱព្រះបាទភោជៈ បើទ្រង់មានព្រះរាជបំណង នឹងគង់លើបល្ល័ង្កទិព្យនេះ, ត្រូវទ្រង់មានព្រះរាជហឫទ័យទូលាយស្មើនឹងព្រះបាទវិក្រមាទិត្យ" ។ ព្រះបាទភោជៈតបថា "តើព្រះបាទវិក្រមាទិត្យទ្រង់មានសប្បុរសធម៌យ៉ាងណាខ្លះ?" ។ រូបទេពនិម្មិតក្រាបបង្គំទូលថា: "សូមព្រះបាទភោជៈទ្រង់ព្រះសណ្ដាប់ ។

មានកាលមួយថ្ងៃ ព្រះបាទវិក្រមាទិត្យ ទ្រង់ស្ដេចហោះទៅលើអាកាសដោយព្រះសុពណ៌បាទពិសិដ្ឋ ទ្រង់យាងទតប្រទេសជាច្រើន ។ ទ្រង់យាងទៅដល់កន្លែងមួយ, ទ្រង់ទតឃើញនូវមាត់ទន្លេ មិនឆ្ងាយពីទន្លេនោះប៉ុន្មាន មានព្រះវិហារព្រះអាទិទេពមួយ, ឃើញពួកព្រាហ្មណ៍បណ្ឌិតអង្គុយសន្ទនាគ្នាទៅវិញទៅមកអំពីសាស្ត្រៈ ។ ព្រះបាទវិក្រមាទិត្យទ្រង់យាងចិតចូលទៅជិត ដើម្បីនឹងទ្រង់សណ្ដាប់ នូវការសន្ទនានេះ ។

ក្នុងពេលដែលបណ្ឌិតទាំងនោះ សន្ទនាគ្នាទៅវិញទៅមក, បណ្ឌិតម្នាក់ៗ ខំព្យាយាមគាំទ្រយោបល់តែរៀងខ្លួន, ហើយញែកអត្ថបទនីមួយៗ ដើម្បីនឹងបំបាត់នូវពាក្យពិតនៃសាស្ត្រៈទាំងនោះ ។ ព្រះមហាក្សត្រិយ៍ ដល់ទ្រង់ផ្ទៀងនូវព្រះស្រោតស្ដាប់នូវការបុច្ឆា - វិសជ្ជនា ទ្រង់ក៏មាន

ព្រះបន្ទូលថា "ឱបណ្ឌិត, ចូរលោកស្ដាប់ខ្ញុំ. ការស្វែងរកន័យឲ្យជាក់លាក់នៃសាស្ត្រៈ គឺជាគោលការណ៍នៃបណ្ឌិត, បើកាលណាគេបោះបង់ចោលនូវន័យដ៏ពិតប្រាកដនៃសាស្ត្រ ហើយគេខំព្យាយាមស្ថាបនានូវយោបល់របស់ខ្លួនថាត្រូវថាមែនទៅវិញ ធ្វើបែបនេះគេមិនទុកលោកថាជាបណ្ឌិតទេ ។ អ្នកណាជាបណ្ឌិតពោលនូវពាក្យមិនពិត ដើម្បីឲ្យគេជឿនូវយោបល់របស់ខ្លួន ហើយលះបង់ចោលន័យដ៏ពិតប្រាកដនៃសាស្ត្រៈ អ្នកនោះឯងវង្វេងលែងរកអ្វីឃើញ ហើយនាំឲ្យបាត់បង់ថយចំនួននូវសាវ័កដែលអង្គុយជុំវិញខ្លួនថែមទៀត" ។ ពួកបណ្ឌិតលុះបានស្ដាប់ព្រះបន្ទូលមហារាជ ក៏គិតរៀងខ្លួនថា: "បណ្ឌិតគឺអ្នកណាដែលមានសមត្ថភាពញែកឲ្យច្បាស់លាស់នូវន័យពិតនិងមិនពិតនៃសាស្ត្រៈឯន័យមិនពិតដែលយើងពោល គឺអ្នកនេះយល់ជាក់ច្បាស់, ព្រោះហេតុនេះ យើងគួរទុកជាអ្នកនេះជាបណ្ឌិតទីមួយ ។ ដល់គិតយ៉ាងនេះហើយ, ពួកបណ្ឌិតទាំងអស់ក៏អៀនខ្មាសលែងធ្វើបុច្ឆា វិសជ្ជនាគ្នាទៅវិញទៅមក ។

ក្នុងពេលនោះ, មានបុរសម្នាក់ មានរូបឆោមល្អពន់ពេក, លុះមកដល់មាត់ទន្លេ, បុរសនោះជិតនឹងមរណៈទៅហើយ ។ បុរសនោះក៏ដួលក្រាបទៅលើដី, ពោលទៅរកអ្នកទាំងអស់ដែលនៅជិតនោះថា: "ចូរអ្នកអញ្ជើញមកឆាប់, លោកអ្នកឃើញទេ, តើខ្ញុំយ៉ាងណាក្នុងពេលនេះ? ។ តែបើទុកជាបុរសនោះស្រែកហៅយ៉ាងណា, ក៏គ្មានបុគ្គលណាមួយចូលទៅជិតសោះឡើយ ។

ព្រះបាទវិក្រមាទិត្យទ្រង់ទតឃើញយ៉ាងនេះ, ទ្រង់មានព្រះរាជហឫ-

ទ័យអាណិតអាសូរដល់បុរសនោះពន់ពេក; ទ្រង់ក៏យាងចូលទៅជិតបុរស ហើយទ្រង់ថែទាំរក្សាបីបាច់ដូចជាព្រះញាតិរបស់ព្រះអង្គ ។ បុរសនោះត្រេកអរពន់ពេក ហើយក្រាបបង្គំទូលព្រះនរបតីថា "បពិត្រលោកជាសប្បុរស, លោកជាញាតិសាលោហិតរបស់ខ្ញុំ (ប្រហែលបុរសនោះមិនដឹងថា បុរសដែលថែទាំនេះជាព្រះបាទវិក្រមាទិត្យទេ); ព្រោះថាជនដែលជាញាតិពិត គឺអ្នកដែលមកជួយស្រោចស្រង់ក្នុងពេលដែលខ្ញុំកំពុងមានទុក្ខលំបាក ។ ព្រោះហេតុនេះ ក្នុងគេហដ្ឋានខ្ញុំ មានទិព្វកណ្ឋៈមួយឈ្មោះមូលិកា, ទិព្វកណ្ឋៈនោះខ្ញុំជូនលោក, ចូរលោកយកទៅ, របស់នេះបើអ្នកប្រាថ្នាចង់បានអ្វី ៗ នឹងបានដូចបំណងភ្លាម ៗ" ។ លុះពោលពាក្យយ៉ាងនេះហើយ បុរសនោះក៏ថ្វាយទិព្វកណ្ឋៈនោះទៅមហារាជ, រួចអនិច្ចកម្មក្នុងពេលនោះទៅ ។ ក្នុងមួយរំពេចនោះស្រាប់តែមានស្មូមម្នាក់ចូលទៅជិតព្រះនរបតី ហើយសូមមូលិកានោះថា "បពិត្រមហារាជ, ព្រះអង្គទ្រង់ធ្លាប់ជាអ្នកព្រះរាជទាននូវអំណោយគ្រប់យ៉ាងអ្នកដល់ទុគ៌ត; ទូលព្រះបង្គំសូមព្រះអង្គ ព្រះរាជទាននូវអំណោយអ្វីមួយ ដែលជាហេតុឲ្យផុតពីសេចក្តីក្រលំបាក ។ កាលស្មូមនោះក្រាបបង្គំទូលសូមព្រះភូមិន្ទយ៉ាងនេះហើយ ព្រះរាជាទ្រង់ក៏ព្រះរាជទានមូលិកានោះដល់ស្មូមនោះទៅ, រួចទ្រង់ហោះទៅតាមអាកាសដោយព្រះសុពណ៌បាទពិសិដ្ឋ វិលត្រឡប់ទៅកាន់ព្រះរាជធានីវិញ ។

រូបទេពនិម្មិតទី ១២ ក្រាបបង្គំទូលព្រះមហាក្សត្រិយ៍ថា "បពិត្រព្រះមហាក្សត្រិយ៍គោរព: បើព្រះអង្គទ្រង់មានព្រះទ័យសប្បុរសទូលាយ

បែបនេះទើបទ្រង់អាចគង់លើបល្ល័ង្កទិព្វនេះបាន” ។ ព្រះបាទគោជៈទ្រង់ព្រះសណ្ដាប់នូវពាក្យរបស់ទេពនិម្មិត ក៏លះបង់នូវពិធីបុណ្យមុត្តាភិសេកក្នុងពេលនោះទៅ ។

*

* *

(មានត)

មានទ្រព្យរាប់ថាមានស្នេហ៍អុខ

៤– វិជ្ជា ទាន, សិល្បសាស្ត្រ នឹងសេចក្ដីក្លៀវក្លាហាននៃអ្នកមានទ្រព្យ អ្វីមួយដែលអ្នកក្រីក្រទាំងឡាយមិនសរសើរ? សេចក្ដីពិត, ក្នុងលោកនេះ អ្នកមានទ្រព្យ សូម្បីអ្នកដទៃក៏ក្លាយមកជាញាតិមិត្ត ឯអ្នកក្រីក្រ សូម្បីញាតិមិត្តខ្លួនឯងពិតៗ ក៏ផិតប្រែក្លាយទៅជាសត្រូវវិញ (មិនមានហេតុអ្វី) ក្រៅពីការខ្វះខាតទ្រព្យទេ ។

បញ្ចតន្ត្រ: